ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jun-2015, 10:18
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី២៩៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

កញ្ញា រ៉ូប៊ីន្ទី គ្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោកស្រី ទី ស្រ៊ីនណា

លោក ឡៃ ជុនធី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ចាន់ ម៉ន (2-TCW-975) | ខ្មែរ |
| លោក កែវ គីន (2-TCW-910) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ចាន់ ម៉ន** (2-TCW-975)

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ៤
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ៣៥
សួរដោយលោក គង់ សំអុន ផ្តើមពី....................ទំព័រ ៥៧

**ការសួរសំណួរទៅសាក្សី៖ លោក កែវ គីន** (2-TCW-910)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី....................ទំព័រ ៦៤
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី....................ទំព័រ ៦៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ចាន់ ម៉ន។ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សីមួយទៀត គឺសាក្សី 2-TCW-910។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សវនាការដែលត្រូវមកផ្ដល់សក្ខីកម្ម -- សូមទោស សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក ចាន់ ម៉ន។ សាក្សីមានវត្តមានរួចហើយ នៅបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-910។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះ បានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីម្សិលមិញ។

សូមអរគុណ លោក ប្រធាន។

[០៩:០៣:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ហើយជាដំបូងនេះ អង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខ-ភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥ បានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះ និងវិលមុខពេលអង្គុយ និងបានផ្តល់អនុសាសន៍ថា សូមឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៤:៣២]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដែលដំបូងនេះ គឺសុំប្រគល់ទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសាកសួរលោកនៅព្រឹកនេះ។

[០៩:០៥:៣៨]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**សៈ** ខ្ញុំសុំចាប់ផ្តើមសួរលោកអំពីបញ្ហាមួយចំនួនទាក់ទងទៅនឹងការងារជាកងទ័ពរបស់លោក ចន្លោះពីឆ្នាំ៧៣ ដល់ឆ្នាំ១៩៧៩។ ហើយខ្ញុំសុំបែងចែកពេលវេលានេះទៅជាបីផ្នែក។ ទី១ គឺចន្លោះពី ៧៣ ដល់ ៧៥។ បន្ទាប់មកគឺ ៧៥ គឺនៅពេលរំដោះ រហូតដល់ពេលដែលកងទ័ពជាច្រើនចាប់ផ្តើមទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង គឺប្រហែលជាក្នុងឆ្នាំ៧៦។ ដូច្នេះ ពីដំបូងខ្ញុំចាប់ផ្តើមពីចន្លោះឆ្នាំ៧៣ ដល់៧៥។ តាមសក្ខីកម្មរបស់លោកកាលពីម្សិលមិញ លោកគឺជានីរសាររហូតទៅដល់ឆ្នាំ៧៣ លោកគឺជានីរសាររបស់កងទ័ព។ តើលោកបន្តការងាររបស់លោកជានីរសារហ្នឹងរហូតដល់ពេលរំដោះគឺថ្ងៃ១៧ មេសា ៧៥ ឬមួយក៏យ៉ាងណា?

**លោក ចាន់ ម៉ន៖**

**ឆ៖** ពី៧៣ មកទល់នឹង ៧៥ ហ្នឹង ខ្ញុំនៅកងនីរសាររហូត មកទល់នឹង ៧៥។

[០៩:០៧:២០]

**សៈ** តើលោកជាសមាជិកនៃកង គឺជាកងដែលជាក្រុមការងារដែរឬទេ? តើលោកអាចប្រាប់ឲ្យច្បាស់បន្តិចបានទេអំពីរចនាសម្ព័ន្ធនៃកងពលធំដែលលោកធ្វើការនៅនោះ?

**ឆ៖** អង្គភាពខ្ញុំពីដើម នៅអង្គភាព១២០។ ដល់ពេល ៧៥ ហ្នឹង គេហៅកងពល៥០២ នៅទ័ពអាកាស។

**សៈ** ខ្ញុំយល់ ប៉ុន្តែ ខ្ញុំចង់ជម្រាបសួរលោកថា តើក្នុងនាមជានីរសារហ្នឹង លោកគឺជាផ្នែកនៃកង ហើយកងហ្នឹងគឺជាផ្នែកនៃអនុសេនាតូច ឬមួយក៏យ៉ាងម៉េចដែរ? ខ្ញុំចង់ដឹងថា តើកងពលធំ១២០ ហ្នឹងគេរៀបចំ ឬក៏គេមានរចនាសម្ព័ន្ធយ៉ាងម៉េចដែរ? តើលោកអាចជម្រាបបានទេ?

**ឆ៖** ខ្ញុំជាកងនីរសារមួយសម្រាប់រត់សារ និងនាំសារសម្រាប់តាមអង្គភាព បើអនុសេនាតូច អនុសេនាធំ តាមអង្គភាពកងពល។ ពីអង្គភាពកងពល មកអង្គភាពអនុសេនាធំ អនុសេនាតូច និងតាមកាំភ្លើងធំ កាំភ្លើងតូច។

**សៈ** អ៊ីចឹង លោកគឺជាផ្នែកនៃកងនីរសារ អ៊ីចឹង ហើយអ្នកណាជាប្រធានកងនីរសាររបស់លោក?

**ឆ៖** ប្រធានមានតែប្រធានមន្ទីរទេ ប្រធានមន្ទីរគេហ្នឹង ដូចថា ក្នុងមួយកងពលហ្នឹង គេមានប្រធានមន្ទីរគេមួយ។ ប្រធានមន្ទីរហ្នឹងគឺ កាលជំនាន់ដែលខ្ញុំនៅហ្នឹងឈ្មោះ តាយ៉េង។ ប្រើ ដូចថាយើង

ទៅតាមអង្គភាពតូចៗ។ គេប្រើទៅណាយើងទៅហ្នឹង។

**ស៖** តើក្នុងកងរបស់លោកនុ៎ងមាននីរសារប៉ុន្មាននាក់? ហើយតើប្រធានកងយោធាហ្នឹង តើគេបញ្ជាទៅមនុស្សប៉ុន្មាននាក់ដែរ?

**ឆ៖** នីរសារនៅក្នុងអង្គភាពកងពលហ្នឹងមានបួននាក់។ សម្រាប់នេះហ្នឹងមានបួននាក់ គេបែងចែកដូចថាថ្ងៃដែលចេញវ៉ៃ ឬចេញរត់ទៅទាក់ទងកន្លែងទូរលេខ ឬក៏គេអូអីហ្នឹង គេមានបួននាក់រត់តាមតែថាលេខរៀង។

**ស៖** ថាតើអ្នកណាជាអ្នកផ្ដល់ការណែរនាំ ឬក៏ការបញ្ជាទៅប្រធានមន្ទីរឈ្មោះ ជឹង នោះ? តើនរណាជាអ្នកបញ្ជាទៅគាត់?

**ឆ៖** អ្នកបញ្ជាហ្នឹងគឺគេបញ្ជាពីលើមានកងពល។ កងពលហ្នឹង តាល្វៃ ហើយនិង ម៉េត គេបញ្ជាទៅប្រធានមន្ទីរ។ ប្រធានមន្ទីរហ្នឹងគេប្រើនីរសារហ្នឹង ឲ្យទៅទាក់ទងនៅកន្លែងណា កងណាៗ អាហ្នឹងនៅលើ តាយ៉េង ហ្នឹងជាអ្នកប្រាប់។

[០៩:១២:០៨]

**ស៖** អរគុណលោក។ តើលោកអាចប្រាប់បានទេថា កងទ័ពទាំងអស់ គឺថាកងទ័ពនៅក្នុងកងពលហ្នឹង តើពួកគាត់ទទួលរបបអាហារប៉ុន្មានដែរ? តើបាយ គេទទួលបានប៉ុន្មានដែរក្នុងមួយថ្ងៃ? គឺខ្ញុំចង់និយាយអំពីរបបអាហារពីចន្លោះឆ្នាំ៧៣ ដល់ ៧៥ គឺដល់ពេលរំដោះនោះ?

**ឆ៖** ៧៣ នៅវ៉ៃ នៅវ៉ៃគ្នា នៅប្រទាញប្រទង់គ្នាហ្នឹង អាហ្នឹងគឺបាយកញ្ចប់គេយកពីក្រោយទៅឲ្យ អាហ្នឹងគេវេចបាយកញ្ចប់។ អាហ្នឹងនិយាយពីឆ្នាំ៧៣។ បើថាមកដល់៧៥ ដែលឈប់ពីវ៉ៃគ្នាហ្នឹងមានកន្លែងរៀងៗខ្លួន ដូចថាតាមក្រុម។ ដាំបាយតាមក្រុមហ្នឹង ដូចនៅ៧៥ នៅមកនៅពោធិ៍ចិនតុងនៅអីហ្នឹង គេចែកជាតាមក្រុម គេឲ្យអង្ករដាំរៀងៗខ្លួន តាមក្រុម។ ហើយ១ថ្ងៃហ្នឹង គេដាំដូចបបរល្ងាច -- ព្រឹកហ្នឹងបបរខាប់ទៅ ល្ងាចឡើងបបររាវ។

**ស៖** ពាក់ព័ន្ធទៅហ្នឹងឆ្នាំ៧៣ ដល់ ៧៥ ហើយប្រហែលជាក្រោយមកទៀតនោះ តើគិតទៅប្រហែលក្នុង១ឆ្នាំហ្នឹង តើទាហានហ្នឹងទទួលអង្ករ ឬក៏ទទួលបានបាយប៉ុន្មានថាំងដែរ?

**ឆ៖** គេចែកមកតាមអង្ករហ្នឹងចែក បើថានៅ៧៣ គេចែកតាមក្រុមហ្នឹង មួយទៃម្នាក់ៗ។ គេដាក់មួយទៃៗអីចឹងទៅ។ រាយមួយទៃម្នាក់ហ្នឹង អ្នកណា ដូចថាថ្ងៃនេះដាំទៃខ្ញុំទៅ ស្អែកដាំទៃគេអីចឹងទៅ។ មួយទៃហ្នឹងវាបាន១០ កំប៉ុង ២០កំប៉ុងដែរអាខ្លះ។ យើងមិនបានរាប់ដឹងថាប៉ុន្មានកន្ដាំង ឬប៉ុន្មាន

កញ្ចើ ប៉ុន្មាននេះហ្នឹង អត់មានទេ។ គេច្រកដាក់ទៃ ស្តាយរហូត។ ក្នុងម្នាក់ហ្នឹងដូចថា ថ្ងៃហ្នឹងច្រករបស់ខ្ញុំអីចឹងទៅ គេមិនអស់ក្នុងទៃទេព្រោះខ្លាចមានអាសន្នអីចឹងទៅ យើងរត់បែកគ្នាអីទៅ វាអត់មានអង្ករនឹងប្រចាំក្នុងខ្លួន។ ធ្វើយ៉ាងម៉េចឲ្យបានតែពីរកំប៉ុង ឬបីកំប៉ុងនៅក្នុងទៃ ក្នុងម្នាក់។

[០៩:១៥:៣០]

**ស៖** តើប្រសិនបើខ្ញុំនិយាយថា កងពល៥០២ ទទួលបានប្រហែលជា១៥ថាំងក្នុង១ឆ្នាំ។ តើលោកអាចនឹកឃើញ ឬក៏អាចធ្វើឲ្យលោកចងចាំបានទេ តើការដែលខ្ញុំនិយាយថា ក្នុង១ឆ្នាំ កងទ័ពម្នាក់ៗទទួលបានប្រហែល ១៥ថាំងហ្នឹង វាអាចធ្វើឲ្យលោកអាចនឹកឃើញឬក៏ចងចាំបានឡើងវិញដែរឬទេ?

**ឆ៖** ខ្ញុំចងចាំវាមិនបានទេដែរ អារឿង៥ថាំងហ្នឹង វាមានតែអង្ករនៅក្នុងទៃខ្លួនឯងបន្តិចៗ អត់មានថាគេដាក់មកឲ្យទាំងការុង ទាំងនេះហ្នឹង គឺគ្មាន។ អាហ្នឹងពីឆ្នាំ៧៣ មកគិតពី៧៣ មកគឺគ្មានអង្ករដាក់ការុង ដាក់អីឲ្យគឺអត់មានទេ។

**ស៖** ចន្លោះឆ្នាំ៧៣ ដល់ ៧៥ គឺថាពេលរំដោះនោះ តើលោកហើយនិងសមាជិកកងនីរសាររបស់លោកហ្នឹងមានបាយហូបគ្រប់គ្រាន់ដែរឬទេ? គឺខ្ញុំចង់និយាយថាលោកមានម្ហូបអាហារហូបគ្រប់គ្រាន់ មានកម្លាំង គ្រប់គ្រាន់ដើម្បីវាយប្រយុទ្ធជាមួយកងទ័ពលន់ នល់ បានដែរឬទេ?

**ឆ៖** ពីសម័យហ្នឹង គេបញ្ជូនពីក្រោយទៅគេមានបាយកញ្ចប់ឲ្យហ្នឹងទៅ ហើយម្ហូបហ្នឹង ដូចថាសម័យហ្នឹង ដែលសម័យសង្គ្រាមតឹងតែងមកភ្នំពេញ ដូចថានៅម្តុំ នេះៗជាប់នឹងភ្នំពេញហ្នឹង អាហ្នឹងគេផ្តល់ឲ្យបាយមួយកញ្ចប់ៗរហូត គេយកអង្ករ -- គេយកបាយមកឲ្យ ហ្នឹងអត់ដឹងថាគេដាំពីកន្លែងណាទេ ព្រោះបានកញ្ចប់ហ្នឹងមកពីក្រោយ។ អ្នកដែលនៅមុខហ្នឹងបានតែមួយកញ្ចប់ៗ ព្រឹកឡើងគេយកទៅដល់ៗ ល្ងាចឡើងគេយកទៅដល់ យកមកដល់ឲ្យ។ អត់ៗដែលមានបានដាំនៅសមរភូមិទេ ដាំពីក្រោយមក ហើយនីរសារហ្នឹងនៅតែជាប់នៅនឹងមុខហ្នឹងឯង ជាមួយក្បែរថ្មើរជើង ក្បែរកាំភ្លើងធំហ្នឹងឯងសម្រាប់ទៅទាក់ទងរត់តាមអាដែង កាលហ្នឹងជិតមកចូលវាយភ្នំពេញហ្នឹង អាហ្នឹងនៅជាប់នៅហ្នឹងឯងអត់មានចេញទៅក្រៅរួចទេ ក្រោយគេមិនសូវឲ្យទៅទេ នៅតែមុខ។

[០៩:១៨:៤៥]

**ស៖** ប៉ុន្តែខ្ញុំចង់ដឹងថាតើលោកហើយនិងកងទ័ពដទៃទៀតមាន ម្ហូបអាហារគ្រប់គ្រាន់ហូបដែរឬទេ មុនឆ្នាំ -- មុនថ្ងៃ ១៧ មេសា ឆ្នាំ៧៥នោះ?

**ឆ៖** មិនៗមានអីគ្រប់គ្រាន់ទេ តាំងពីនេះមកដូចតែអីចឹងរហូត។ មានតែបាយកញ្ចប់ហូបអត់

ហូបមានគ្រប់គ្រាន់ បើយើងចេញមកដូចនៅសមរភូមិហ្នឹង តឹងតែងយន្តហោះអី មិនសូវទម្លាក់ មិនសូវអី អាចរកអាហ្នឹងហូប កាលជំនាន់ហ្នឹងវាសម្បូរត្រីតាមបឹង តាមអី ចេះតែបានអាហ្នឹងហូបទៅវាមិនសូវអីដែរ ម្ហូបអី បរិបូណ៌រកខ្លួនឯងបាន ជាប់ៗផ្លូវ។

**សៈ** ចុះក្នុងរយៈពេលក្រោយរំដោះគឺ ក្រោយរំដោះ គឺក្រោយ គឺចាប់ពីខែមេសា ៧៥ ដល់ដាច់ឆ្នាំ៧៥ ថាតើលោក ហើយនិងកងទ័ពនៅក្នុងកងរបស់លោកហ្នឹង ថាតើមានម្ហូបអាហារហូបគ្រប់គ្រាន់ប្រចាំថ្ងៃដែរឬទេ?

**ឆៈ** ពេលហ្នឹង ដូចថាវាមកដល់ក្នុងទៅ វាមាន។ ចូលមកដល់ភ្នំពេញហើយ មានតាមអង្គភាពហ្នឹង តាមក្រុមតាមអីហ្នឹង គឺបានម្ហូបរកខ្លួនឯងហ្នឹង ហូបគ្រប់គ្រាន់ តែវាបែកគ្នា ដូចថា គេបំបែកជាក្រុមៗអស់ អត់មាននៅជុំគ្នាបានទេ។ គេបំបែកទៅដាក់តាមក្រុម តាមអង្គភាពផ្សេងៗ យកទៅដាក់ដូចថា ចោមចៅទៅ ទៅស្ទឹងមានជ័យទៅ ទៅផ្សារថ្មីទៅ ទៅអីចឹង គេផ្លាស់ប្តូរគ្នាអស់ទៅ ដូចជាខ្ញុំអីនៅពីរនាក់ នៅនឹងពោធិ៍ចិនតុង។ ផុតពីនោះបែកគ្នាអស់ ខ្លះគេទៅនៅខាងជើងទឹក គេយកទៅជើងទឹកជើងអីបាត់ បែកគ្នាខ្ចាត់ខ្ចាយអស់ហើយ អាហ្នឹងអត់មានទៀតទេ ហ្នឹងក្រុមខ្ញុំហ្នឹង។

[០៩:២១:០៦]

**សៈ** តើខ្ញុំអាចនិយាយបានទេថា លោក ហើយនិងកងទ័ពដទៃទៀតហ្នឹង គឺមានម្ហូបអាហារគ្រប់គ្រាន់ គឺក្នុងឆ្នាំ៧៥ គឺក្រោយថ្ងៃរំដោះ១៧មេសា រហូតដល់ដាច់ឆ្នាំ៧៥។ តើអីចឹងមែនទេ?

**ឆៈ** ពីរំដោះបានហ្នឹងហើយ ខ្ញុំក៏មិនបានដើរមើលទ័ពថា មានគ្រប់គ្រាន់ ឬមិនមានទេ ព្រោះខ្ញុំគេឲ្យខ្ញុំចេញទៅជូនខាងចិនខាងអី ទៅតាមចិនតាមអី ខ្ញុំវាចេះតែហូបនឹងគេឯង ទៅតាមគេតាមឯងហ្នឹងទៅ។ បើកងទ័ពខ្ញុំមិនបានចូលតាមអង្គភាពគេ គឺមិនសូវបានចូលទេ ព្រោះការងារខ្ញុំផ្សេង គេប្រើទៅ។

**សៈ** តើលោកអាចបញ្ជាក់អំពីម៉ោង ពេលម៉ោងធ្វើការ នៅពេលដែលលោកធ្វើការនៅពោធិ៍-ចិនតុង ក្រោយថ្ងៃរំដោះហ្នឹង តើលោកចាប់ផ្តើមធ្វើការម៉ោងប៉ុន្មាន? ហើយពេលឈប់សម្រាកហូបថ្ងៃត្រង់នៅម៉ោងប៉ុន្មាន? ហើយលោកឈប់ពេលល្ងាច លោកទៅគេងនៅម៉ោងប៉ុន្មានដែរ លោកអាចជម្រាបបានទេ?

**ឆៈ** ដូចអត់មានម៉ោង មានតែព្រឹកឡើងទៅ ដូចម៉ោងប្រាំមួយហ្នឹងគេចេញហើយ ចេញទៅដល់ម៉ោងប្រាំពីរជួបជុំគ្នា គេហៅ បោសសម្អាត។ ដូចទៅមុនដំបូងអីចឹង ដូចក្នុងពោធិ៍ចិនតុង វាមាន

បាក់បែកកន្លែងគ្រាប់ធ្លាក់គ្រាប់អី ហើយបាក់បែកអីវ៉ាន់ ហើយអីវ៉ាន់វានៅពេញតែហ្នឹង ហើយដើរអូស ទៅ រថក្រោះអូស រុញ យន្តហោះអូសអីហ្នឹង ដាក់ប្រមូលម្តុំហ្នឹង គឺគ្មានទេ អត់មានពេលសម្រាកទេ។ សម្រាកតែពេលហូបបាយម៉ោងមួយដណ្តប់ហ្នឹងឯង ហើយល្ងាចឡើងម៉ោងប្រាំ បានចេញទៅតាមកន្លែងរៀង១ខ្លួន។

[០៩:២៣:៤៧]

**ស៖** ក្នុងរយៈពេលចន្លោះពីថ្ងៃ១៧ មេសា ៧៥ ដល់ដាច់ឆ្នាំ៧៥ តើលោកមានការព្រួយបារម្ភអំពីជោគវាសនាដែរឬទេ? តើលោកមានការភ័យខ្លាចថាមានអ្វីកើតឡើងចំពោះខ្លួនលោកដែរឬទេ?

**ឆ៖** មុនដំបូង ដែលឆ្នាំ៧៥ហ្នឹង គឺខ្ញុំអត់សូវព្រួយបារម្ភអីទេ មិនសូវចាប់អារម្មណ៍ថាជីវិតខ្លួនម៉េចទេ ព្រោះវារួចពីសង្គ្រាមទៅហើយ វាអត់មានស្អីមកទៀត គ្រាប់កាំភ្លើងគ្រាប់អី គឺគ្មានទេ។ វាធ្លាប់ឆេះអារ វាធ្លាប់អីអស់ហើយ មួយកន្លែង១ឃើញមិត្តភក្តិងាប់ លីមិត្តភក្តិអីអស់ហើយ អាហ្នឹងវាអស់លែងព្រួយបារម្ភ។ ទាល់តែចុងក្រោយមកទៀត ដែលទៅធ្វើនៅព្រលានថ្មីហ្នឹង បានខ្ញុំមានអារម្មណ៍អត់ល្អ។ វាអត់មានវាសនាថា បានរស់មកដល់ថ្ងៃណេះទេ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីរចនាសម្ព័ន្ធកងពលធំ៥០២។ ឥឡូវនេះ យើងនិយាយអំពីដើមឆ្នាំ៧៦។ តើលោកអាចប្រាប់បានទេថាតើមានកងទ័ពប៉ុន្មាននាក់ដែរនៅក្នុងកងពលធំ៥០២នោះ?

**ឆ៖** ពេលកងពល៥០២ ខ្ញុំក្តាប់អត់បានទេ តែច្រើន វាកងពលធំ វាច្រើនបែងចែកនៅពោធិ៍ចិនតុងផង បែងចែកទៅធ្វើនៅព្រលានថ្មីផង ហើយខ្ញុំដល់រួចអីចឹងទៅ ខ្ញុំមិនសូវដែលបាននៅកន្លែងទេ។ គេប្រើទៅតាមខេត្ត ជូនគេតាមខេត្តរហូត អត់ដែលបាននៅជុំនឹងគេទេ។ មិនដឹងថាគេដាក់កងណាអង្គភាពណាទៅត្រង់ណា១ គឺខ្ញុំអត់ដឹងទេ។ ឈប់ដឹងហើយ លែងចេញពីហ្នឹងទៅឈប់រវីរវល់អីនឹងគេនឹងឯងហើយ គេចេះតែប្រើទៅ១ឡានមួយអីចឹងទៅ១ ពីរនាក់ទៅ ជូនកាលម្នាក់ឯងអីចឹងទៅ។

[០៩:២៦:៣៥]

**ស៖** ប្រសិនបើខ្ញុំប្រាប់លោកថា កងពល៥០២ នៅដើមឆ្នាំ៧៧ហ្នឹងមានមនុស្សប្រហែលជា ៥.០០០នាក់ តើវាធ្វើឲ្យលោកនឹកឃើញអំពីចំនួនហ្នឹងឡើងវិញបានដែរឬទេ?

**ឆ៖** ព្រោះខ្ញុំនឹកវាមិនឃើញទេ ព្រោះគេបែងកម្លាំងចែកអីចឹងទៅ ហើយខ្ញុំវាមិនបាននៅជុំនឹងគេទេ។ អត់ មិនដឹងថាអង្គភាពណាខ្លះ ឬក៏ដាក់ត្រង់ណាប៉ុន្មាននាក់១ ខ្ញុំអត់ដឹង។ ដឹងតែខ្លួនឯង គឺព្រឹកឡើងដឹងតែចេញដំណើរ។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ។ តើលោកដឹងទេថា កងពល៥០២ ត្រូវបានបែងចែកទៅជាកងជាច្រើន ទៅជាវរសេនាធំពីរ វរសេនាតូចប្រាំ។ តើលោកនឹកឃើញដែរទេ អំពីចំណុចនេះ?

**ឆ៖** អាហ្នឹង គេបែងចែកអ្នកធំគេបែងចែក ខ្ញុំអត់បានដឹងទេ។ ខ្ញុំអត់ដឹងគេបែងចែកថាអង្គភាពអនុសេនាធំហ្នឹងមានប៉ុន្មាន។ អនុសេនាធំ អនុសេនាតូចមានប៉ុន្មាន។ អនុសេនាតូចហ្នឹងខ្ញុំអត់បានដឹង។ មួយកងពលធំហ្នឹងអត់។ ខ្ញុំដឹងថា កន្លែងខ្ញុំហ្នឹងទីចុងក្រោយមកមានតែពីរនាក់ហ្នឹង នៅសល់តែពីរនាក់ទេ។ ផុតពីនេះគេដកទៅតាមអង្គភាពផ្សេងៗអស់។

**ស៖** ប៉ុន្តែលោកដឹងអំពី -- តើលោកដឹងអំពីចំនួននៃកងពល និងវរសេនាតូចទេ ដូចថា វរសេនាធំ ៥១, ៥២, វរសេនាតូច៥០៤, ៥០៥, ៥០៦, ៥០៧។ តើលោកអាចនឹកឃើញអំពីចំនួនវរសេនាធំ និងវរសេនាតូចដែលបង្កើតបានជាកងពល៥០២ ហ្នឹងដែរឬទេ?

[០៩:២៩:០៨]

**ឆ៖** ខ្ញុំអារឿងគេបង្កើតហ្នឹង គេអត់មានប្រាប់ខ្ញុំផង អត់មានដឹងទេអាហ្នឹង។ អត់ៗដឹង បាទអត់ដឹង ព្រោះខ្ញុំអ្នកនីរសារគេថាតូចតាច សម្រាប់តែគេប្រើទេ។ សម្រាប់តែរដ្ឋការប្រើ។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ ប៉ុន្តែកងនីមួយៗនៅក្នុងកងវរសេនា -- កងពលធំហ្នឹង គឺមាននីរសារនីមួយៗ។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោកដែលជាកងនីរសារមួយដែរហ្នឹង លោកស្ថិតនៅក្នុងកងវរសេនាធំ ឬក៏កងវរសេនាតូចមួយណាដែរ?

**ឆ៖** ខ្ញុំនៅនីរសារកងពលធំ នៅៗនឹងកងពលបណ្តោយ។

**ស៖** តើក្នុងកងរបស់លោកហ្នឹងមានមនុស្សប៉ុន្មាននាក់ដែរ ដែលធ្វើការឲ្យកងពលធំនោះ?

**ឆ៖** មានកងពិសេសនោះ កងពិសេសសម្រាប់កងពលធំនោះ មានមួយក្រុមដែលពិសេសនោះ មាន ១២នាក់ ហើយពិសេសសម្រាប់ទៅតាមកម្លាំងកងពលតូចៗនោះ មាន៥០នាក់។ ហើយកង -- អាហ្នឹង ខ្ញុំដឹងទេ ហើយកងនីរសារក្នុងកងពលធំហ្នឹងមានតែបួននាក់ទេ។

**ស៖** តើត្រឹមត្រូវដែរទេ ប្រសិនបើខ្ញុំនិយាយថាមានកងទ័ពប្រហែលជា ៥០០០នាក់ជាង ធ្វើការនៅក្នុងមន្ទីរនោះ?

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោក រ៉ិចទ័រ កូប៉េ! សូមអញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍!

[០៩:៣១:៥១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ លោកមេធាវី កូប៉េ តាំងពីព្រឹកមក ខ្ញុំស្តាប់ការចោទសំណួររបស់លោកនោះ លោកផ្តល់ព័ត៌មានមួយចំនួនទាក់ទងទៅនឹងអាហារដែលយោធាទទួលបានក្នុងរយៈពេល ១ឆ្នាំ ប្រចាំឆ្នាំនោះ ហើយទាក់ទងទៅកងវរសេនាធំ កងវរសេនាតូច កងពលលេខ៥០២។ តើព័ត៌មានទាំងអស់នេះ ដែលលោកបានរៀបរាប់តាំងពីព្រឹកមិញមកហ្នឹង លោកបានមកពីណាដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកចៅក្រម ឡាវែន៍ រចនាសម្ព័ន្ធរបស់កងពល៥០២ រហូតទៅដល់ខណៈចុងក្រោយនេះ គឺលោកអាចមើលឃើញនៅក្នុង E3/1138, បារាំងគឺមានលេខ 00541739 អង់គ្លេសមានលេខ 0060 2523 និងខ្មែរមានលេខ 00160884។ ហើយបរិមាណនៃស្បៀងអាហារដែលកងទ័ពនីមួយៗទទួលបានគឺ E3/1136 បារាំង-- អង់គ្លេសមានលេខ 0054273-- និងខ្មែរមានលេខ 00160081។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំស្តាប់ទៅ លោកនិយាយដូចលឿនសម្បើមណាស់អ៊ីចឹង។ អាចផ្តល់លេខ ERN ចុងក្រោយគេបំផុតនោះម្តងទៀតបានទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកចៅក្រម គឺថា វាជាឯកសារដែលទំព័រតែមួយសន្លឹកគឺ E3/1138 និង E3/1136។ ដូច្នេះគឺថា លោកចៅក្រមអាចពិនិត្យមើលទៅលើឯកសារហ្នឹងទៅ ហើយឃើញលេខ ERN នៅទីនោះហើយ។

[០៩:៣៤:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើបន្ទាប់មកទៀត ពេលលោកចោទសំណួរបន្តទៀតនោះ សូមឲ្យលោកផ្តល់លេខឯកសារដោយមិនចាំបាច់ឲ្យយើងសុំលោកទេ តើបានដែរឬទេ ធ្វើយ៉ាងដូច្នេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ការពិតទៅ ខ្ញុំប្រើប្រាស់ឯកសារហ្នឹងគ្រាន់តែជាលេខ យោងប៉ុណ្ណោះ។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំនឹងបញ្ជាក់ឡើងវិញគឺបារាំងមានលេខ 0054139-- និងមួយទៀតគឺ E3/3116, 00348764, ខ្មែរមានលេខ 00160084 និង 00160081។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថាប្រហែលជាមានការយល់ច្រឡំហើយ។ ចៅក្រម ឡាវ៉ែន៍ ចង់សួរលោកឲ្យអនុវត្តនូវនីតិវិធីដែលយើងធ្វើកន្លងមក ដោយមិនចាំបាច់ឲ្យយើងជាចៅក្រមហ្នឹងសួរ ឬក៏សុំលោកនូវលេខ ERN និងលេខឯកសារនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ ប៉ុន្តែខ្ញុំនឹងដាក់ឯកសារនេះឲ្យសាក្សីមើល។ ដូច្នេះ ខ្ញុំគ្រាន់តែចង់សួរសំណួរអំពីអង្គហេតុជាដំបូងប៉ុណ្ណោះ។ ប៉ុន្តែលោកចៅក្រមអាចពិនិត្យមើលទៅលើឯកសារនេះ គឺឯកសារដែលមានតែពីរទំព័រប៉ុណ្ណោះ គឺ E3។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះ លោកសាក្សីខ្ញុំប្រាប់ត្រឹមត្រូវដែរឬទេ ដែលថាកងពលដែលលោកធ្វើការហ្នឹង គឺមានមនុស្សប្រហែល៥០០នាក់ជាង ធ្វើការនៅក្នុងមន្ទីរហ្នឹង នៅក្នុងដើមឆ្នាំ៧៦នោះ?

[០៩:៣៥:៥២]

**លោក ចាន់ ម៉ន៖**

**ឆ៖** ខ្ញុំស្តាប់អត់សូវបានទេថា ពីខែណា? ពីឆ្នាំណា?

**ស៖** ខ្ញុំនិយាយអំពីដើមឆ្នាំ៧៦ លោកជាកងទ័ព។ ដូច្នេះខ្ញុំចង់ដឹងឲ្យបានច្បាស់ថាតើ កងវរសេនាធំ ឬក៏កងវរនាតូច ថាតើមន្ទីរកងវរសេនាធំ ឬកងវរសេនាតូចណាដែលលោកធ្វើការ? លោកថាលោកជានីរសារ ដូច្នេះខ្ញុំចង់ដឹងថាតើក្នុងឆ្នាំ៧៦នោះ គឺមានកងទ័ពប្រហែលជា៥០០នាក់ជាង ធ្វើការនៅមន្ទីរកងពលធំ។ តើអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេ -- សហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៩:៣៦:៤៥]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់ឲ្យព្រះរាជអាជ្ញា -- ចង់ឲ្យមេធាវីការពារក្តីគាត់យោងទៅលើកាលបរិច្ឆេទនៅក្នុងឯកសារ។ ព្រោះថាមេធាវីគាត់យោងទៅលើខែឧសភា ឆ្នាំ៧៦ ហើយអ្វីដែលសាក្សីបានឆ្លើយកន្លងមកនោះ គឺថាគាត់មិនដឹងពីរចនាសម្ព័ន្ធកងពលធំនោះទេ។ ដូច្នេះ ខ្ញុំចង់ឲ្យ

មេធាវីការពារក្តីសួរសំណួរទាក់ទងទៅនឹងឯកសារហ្នឹង ហើយគាត់ត្រូវផ្តល់ឯកសារនោះទៅឱ្យសាក្សីផង ព្រោះវាជាឯកសារដែលមានលក្ខណៈស្មុគស្មាញ ហើយស្របទៅតាមអ្វីដែលបានឆ្លើយគឺថា ហើយស្របទៅនឹងអ្វីដែលគាត់ឆ្លើយ គឺថាគាត់មិនបានយល់ច្បាស់ អំពីរចនាសម្ព័ន្ធនៃកងពលធំនោះឡើយ។

[០៩:៣៧:៥០]

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំសូមឆ្លើយដោយសង្ខេបលោកប្រធាន។ ឯកសារនេះត្រូវបានធ្វើពង្រាងនៅក្នុងខែកុម្ភៈ ឆ្នាំ៧៦ ប៉ុន្តែខ្ញុំមិនចាប់អារម្មណ៍ពីលើចំនួននៃកងវរសេនាធំទាំងអស់នោះឡើយ ខ្ញុំគ្រាន់តែចង់ដឹងថាតើ សាក្សីហ្នឹង គាត់ស្ថិតនៅក្នុង -- នៅត្រង់ចំណុចណាមួយនៃរចនាសម្ព័ន្ធកងពលធំ។ គាត់និយាយថាគាត់ជាកងទ័ព ហើយគាត់ក៏ផ្តល់សក្ខីកម្មផងដែរថាគាត់ចូលរួមទាក់ទងទៅនឹងអ្វីៗទាំងអស់ ចន្លោះពីឆ្នាំ៧៥ ដល់៧៩។ គាត់អ្នកយាម គាត់ធ្វើការ ហើយគាត់ត្រួតពិនិត្យមើល។ គឺថាគាត់ធ្វើការងារគ្រប់ទាំងអស់។ ដូច្នេះខ្ញុំគិតថាវាជាការគួរឱ្យចាប់អារម្មណ៍ ដូច្នេះខ្ញុំចង់ដឹងថាតើគាត់ស្ថិតនៅក្នុងផ្នែកណាមួយ ឬក៏ស្ថិតនៅក្នុងឋានានុក្រមណាមួយនៃកងពលធំ៥០២។ ដូច្នេះ ខ្ញុំចង់ដឹងថាតើគាត់ស្ថិតនៅក្នុងកងវរសេនាតូចណា កងវរសេនាធំណា គាត់មានមនុស្សប៉ុន្មានណា។ ប៉ុន្តែឥឡូវនេះ គាត់ផ្តល់ចម្លើយមួយដែលមិនសូវច្បាស់លាស់។ ដូច្នេះអ្វីដែលខ្ញុំចង់ធ្វើ ចង់ព្យាយាម គឺខ្ញុំមិនចង់និយាយអំពីឯកសារនោះទេ ខ្ញុំគ្រាន់តែចង់ឱ្យមានការផ្តល់សក្ខីកម្មទាក់ទងទៅនឹងរចនាសម្ព័ន្ធរបស់កងពលធំ៥០២ ព្រោះកងពលធំ៥០២ ជាកងពលធំដែលទទួលខុសត្រូវលើការសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។

[០៩:៤០:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤១:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីសម្រេចលើបញ្ហានេះ ដើម្បីឱ្យបានច្បាស់លាស់ ពីព្រោះតាំងពីព្រឹករហូតដល់ពេលនេះហាក់ដូចជានៅមិនមានលទ្ធភាពក្នុងការដេញដោលហ្នឹងច្បាស់លាស់ទេ ធ្វើឱ្យមាន សាក្សីនេះមិនអាចឆ្លើយបានល្អតបទៅនឹងសំណួរទាំងឡាយដែលសួរឡើងដោយក្រុមមេធាវីការពារក្តីទេ។

សូមអញ្ជើញលោកស្រីចៅក្រម!

[០៩:៤១:៣៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងកត់សម្គាល់ឃើញថាមានការជំទាស់ ប៉ុន្តែមានខាងព្រះរាជអាជ្ញាបានស្នើសុំថា តើត្រូវប្រើប្រាស់ឯកសារដោយរបៀបណា។ មេធាវីការពារក្តីអាចស្នើសុំបង្ហាញឯកសារទៅសាក្សីបាន ហើយការកំណត់អត្តសញ្ញាណឯកសារគឺជាការចាំបាច់បំផុត ហើយបើលោកសួរតទល់ជាមួយនឹងសាក្សីពាក់ព័ន្ធទៅនឹងលេខឯកសារដែលត្រូវប្រើ លោកត្រូវប្រាប់អំពីលេខឯកសារទាំងនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម ហ្វេនស៍។ ខ្ញុំមិនចាប់អារម្មណ៍ពាក់ព័ន្ធទៅនឹងការយល់ឃើញអំពីឯកសារនេះទេ ដោយសារតែសាក្សីមានឋានៈតូចណាស់ ក៏ប៉ុន្តែខ្ញុំចង់ដឹងថាតើរចនាសម្ព័ន្ធកងទ័ពនោះមានប្រត្តិបត្តិការដោយរបៀបណា។ ជាពិសេសគាត់មានទំនាក់ទំនងផ្ទាល់ជាមួយ ស៊ូ ម៉េត គឺថាមិនមែនគ្រាន់តែថា អាចទេ គឺថាជាការគួរឲ្យកត់សម្គាល់បំផុត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី បើខ្ញុំយល់មិនច្រឡំទេ គឺលោកមិនដឹងចំនួនកងទ័ពពិតប្រាកដធ្វើការនៅមន្ទីរកងពលនោះទេ។ តើអ៊ីចឹងមែនទេ?

**លោក ចាន់ ម៉ន៖**

**ឆ៖** មិនៗដឹងទេ ព្រោះគេបែងចែកអស់ទៅ ខ្ញុំអត់ដឹង។ មិនដឹងគេទៅខាងណាខាងណី។

**ស៖** តើលោកជាសមាជិកនៃកងនីរសារហូតដល់ឆ្នាំ១៩៧៩ ឬក៏លោកបានប្តូរតួនាទីរបស់លោកទៅខាងអង្គភាពដឹកជញ្ជូន? តើលោកអាចរៀបរាប់អំពីការផ្លាស់ប្តូរតួនាទីរបស់លោកចេញពីកងពល ៥០២ នេះបានទេ?

[០៩:៤៣:៤៤]

**ឆ៖** ពេលដែលមកនៅព្រលានថ្មីហ្នឹង គឺគេផ្លាស់ប្តូរឲ្យទៅខាង ដូចថា ជូនគេទៅកាប់ឈើជូនគេបោសសម្អាតធ្វើព្រលានថ្មីហ្នឹង ដើមឈើ ដើមអីហ្នឹង។ អាហ្នឹងចេញពីកន្លែងនីរសារហើយហ្នឹងចេញពីហ្នឹងមកគេឲ្យដើរបោសសម្អាតតាម វាស់ដីវាស់អី មើលតាមនេះហើយ ហើយទៅកាប់ឈើកាប់អីហើយហ្នឹង អត់មាននៅកន្លែងក្រុមនីរសារហ្នឹងទៀតទេ។

**ស៖** នៅពេលលោកចាប់ផ្តើមធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង លោកមិនមានតួនាទីក្នុង

ការបញ្ជូននីរសារចេញពីកងមួយទៅកងមួយទេ។ លោកគ្រាន់តែក្លាយទៅជាអ្នកធ្វើការម្នាក់នៅព្រលានយន្តហោះកំពង់ឆ្នាំង។ ត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវ ខ្ញុំនៅឈប់ពីកន្លែងគេឲ្យនៅកន្លែងនីរសារហ្នឹងមក ខ្ញុំមកកាន់ឡាន ឡានដឹកដីអីចឹងទៅ ដល់ពេលនេះគេហៅទៅ មើលឡានទៅដឹកឈើអីចឹងទៅ វាអត់ទៀងទាត់ទេ គេប្រើតាមគេនឹកឃើញថាឲ្យយើងធ្លាប់ស្គាល់ព្រៃ ឬធ្លាប់ស្គាល់កន្លែង នេះទៅ គេហៅឲ្យជូនគេទៅត្រង់ហ្នឹងវិញទៅ វាប្រែប្រួលរហូតនៅកន្លែងហ្នឹង។

**ស៖** បាទ ខ្ញុំយល់ហើយ។ នៅពេលដែលលោកត្រូវបានចាត់តាំងឲ្យធ្វើការជាមួយក្រុមនេះ ហើយឈប់ធ្វើការនៅកងនីរសារ តើលោកឈប់ទាក់ទងជាមួយ ស៊ូ ម៉េត និង ល្វៃ ដោយផ្ទាល់ ឬក៏នៅតែបន្តទាក់ទង?

**ឆ៖** អាហ្នឹងអត់មានទៅជិតគាត់ទេ ទៅឆ្ងាយពីគាត់ហើយ នៅតែ មកជាប់ទៅប្រធានមន្ទីរវិញ មកទាក់ទង ដូចថាទៅបើកអង្ករបើកអីយកមកហូបហ្នឹង ទាក់ទងប្រធានមន្ទីរវិញ អត់មានបានជួបគាត់នេះទេ នៅដាច់ដោយឡែកហើយហ្នឹង ទៅកាប់ឈើកាប់អីហ្នឹង នៅដាច់ដោយឡែកហើយ។

[០៩:៤៦:២០]

**ស៖** បើខ្ញុំយល់មិនច្រឡំទេ លោកមិនបានមកធ្វើជានីរសារវិញទេ គឺលោកជាមនុស្សម្នាក់ដែលធ្វើការនៅព្រលានយន្តហោះ។ តើអីចឹងមែនទេ?

**ឆ៖** ពិតមែន នៅក្នុងព្រលានយន្តហោះហ្នឹង។

**ស៖** ហើយក្រុមមួយដែលលោកធ្វើការហ្នឹង គឺមានគ្នាប្រហែលជា ១០០ ទៅ ១២០ -- មានកងទ័ព ១០០ ទៅ ១២០ នាក់។ តើត្រឹមត្រូវ តើអីចឹងឬក៏អត់ទេ?

**ឆ៖** អាហ្នឹងមានអង្គភាពគេកាន់កាប់របស់គេ មានប្រធានគេ តែខ្ញុំហ្នឹងគ្រាន់តែដឹកនាំ ដូចថាជូនដំណើរគេទៅ ដូចថាទៅព្រៃ ទៅអីចឹង ទៅកន្លែងដូចថា ទៅឃុំក្រាំងស្គារ ស្រុកទឹកផុស អីចឹងទៅ កន្លែងណាដែលមានឈើអីចឹង ខ្ញុំជូនទៅដាក់ត្រង់ហ្នឹងទៅ ខ្ញុំឡប់មកវិញមក ដឹកឈើហ្នឹងមកវិញមក។ អត់មានបាននៅជាមួយគេជាថិតថេររៀងរាល់ថ្ងៃ គឺអត់ទេ។ មកដល់វិញទៅ គឺថាគេឲ្យទៅកន្លែងខ្សាច់អីចឹងទៅ វាមិនទៀងទាត់ទេ រឿងខ្ញុំគេប្រើគឺអត់ទៀងទាត់ទេ។

**ស៖** ខ្ញុំយល់ហើយគឺថាលោកមានភារកិច្ចខុសៗគ្នានៅពេលនោះ ប៉ុន្តែសំណួរខ្ញុំ តើក្រុមនេះមានកងទ័ពពី១០០ ទៅ ១២០នាក់ ឬក៏អត់ទេ ហើយថាតើលោកយល់អំពីរចនាសម្ព័ន្ធរបស់កងមួយនេះបាន

ទេ ដូចជាខាងផ្នែកកងអនុសេនាធំ ឬក៏ក្រុមអ្វីជាដើម?

**ឆ៖** ក្នុងៗកងហ្នឹង ដូចថាគេឲ្យខ្ញុំជូន ជូនកាលគេយកមួយកងអ៊ីចឹងទៅ ១០០នាក់អ៊ីចឹងទៅ ហើយកងមួយទៀតទៅ ៥០នាក់អ៊ីចឹងទៅ យកទៅដាក់ក្នុងព្រៃអ៊ីចឹងទៅ ឲ្យនៅកាប់ឈើហ្នឹង។ មានអង្គភាពទៅពីរកងអ៊ីចឹងទៅ ពីរកងហ្នឹង មួយកង៥០ មួយកង១០០ អ៊ីចឹងទៅ។ ឡាន៥០, ៦០ឡានអ៊ីចឹងទៅ យកទៅដាក់នៅនឹងព្រៃហ្នឹងទៅ។ ហើយដល់តែពេលនេះហ្នឹង ខ្ញុំត្រឡប់មកវិញមក អូសឈើត្រឡប់មកវិញ។ ទៅដល់ពេលបានឈើច្រើនអ៊ីចឹងទៅ គេប្រាប់ទៅបានទៅយកអ៊ីចឹងទៅ គេអស់អង្ករអស់អ៊ីចឹងទៅ បានខ្ញុំផ្ដល់អង្ករ ឬក៏ផ្ដល់ថ្នាំពេទ្យឲ្យគេអ៊ីចឹងទៅ។ នៅវាមិនបានយូរនឹងគេទេ ជួនណាដេកបានពីរយប់អីទៅ មួយយប់អីខ្ញុំត្រឡប់មកវិញហើយ។ ដូចអត់បាននៅជាមួយអង្គភាពគេទេ។

[០៩:៤៩:១៩]

**ស៖** លោកសាក្សី ខ្ញុំមិនសួរអ្វីដែលលោកកំពុងតែធ្វើនៅទីនោះទេ ខ្ញុំសួរអំពីរចនាសម្ព័ន្ធនៃការបញ្ជានៅក្នុងក្រុមនេះ ក្រុមដែលលោកធ្វើការ អ្នកណាជាមេផ្ទាល់របស់លោកនៅក្នុងក្រុមហ្នឹង? ហើយអ្នកណាជាមេរបស់ក្រុមហ្នឹងទាំងមូលទៀត? គឺលោកថា មានទាហានប្រហែលជាជាង១២៥នាក់ហ្នឹង គឺថាលោកអាចផ្ដល់ជារចនាសម្ព័ន្ធនៃការបញ្ជាបានទេ?

**ឆ៖** អាហ្នឹងប្រធានមន្ទីរ ប្រធានមន្ទីរគេបញ្ជាឲ្យទៅ ខ្ញុំដឹងតែប្រធានមន្ទីរ។ ប្រធានមន្ទីរគេប្រើទៅហ្នឹង។ គេប្រាប់ថា “នេះ! អង្គភាពនេះ អង្គភាពនេះត្រូវទៅជាមួយអ្នែង” ទៅអ៊ីចឹង គេប្រាប់តែប៉ុណ្ណឹង។ មិត្តឯងនាំកម្លាំងហ្នឹង ប៉ុណ្ណឹងទៅ។ ហ្នឹងប្រធានមន្ទីរគេប្រាប់។ គេប្រាប់ប៉ុណ្ណឹង។

**ស៖** ជាថ្មីម្ដងទៀត លោកសាក្សី គឺលោកធ្វើជាកងទ័ពប្រហែលជា៦ឆ្នាំ ម្ដងនោះគឺលោកធ្វើជានីរសារ ក្រោយមកក៏ទៅជាសមាជិកនៅក្នុងក្រុមមួយដែលធ្វើការនៅព្រលានយន្តហោះ។ ក្នុងឋានៈលោកជាកងទ័ព នៅពេលហ្នឹង គឺថាលោកដឹងថាអ្នកណាជាអ្នក ជាមេផ្ទាល់របស់លោក ហើយមេរបស់លោកហ្នឹងត្រូវរាយការណ៍ខាងណា។ ដូច្នេះ ខ្ញុំសួរអំពីរចនាសម្ព័ន្ធនៃការបញ្ជានៅក្នុងក្រុមរបស់លោក ថាតើលោកដឹង ឬក៏អត់ទេ?

**ឆ៖** មេធំ ខ្ញុំមិនដឹង ដឹងតែ តាម៉េត ហើយនិង តាល្វៃ ហើយនិងប្រធានមន្ទីរប៉ុណ្ណឹងឯង ដឹងប៉ុណ្ណឹង មេធំ។ ដែលគេបញ្ជាទៅណា ហើយនេះហ្នឹង មានតែបីនាក់ហ្នឹងឯង ដែលអាចដឹង។ ផុតពីហ្នឹងខ្ញុំអត់ដឹងថា គេទៅណាទៅណី គេបន្តទៅថ្នាក់លើឯណាទៀត ក៏ខ្ញុំអត់ដឹងដែរ។ អត់មានដឹងទេ។

[០៩:៥១:៤២]

**សះ** លោកសាក្សី លោកឆ្លើយមកដូចជាមិនត្រឹមត្រូវទេ គឺលោកនិយាយថា មេបញ្ជាការធំនៅទីនោះ គឺ ស៊ូ ម៉េត និង ល្វៃ គឺជាអ្នកដឹកនាំកម្លាំង ប្រាំ ទៅ៦000នាក់នេះ ហើយលោកគឺថាមានតួនាទីទាបបំផុតនៅក្នុងកងពលហ្នឹង។ នៅពេលដែលលោកធ្វើការហ្នឹង តើលោកទទួលខុសត្រូវនៅក្រោមអ្នកណាផ្ទាល់? អ្នកណាជាអ្នកដាក់ភារកិច្ចមកឲ្យលោកធ្វើ សូមឲ្យលោករៀបរាប់រចនាសម្ព័ន្ធទៅក្នុងក្រុមរបស់លោកហ្នឹង រៀបរាប់ពីរចនាសម្ព័ន្ធពីថ្នាក់ទាបបំផុត ដល់ថ្នាក់ខ្ពស់បំផុតក្នុងក្រុមរបស់លោក។

**ឆះ** ពីថ្នាក់ទាបទៅ មានខ្ញុំ -- វាអត់មានណានេះផង មានតែប្រធានមន្ទីរហ្នឹងប្រាប់។ ថ្នាក់ទាបដែលមកប្រាប់ខ្ញុំហ្នឹង វាមានប្រធានមន្ទីរ ប្រធានមន្ទីរហើយ ខ្ញុំចេញធ្វើហើយ គេប្រាប់ឲ្យទៅនេះទៅនោះហ្នឹង មានប្រធានមន្ទីរហ្នឹងឯង។ អត់មានពីណាទៀតមកប្រាប់ខ្ញុំផង មានតែប៉ុណ្ណឹង។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**សះ** សូមលោកផ្តល់ឈ្មោះមេបញ្ជានៅក្នុងក្រុងរបស់លោកនេះ គឺក្រុមដែលមានកងទ័ពប៉ុន្មានជា១២៥នាក់។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ មិនមែនជាការជំទាស់ទេ ប៉ុន្តែគ្រាន់តែសួរបញ្ជាក់អំពីភស្តុតាង។ សាក្សីនិយាយអំពីការនាំកម្លាំងទៅកាប់ព្រៃ។ តើមេធាវីកំពុងតែនិយាយអំពីក្រុមដែលសាក្សីគាត់នាំទៅកាប់ព្រៃនេះ ឬក៏កំពុងតែនិយាយទៅលើកងណាផ្សេងទៀត។ សំណួរសួរហាក់ដូចជាមិនច្បាស់លាស់ ដូច្នេះ សូមសួរឲ្យបានច្បាស់លាស់។

[០៩:៥៤:១១]

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំមានការមន្ទិលសង្ស័យគ្រប់ចំណុចទាំងអស់។ អ៊ីចឹងឯងបានខ្ញុំសួរបែបនេះ។ អ៊ីចឹង ខ្ញុំសូមសួរឲ្យចំៗតែម្តង។ សូមដកសំណួរនេះវិញ។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**សះ** នៅព្រលានយន្តហោះកងទ័ពនេះ តើព្រលានយន្តហោះនេះ ត្រូវបានគេគ្រប់គ្នាដឹងថា

ព្រលានយន្តហោះនេះកំពុងតែសាងសង់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរទេ?

**លោក ចាន់ ម៉ន៖**

**ឆ៖** ព្រលានហ្នឹង បើដឹង ដឹងតែទ័ព ទ័ព -- ដឹងតែទ័ពទេ បើប្រជាជន គ្មានអ្នកណានៅជិតផង អត់មានអ្នកណាដឹង ដឹងតែទ័ពនៅធ្វើការហ្នឹង គេដឹង។ ជំនាន់ហ្នឹង គ្មានអ្នកណាដឹង អ៊ូ! ធ្វើនេះធ្វើនោះអី គឺប្រជាជនគ្មានដឹងទេ មានតែកងទ័ពដែលនៅជិតៗហ្នឹងគេដឹង ដឹងថា ធ្វើព្រលានយន្តហោះ។

**ស៖** តើត្រឹមត្រូវដែរទេ បើខ្ញុំនិយាយថាជាប្រតិបត្តិការសាងសង់នៅក្នុងជួរកងទ័ពមួយលាក់ការណ៍សម្ងាត់បំផុតនៅក្នុងចំណោមកងពល៥០២ ហើយតើអ្នកនៅខាងក្រៅពីកងពលហ្នឹង តើគេដឹងទេ ដឹងថាមានការសាងសង់ព្រលានយន្តហោះហ្នឹងទេ?

**ឆ៖** ខ្ញុំមិនដឹងដែរ ព្រោះវាមកធ្វើការហ្នឹង ដឹងតែ៥០២ចុះមកធ្វើ គេមិនឲ្យដឹងអីផង។ ដឹងតែថាមកសាងសង់ព្រលានថ្មីនៅហ្នឹង គឺអត់មានអ្នកណានៅជិតខាងហ្នឹងទេ ដែលខ្ញុំមកមុនដំបូងក៏គ្មានអ្នកណានៅដែរ ស្ងាត់ឈឹងតែម្តង អត់មានទេ។

[០៩:៥៦:០៨]

**ស៖** លោកដឹងថាមាន -- ក្នុងមួយកងមានប៉ុន្មានក្រុមដែរ ជាពីកងពលធំ៥០២ហ្នឹង? លោកបានឆ្លើយថា លោកជាសមាជិកនៃក្រុមមួយ ឬក៏កងមួយ។ តើនៅក្នុងកងពលធំ៥០២ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គេបែងចែកទៅជាប៉ុន្មានកងដែរ?

**ឆ៖** ខ្ញុំមិនដឹងថាគេបែងចែកប៉ុន្មានៗទេ គ្រាន់តែដឹងថា អ្នកខ្លះហ្នឹង ក្រុមខ្លះ កងខ្លះគេទៅនៅខាងវ៉ៃថ្ម កងខ្លះទៅនៅខាងភ្លើង កងខ្លះនៅខាងសាងសង់បង្គោលភ្លើង អ្នកខ្លះគេអូសសាងសង់ខាងខ្សែៗភ្លើង ក្រុមខ្លះទៀត គេនៅខាងដាក់តទឹកពីទន្លេ។ អាហ្នឹងខ្ញុំដឹងតែអ៊ីចឹង ដឹងថា គេបែងចែកតាមក្រុមអ៊ីចឹង ហើយខាងកាប់ឈើ ខាងអារឈើ ខាងជីកដី។ គេបែងចែកទាំងអស់ តែខ្ញុំដឹងតែ ដូចវាស្រពេចស្រពិលដឹងតែថា ដឹងជាប៉ុន្មានកង អង្គភាពហ្នឹងវាបែងចែកតាំងពីជីកថ្ម ជីកដី ជីកខ្សាច់។ អាហ្នឹងទាំងអស់ទាំងស្រីទាំងប្រុស វាបើកឡានទាំងអស់តែគ្នា ដឹងអ្នកណាជាអ្នកណើ អង្គភាពវាច្រើនអង្គភាពណាអង្គភាពណើទេ គេបែងចែកអ៊ីចឹងអស់ហើយ។

**ស៖** ខ្ញុំយល់ហើយ។ លោកក៏បានឆ្លើយពីម្សិលមិញរួចមកហើយ តើខាងក្រុមបំបែកថ្ម ឬក្រុមតភ្លើង តើជាសមាជិកនៃកងពលធំ៥០២ទេ? តើលោកស្គាល់កងដែលធ្វើការផ្សេងៗដែលធ្វើការដូចលោករៀបរាប់នេះ តើគេមកពីវរសេនាធំ៥១ ឬក៏មកពីវរសេនាធំ៥២?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ។ វាភ្លេចមិនដឹងជាកងណាៗលេខប៉ុន្មាន ទៅធ្វើអីៗ ខ្ញុំភ្លេចអស់ អត់ចងចាំទេ វាយូរឆ្នាំហើយ ហើយវាខ្ញុំវាមានវិបត្តិក្នុងខ្លួនខ្ញុំទៅវាអត់ចងចាំ។

[០៩:៥៨:៥១]

**សៈ** លោកសាក្សី លោកឆ្លើយពីខាងដើមថា លោកធ្លាប់ធ្វើជានីរសារ ហើយភារកិច្ចរបស់លោក គឺថាត្រូវទៅធ្វើការនាំសារពីក្រុមមួយទៅក្រុមមួយមុនឆ្នាំ៧៥ ក្រោយមកគេបញ្ជូនមកធ្វើការនៅព្រលានយន្តហោះពោធិ៍ចិនតុង។ ពិតណាស់ថា លោកប្រាកដជាស្គាល់សមាជិកទាំងឡាយនៅក្នុងកងពលធំ៥០២ នៅពេលដែលលោកធ្វើការនៅកំពង់ឆ្នាំង។ តើលោកស្គាល់ ឬក៏មិនស្គាល់ទេ?

**ឆ៖** ដល់ឥឡូវវាភ្លេចឈ្មោះអស់ ហើយខ្លះក៏ស្លាប់ ខ្លះក៏អីទៅ ខ្ញុំភ្លេចអស់។ វាមាន -- វាមិនសូវមានអ្នករស់ផង ឥឡូវវាអត់ម៉ាសេរីខ្ញុំហ្នឹង វាគិតទៅនៅសល់តែពីរនាក់ទេដែលអាចឃើញមុខគ្នាមួយឆ្នាំពីរឆ្នាំហ្នឹង រួចពីនោះអត់។

**សៈ** ខ្ញុំគិតថា ខ្ញុំខ្លាចក្រែងមិនយល់ចម្លើយរបស់លោក។ លោកជាទាហានម្នាក់ កាលនោះទទួលខុសត្រូវក្នុងការវាយរំដោះយកទីក្រុងភ្នំពេញដែរ។ លោកនៅក្នុងសមរភូមិ ដូច្នេះលោកប្រាកដជាស្គាល់អ្នកណាម្នាក់នៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងក្នុងកងពល៥០២ ហើយ។ តើលោកស្គាល់ ឬក៏មិនស្គាល់?

**ឆ៖** អាហ្នឹងខ្ញុំប្រាប់រួចហើយ។ ខ្ញុំចាំតែ បងម៉េត និង បងល្វៃ ចាំ។ ខ្ញុំដឹងតែពីរបីនាក់ហ្នឹងឯង និងប្រធានមន្ទីរហ្នឹង។ ផុតហ្នឹងអ្នកធំពីហ្នឹងទៀត គឺខ្ញុំអត់មានដឹងអីទេ។ ដឹងតែពីរនាក់ហ្នឹង។

[១០:០១:០២]

**សៈ** ដូច្នេះ មានតែកងពល -- តែមេកងពល និងអនុកងពលទេដែលលោកស្គាល់ ក្រៅពីហ្នឹងលោកមិនស្គាល់ទេ។ តើលោកចាំកម្លាំងមកពីកងពល -- កងពលធំ៣១០ទេ?

**ឆ៖** ខ្ញុំស្តាប់អត់បានត្រង់ហ្នឹង? សុំម្តងទៀត។

**សៈ** ខ្ញុំនឹងរៀបសំណួរឡើងវិញ។ តើលោកដឹងថាមានកងទ័ពណាមួយមកពីកងពលធំលេខ៣១០ ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងដែរទេ?

**ឆ៖** អ៊ូ! អាហ្នឹងខ្ញុំដឹងថា ពួក៣១០ ហ្នឹងខាងរ៉ាដាទេ អត់មានមកធ្វើនៅព្រលានហ្នឹងទេ គេខាងរ៉ាដា ខាងឡានចាប់រ៉ាដា ឡានអីហ្នឹង។ នៅក្នុងព្រលានហ្នឹងដែរ តែគេខាងរ៉ាដា។ អាហ្នឹងខ្ញុំដឹងថា ពួកហ្នឹងគេមកខាងរ៉ាដា។

**ស៖** ប៉ុន្តែ តើលោកមានចាំអ្នកណាម្នាក់មកពីកងពលធំ៣១០។ តើលោកនៅនឹកឃើញឈ្មោះកូនទាហានណាមួយ ឬមេបញ្ជាការណាមួយមកពីកងពល៣១០ ដែលធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងនោះដែរទេ?

**ឆ៖** អត់ចាំ ខ្ញុំអត់ចាំ។

**ស៖** ចុះទាហានមកពីកងពលធំ៤៥០ លោកដឹងថា កងពលនេះមកពីណាដែរទេ? ហើយតើកងពលនេះធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងដែរទេ?

[១០:០២:៥៨]

**ឆ៖** កងពលហ្នឹង គេយកពីភ្នំពេញទៅដែរ ហើយយកទៅបញ្ចូលនៅ-- ធ្វើការនៅកំពង់ឆ្នាំងហ្នឹងខាង-- គេបែងចែកដីក ទៅខាងខ្សាច់ខាងអី ដីកខ្សាច់ដីកអី ទៅធ្វើនេះ ខ្ញុំដឹងបានតែប៉ុណ្ណឹង មិនដឹងកងណា កងអីទៀត ខ្ញុំអត់ដឹ។

**ស៖** តាមសក្ខីកម្មរបស់លោកគឺ កងពលធំ៤៥០ គឺលោកឆ្លើយថា មកពីភ្នំពេញ អ៊ីចឹងមែនទេ?

**ឆ៖** គេទៅពីភ្នំពេញទាំងអស់ ទៅពីភ្នំពេញទាំងអស់ អត់មាននៅនេះទេ។

**ស៖** តើលោកច្បាស់ទេថាកងពលធំ៤៥០ មិនមកពីខាងឧត្តរទេអី? កងពល -- ចុះកងពល៣១០ អ៊ីចឹងកងពលទាំងពីរហ្នឹងមកពីណា លោកដឹងច្បាស់លាស់ទេ?

**ឆ៖** គេយកទៅពីហ្នឹងទៅ យកពីភ្នំពេញទៅយកទៅដាក់ហ្នឹង ដឹងតែកងពលហ្នឹងយកមកពីបូព៌ាមិនដឹង យកពីណាមិនដឹង វាច្រើនណា ថ្ងៃក្រោយមកដែលនេះហ្នឹង វាច្រើនយកទៅដាក់ហ្នឹង ខ្ញុំមិនចាំ មិនដឹងកងពលណាកាលហ្នឹង។ ខ្ញុំមាននាទីមួយដូចថា នាំផ្លូវគេធ្វើការហ្នឹងឯង អត់មានដឹងថាកងពលហ្នឹងលេខប៉ុន្មានៗ យកទៅដាក់ហ្នឹង។ ដឹងតែគេឱ្យហៅកាលហ្នឹង "កងនេះ ត្រូវយកកងនេះទៅដាក់កន្លែងនេះ, ហ៎! កងនោះ យកទៅធ្វើកន្លែងនោះ"។ ខ្ញុំដឹង នាទីខ្ញុំដឹងតែប៉ុណ្ណឹងទេ។

[១០:០៥:០១]

**ស៖** លោកប្រធាន ឯកសារ E3/849, ERN អង់គ្លេស 00183956 គឺមានតែ១ទំព័រទេ អ៊ីចឹងងាយស្រួលក្នុងការអានឯកសារនេះទេ។ ឯកសារនេះបញ្ជាក់ថា ១០២៧ – កងទ័ព ១០២៧នាក់ គឺមកពីកងពល៤៥០ និងកងពល៣១០ ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងដែរ។ លោកសាក្សីពីម្សិលមិញលោកឆ្លើយអំពីកងទ័ពមកពីភូមិភាគបូព៌ា។ តើលោកដឹងលេខកងពលធំ ដែលចំណុះឱ្យភូមិភាគបូព៌ាមកទីនោះហ្នឹង គឺលោកដឹងៗលេខកងពលធំហ្នឹងទេ?

**លោក ចាន់ ម៉ន៖**

**ឆ៖** អត់ដឹង១ មក គេមកដាក់ហ្នឹងហើយ មិនដឹងកងពលលេខប៉ុន្មាន១ ខ្ញុំអត់ដឹង។

**ស៖** កងទ័ពដែលមកពីភូមិភាគបូព៌ាដែលលោកបានឆ្លើយថា លោកបានឃើញនោះ តើលោកនឹកមើលនៅចាំខែ ឬក៏ឆ្នាំដែលកងទ័ពមកពីបូព៌ាហ្នឹងមកធ្វើការលើកដំបូងនៅព្រលានយន្តហោះកំពង់ឆ្នាំងបានទេ? លោកនឹកមើល៍អាចចាំថ្ងៃខែឆ្នាំពិតប្រាកដបានទេ?

**ឆ៖** ចុងឆ្នាំ៧៦ តែមិនដឹងខែប៉ុន្មាន ខ្ញុំអត់ចាំ។ រក -- ក្នុងយកមកអង្គាល់ហ្នឹងមានរឿងរ៉ាវនៅនោះ ដល់រួចមកគេដឹកកម្លាំងហ្នឹងមកដាក់កន្លែងហ្នឹងទៅ ខ្ញុំអត់ចាំទេ ដឹងថ្ងៃទីប៉ុន្មាន តែនៅឆ្នាំ៧៦ហ្នឹងខ្ញុំអត់។

**ស៖** ខ្ញុំសូមឲ្យលោកគិតឲ្យបានហ្មត់ចត់បន្តិច តើឆ្នាំ១៩៧៦ ឬក៏នៅចុងបញ្ចប់នៃឆ្នាំ១៩៧៧ ឬក៏ឆ្នាំ១៩៧៨? តើលោកប្រាកដថាជាឆ្នាំ១៩៧៦ មែន ឬក៏អត់ទេ?

[១០:០៧:៤៤]

**ឆ៖** ៧៦ហ្នឹងវាចុងឆ្នាំ ដើមឆ្នាំ៧៧ ក៏ខ្ញុំភ្លេចអស់ហើយ ព្រោះខ្ញុំមិនចាំបានទេ។ ខ្ញុំវាកើតតាំងពីហ្នឹងមកដល់សម័យយើងនេះ វា ខ្ញុំមានវិបត្តិក្នុងខ្លួនខ្ញុំ វាភ្លេចចាំមួយចំនួន ដែលត្រូវមីន ត្រូវអីទៅ វាខូចខួរក្បាល វាអត់ចាំ ភ្លេច។ ដឹងតែថ្ងៃ ខែ ឆ្នាំ ចុងឆ្នាំ ឬដើមឆ្នាំ៧៧ ឬចុងឆ្នាំទេ ខ្ញុំវាភ្លេចទៅណា៎។ ខ្ញុំចាំមិនអស់។

**ស៖** ខ្ញុំសូមសួរសំណួរតាមរបៀបផ្សេងវិញ។ តើមុនពេលវៀតណាមលុកលុយចូលកម្ពុជាផ្តួលរលំកម្ពុជាប្រជាធិបតេយ្យ តើកងទ័ពមកពីភូមិភាគបូព៌ាហ្នឹងមកធ្វើការនៅកំពង់ឆ្នាំងហ្នឹងបានប៉ុន្មានខែដែរ?

**ឆ៖** មកយូរដែរ ចង់ប្រាំមួយប្រាំពីរខែដែរហ្នឹង បើគិតទៅមកបានយូរ។ មកកាប់ឈើ គ្រាន់តែកាប់ឈើ ខ្ញុំនាំទៅកាប់ឈើ វា៣ខែ ៤ខែហើយ។ ដល់ក្រោយមកទៀតទៅ ខ្ញុំវាមាននេះទៅ វាបែកគ្នា គឺថា តាំងមកពីហ្នឹង ខ្ញុំមានរឿង មានរ៉ាវទៅ វាបែកគ្នាតាំងពីហ្នឹង ភ្លេចទៅ មិនដឹងប៉ុន្មានខែ១ ខ្ញុំអត់ចាំ។ ព្រោះចាប់ពីហ្នឹងមក ខ្ញុំមានរឿងហើយ។

**ស៖** ខ្ញុំសូមទៅនិយាយកងពលផ្ទាល់របស់លោកវិញម្តង គឺកងពលធំ៥០២។ ហើយក៏អាចហៅថាជាកងពលខាងទ័ពអាកាស។ តើត្រឹមត្រូវទេដែលថាការងារនៅព្រលានយន្តហោះកំពង់ឆ្នាំង ធ្វើឡើងដោយកងពលធំ៥០២ ដែលជាភារកិច្ចជាធម្មតារបស់កងពលនេះតែម្តង? កងពលធំ៥០២ គឺថាត្រូវតែ

ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង ដោយសារតែកងពលនេះជាកងពលចំណុះឲ្យខាងកងពលទ័ពអាកាស តើអ៊ីចឹងមែនទេ?

**ឆ៖** មែន ព្រោះកងពល៥០២ គឺកង -- គេហៅថាកងទ័ពអាកាស។ កងសម្រាប់ធ្វើនៅទ័ពអាកាសហ្នឹង គេយកមកធ្វើនៅហ្នឹងគឺគេធ្វើព្រលានធ្វើអី គឺដឹងថា៥០២ហ្នឹង នៅទ័ពអាកាស។ ខ្ញុំដឹងថាគេយកពួកហ្នឹងឯង យកមកទាំងអស់។ គេបែងចែកគ្នា អាខ្លះយកហ្នឹងមក អាខ្លះនៅពោចិនតុង។ ខ្ញុំដឹងប៉ុន្នាន។ ហើយអ្នកខ្លះ គេនៅរៀនទៅ។

[១០:១១:១៥]

**ស៖** បន្ទាប់ពីខែមេសា ១៩៧៥ តើលោកនៅចាំថាគេបាននិយាយអ្វីខ្លះដែលតាមរយៈវិទ្យុទាក់ទង ឬនៅក្នុងកិច្ចប្រជុំណាមួយ? គឺតើលោកនៅចាំថា គេនិយាយភារកិច្ចទាំងពីរ ប្រគល់ឲ្យកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា ជាពិសេសកងពលប្រាំ -- កងពលធំ៥០២នេះ ភារកិច្ចចម្បងពីរនេះ លោកនៅចាំភារកិច្ចស្អីដែរ?

**ឆ៖** ភារកិច្ចរបស់៥០២ នៅទ័ពអាកាសហ្នឹងគ្រាន់តែការពារៗខាង ដូចថាអ្នកដែលគេចេះដែលហាត់រៀនបច្ចេកទេសយន្តហោះស្អីៗ ហើយនៅខាងថ្មើរជើងដែលចំណុះឲ្យកងទ័ពអាកាសហ្នឹង គឺការពារតាមព្រំដែនតាមអីហ្នឹង។ គឺគ្រាន់តែបង្រៀងយើងថាយន្តហោះហ្នឹង សម្រាប់តែការពារតាមព្រំដែនតាមអីហ្នឹង។ គេប្រាប់អ៊ីចឹង។ អត់មាននិយាយអីផង អាហ្នឹងខ្ញុំដឹង។ ចុះខ្ញុំដើរ វាមិនបានដឹងអី។ គេប្រជុំអី គេរៀនអីក៏ខ្ញុំមិនសូវបានរៀនអីដែរ ខ្ញុំរវល់តែដើរទៅ ប្រើទៅនេះទៅនោះតាមខេត្តតាមអីបាទ។

[១០:១២:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជម្រះប្រកាសសម្រាកពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្រប់សម្រួលផ្តលកន្លែងសម្រាក់នៅកន្លែងបន្ទប់រងចាំ សម្រាប់សាក្សី និងអ្នកជំនាញ ដល់សក្សីរូបនេះនៅអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

អូ៎! ផ្អាកបន្តិចលោក វ៉ិចទ័រ កូប៉េ! ផ្អាកបន្តិចសិន!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ធ្វើការកត់សម្គាល់មួយ កាលព្រឹក កាលពីព្រឹកមិញនោះលោកមេធាវី កូប៉េ បានយោងទៅលើឯកសារ E3/849 ដែលនៅក្នុងនោះមានតួរលេខមួយចំនួនពាក់ព័ន្ធទៅនឹងចំនួននៃកម្លាំងក្នុងកងពលផ្សេងៗ។ ខ្ញុំពិនិត្យមើលឯកសារ បារាំង និងអង់គ្លេស នៃឯកសារនេះហើយឯកសារគឺដូចជាមិនពេញលេញទេ។ ខ្ញុំសូមបញ្ជាក់ថា អង្គជំនុំជម្រះនឹងផ្ញើអ៊ីម៉ែលទៅអង្គភាពបកប្រែភាសា ដើម្បីឲ្យពិនិត្យមើលឡើងវិញថាតើការបកប្រែត្រឹមត្រូវហ្នឹងមួយណា ដោយសារថាភាសាដើមនោះគឺជាភាសាខ្មែរទេ។

ហើយខ្ញុំសូមបញ្ជាក់ផងដែរថា ផ្នែកដែលខ្វះនោះ គឺចំនួនទាហាននៅក្នុងក្រុម នៅក្នុងកងពល ៤៥០ ដែលមានវត្តមាននៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។

[១០:៣៣:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ លោកចៅក្រមឡាវែន ដែលបានបញ្ជាក់បំភ្លឺទៅលើចំណុចនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីមុនពេលដែលឈប់សម្រាកយើងបាន -- ខ្ញុំបានសួរលោកអំពីភារកិច្ចទូទៅរបស់កងទ័ពបដិវត្តន៍កម្ពុជាក្រោយថ្ងៃរំដោះ។ ឥឡូវនេះ ខ្ញុំសូមជួយបន្ថែមបន្តិច ថាតើលោកចាំដែរឬទេថាកងទ័ពបដិវត្តន៍កម្ពុជាមានគោលដៅពីរ ទី១ គឺការពារប្រទេស, ទី២ កសាងប្រទេសក្រោយពីសង្គ្រាម។ តើលោកចាំអំពីចំណុចនេះទេ?

**លោក ចាន់ ម៉ន៖**

**ឆ៖** អាហ្នឹងកងទ័ពមានតែពីរមុខហ្នឹងឯង អត់មានអីទេ កងទ័ព៥០២ ហ្នឹងសម្រាប់តែការពារ ដែលខ្ញុំបានដឹងហ្នឹង ហើយមកកសាងនៅព្រលានថ្មីហ្នឹងឯង។

**ស៖** តើខ្ញុំអាចនិយាយបានទេថា ទាហានមកពីកងពល៥០២ នៅពេលដែលធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង គឺពួកគេបំពេញការងារក្នុងនាមជាកងទ័ពទូទៅ គឺដើម្បីការពារនិងកសាងប្រទេស។ តើខ្ញុំអាចនិយាយអ៊ីចឹងបានទេ?

**ឆ៖** ខ្ញុំស្ដាប់អត់បានកន្លែងហ្នឹង។

**ស៖** ខ្ញុំគិតថា ប្រហែលជាសំណួរពិបាក។ ដូច្នេះគឺថាយើងកំពុងតែនិយាយអំពីគោលដៅនៃការកងទ័ពបដិវត្តន៍កម្ពុជា ដែលកងពល៥០២ គឺជាផ្នែកនៃកងទ័ពនេះដែរ ព្រោះថាកងទ័ពបដិវត្តន៍កម្ពុជាមានគោលដៅកសាងនិងការពារប្រទេស។ ដូច្នេះការកសាងព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គឺជាផ្នែកមួយនៃគោលដៅនេះផងដែរ គឺដើម្បី គឺថាការកសាងព្រលានយន្តហោះកំពង់ឆ្នាំង គឺដើម្បីការពារជាតិ ហើយនិងកសាងជាតិ។ ដូច្នេះ ខ្ញុំចង់និយាយថា កងទ័ពនៅក្នុងកងពល៥០២ ដែលគាត់ធ្វើការងារនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងគឺគាត់គ្រាន់តែបំពេញការងារក្នុងនាងជាកងទ័ពធម្មតាប៉ុណ្ណោះ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

[១០:៣៦:៤៥]

**ឆ៖** កងទ័ព៥០២ហ្នឹង គឺមានពីរផ្នែកដែលសម្រាប់ធ្វើការហ្នឹង។ វាមួយផ្នែកគេខាងការពារ។ មួយផ្នែកទៀតខាងកសាង។ អាខាងការពារហ្នឹង គឺខាងទ័ពអាកាសហ្នឹងឯង គេការពារព្រំដែន ការពារនៅប្រទេសហ្នឹងឯង។ ហើយមួយផ្នែកហ្នឹង គេដូចពួកខ្ញុំពួកអីហ្នឹង ដែលគេឲ្យទៅកសាងហ្នឹង ក៏ធ្វើទៅគឺកសាងព្រលាន កសាងធ្វើព្រលានថ្មីហ្នឹង គឺវាពាក់កណ្ដាល។ ពាក់កណ្ដាលទ័ព ពាក់កណ្ដាលមកធ្វើហ្នឹងឯង វាច្រើនគ្នាពេក មិនដឹងឯណាឯណីទេ មិនចាំអស់ទេ ព្រោះវាអ្នកកសាងផ្សេង អ្នកការពារផ្សេងអ៊ីចឹងទៅ។

**ស៖** ខ្ញុំយល់ ប៉ុន្តែតើខ្ញុំអាចនិយាយបានទេថា កងទ័ពមកពីកងពល៥០២ នៅពេលដែលពួកគាត់ធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គឺពួកគាត់បំពេញភារកិច្ច។ ក្នុងនាមគាត់ជាកងទ័ព គឺថាគាត់បំពេញការងារទៅតាមភារកិច្ចដែលមានចែងក្នុងធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បំពេញការងារក្នុងទ័ពហ្នឹង ដូចលោកនិយាយអ៊ីចឹងឯង គេកងទ័ពហ្នឹងការពារនៅកន្លែងហ្នឹងឯង អត់មាន ដូចការងារកសាង និងការពារ។

**ស៖** តើលោកដឹងទេ ថាមានកងទ័ពមកពី៥០២ណាខ្លះ ដែលត្រូវបានគេចាត់តាំងឲ្យទៅធ្វើការហ្នឹង គឺបានន័យថា គេចាត់តាំងមិនមែនដោយសារគាត់ទៅធ្វើការធម្មតាទេ ប៉ុន្តែគេបញ្ជូនគាត់ទៅហ្នឹងក្នុងលក្ខណៈជាការដាក់ទណ្ឌកម្ម ឬក៏ដើម្បីទៅអប់រំរៀនសូត្រលត់ដំហ្នឹង។ តើលោកដឹងទេថាមានទាហានបែបនេះ?

**ឆ៖** ខ្ញុំមិនដឹង ដូចមកហ្នឹង គឺបើដូចខ្ញុំអីហ្នឹង គឺទៅហ្នឹង វាមិនដឹងថាខ្លួនឯងជា គេយកមកលត់ដំលត់អី គឺអត់ដឹងទេ មកធ្វើការហ្នឹងគេប្រើទូទៅអ៊ីចឹង។ មិនដឹងថាគេលត់ដំម៉េចទេ ប៉ុន្តែដល់ពេលមានរឿងរ៉ាវ បានដឹងថា ឈ្មោះខ្ញុំហ្នឹង មាននិន្នាការខ្មាំង ស្អីៗអ៊ីចឹង គេប្រាប់តាមដំណើរអ៊ីចឹង។ បងប្អូនអី ធ្វើស្អីៗអ៊ីចឹង។ ក្រោយមកបានដឹង ដឹងតាមរយៈគេឲ្យធ្វើប្រវត្តិរូបហ្នឹង។

[១០:៤០:២០]

**ស៖** យើងនឹងនិយាយអំពីបញ្ហានេះនៅពេលក្រោយ ប៉ុន្តែខ្ញុំចង់និយាយអំពីកងទ័ពនៅក្នុងកងពល ៥០២។ ថាតើពួកគាត់ធ្វើការដោយធម្មតា ឬក៏ដោយការទទួលទារុណកម្ម។ ឥឡូវនេះយើងបន្តទៅមុខទៀត។ ដូច្នេះខ្ញុំចង់ដឹងថាកងទ័ពនៅក្នុងកងពល៣១០ ឬក៏កងពល៤៥០ហ្នឹង តើពួកគេធ្វើការក្នុងលក្ខណៈជាការកសាងការពារជាតិ ឬមួយក៏ពួកគាត់ទៅធ្វើការហ្នឹងដោយសារតែវាជាការដាក់ទណ្ឌកម្មចំពោះពួកគាត់ទេ?

**ឆ៖** ការងារហ្នឹងអង្កាល់ហ្នឹង វាធម្មតា មិនដឹងថាអីនេះវាមក ម៉ោងចាប់ផ្តើមធ្វើការម៉ោងប្រាំមួយ ម៉ោងប្រាំពីរទៅដល់កន្លែងធ្វើការ។ ម៉ោងមួយដណ្តប់កន្លះហ្នឹង ម៉ោងដប់ -- មួយដណ្តប់ហ្នឹងជួបជុំគ្នាម៉ោងដប់មួយកន្លះ ដល់កន្លែងបាយ។ មិនដឹងថាគេលត់ដំ ឬមិនលត់ដំ គឺអត់ដឹងទេ ដឹងទេម៉ោងធ្វើការទៅធ្វើការ ម៉ោងសម្រាកហូបបាយក៏ហូបបាយទៅ ងូតទឹក ងូតអ៊ីចឹងទៅ។ អត់មានដឹងថាគេលត់ដំអី អត់ដឹង។

**ស៖** ចុះកងទ័ពមកពីបូព៌ាវិញ គឺកងទ័ពដែលលោកនិយាយ។ ថាតើពួកគាត់មកធ្វើការហ្នឹងក្នុងលក្ខណៈជាភារកិច្ចទាហានទូទៅក្នុងការកសាងការពារជាតិ ឬមួយក៏គេយកគាត់ដើម្បីអប់រំរៀនសូត្រលត់ដំនោះទេ តើលោកដឹងអំពីចំណុចនេះទេ?

[១០:៤២:២២]

**ឆ៖** ទ័ពមកពីបូព៌ា គេមកដល់ភ្លាម ខ្ញុំអត់ដឹងទេ។ ដល់តែពេលគេបែងចែកកម្លាំងដោយឲ្យយកទៅកាប់ឈើហ្នឹង គ្រាន់តែប្រាប់ខ្ញុំថា៖ “អូ៎! នាំកម្លាំងអង្គភាពមកបូព៌ាហ្នឹងទៅកាប់ឈើ”។ ដល់ទៅកាប់ឈើហ្នឹងក៏ខ្ញុំជូនទៅកាប់ហ្នឹង ក៏គេមិនប្រើអី ដូចថាលត់ដំអីគាត់នៅក្នុងព្រៃក្នុងអី គឺមិនឃើញទេ មិនឃើញលត់ដំទេ ទៅតាមក្រុមទៅ កាប់ទៅមួយថ្ងៃបាន។ គ្រាន់តែបែងចែកថាមួយថ្ងៃយក ធ្វើម៉េចឲ្យបានដឹក បានប្រាំឡានអីចឹងទៅ មួយថ្ងៃ មួយក្រុមឲ្យបាន១០ដើម ឬ២០ដើម អាហ្នឹងមាន។ មានដាក់កម្រិតឲ្យថា ឥឡូវក្រុមហ្នឹងធ្វើម៉េចឲ្យបាន២០ដើម មួយថ្ងៃ ឬ២០កំណាត់។ មានដាក់កំណត់ឲ្យអីចឹង។ តែបើគាត់មកពីណោះមក គេដឹងថាមកដល់ណោះ ហើយវាមានរឿង មានរ៉ាវអីចឹង ដូចតែលត់ដំដែរ យកទៅក្នុងព្រៃ មានឲ្យនៅនេះណា យកគ្នាទៅដាក់ក្នុងព្រៃកាប់ឈើ មានទៅស្ទី មានតែអង្រឹង មានតែអីហ្នឹង មូសខាំអីចឹងទៅ ហើយគ្រុនចាញ់ក៏ច្រើនដែរ យកមកគ្នាមានដែរនៅនេះណា នៅតែក្នុងព្រៃ។ ដូចតែគ្នាទាំងអស់គ្នាហ្នឹង តែម៉ោងប្រាំមួយ ម៉ោងប្រាំពីរហ្នឹង ចេញទៅរៀងខ្លួន ទាញប្រដាប់ប្រដាកាប់ឈើ កាប់ព្រៃដូចតែគ្នាអីចឹង។

**ស៖** ដូច្នេះកងទ័ពបូព៌ា ដែលលោកបាននិយាយនោះ គឺគាត់មានស្ថានភាពការងារដូចគ្នា ហើយគ្មានអ្នកណាគេបង្ខំពួកគាត់ឲ្យធ្វើការទេ។ អីចឹងលោកចង់និយាយថា ពួកកងទ័ពបូព៌ាហ្នឹងគឺបំពេញការងារដូចពួកកងទ័ពមកពីកងពល៥០២អីចឹងដែរ តើលោកចង់និយាយអីចឹងមែនទេ?

[១០:៤៥:២៩]

**ឆ៖** ខ្ញុំដឹងតែពេលអ្នកដែលទៅជាមួយខ្ញុំទេ ដែលអ្នកនៅក្រោយតើ ដូចនៅតាមម៉ាស៊ីអារឈើ ម៉ាស៊ីនអីដែលនៅក្នុងព្រលានថ្មី ខ្ញុំអត់ដឹងទេ មិនដឹងគេលត់ដំគាត់យ៉ាងម៉េច អីយ៉ាងម៉េច ព្រោះកន្លែងហ្នឹងសុទ្ធតែឈើ សុទ្ធតែអីចឹង ឈើអី អូសអីចឹង។ បើថាទៅក្នុងព្រៃនោះ វាអត់មានអូសមានអូសអីទេ គ្រាន់តែកាប់ហើយហ្នឹង ឡានទាញដាក់ ឡានស្ទូចដាក់ បើថានៅក្រៅ ខ្ញុំអត់ដឹងទេ មិនដឹងគេលត់ដំអីម៉េច ខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំសាកសួរលោកបន្តិចទៀត លោកសាក្សី។ កងទ័ពមកពីកងពលរបស់លោក ប្រសិនបើកង -- ថាតើកងទ័ពរបស់កងពលលោកហ្នឹង គេតែងតែភ្ជង់កាំភ្លើងទៅកងទ័ពបូព៌ាឲ្យធ្វើការ ឬក៏ពួកគាត់ងើបមកធ្វើការដូចគ្នាធម្មតា គ្មានការភ្ជង់កាំភ្លើង គ្មានការបង្ខំ?

**ឆ៖** ដូចអត់មាន អត់មានភ្ជង់។ ហ្នឹងដែលនៅកន្លែងខ្ញុំទេណា អត់មានទេ ទៅ -- ដែលខ្ញុំឃើញអត់មាន កន្លែងខ្ញុំអត់មាន បើកន្លែងគេខ្ញុំអត់ដឹង ព្រោះវានៅខុសគ្នា ផ្នែកខុសគ្នា ខ្ញុំអត់ដឹង។ បើថា ទៅ

ព្រៃងណោះ គ្មានអ្នកណាភ្លង់អ្នកណាទេ គឺគ្រាន់តែនិយាយគ្នា ខំធ្វើការឲ្យបានលឿនឲ្យគេហ្នឹងឯង។ ហើយម្នាក់ៗខំតែលះបង់ធ្វើម៉េចខំយកចិត្តទុកដាក់ធ្វើការខ្លាចតែវាមានរឿងមានរ៉ាវស្លាប់ រស់ហ្នឹង វាធម្មតាដែលទៅណាក៏មិនផុតពីងាប់ហ្នឹង គ្រាន់តែអាហ្នឹងវាអត់មានគិតអីទៀត គិតតែធ្វើការឲ្យគេ។

[១០:៤៦:៣៥]

**ស៖** ខ្ញុំនឹងបន្តទៅប្រធានបទថ្មីមួយទៀត។ កាលពីម្សិលមិញលោកសាក្សីបាននិយាយអំពីមន្ទីរមួយ គឺមន្ទីរដឹកជញ្ជូនដែលមានចម្ងាយប្រហែលជា៣គីឡូម៉ែត្រពីព្រលានយន្តហោះ ហើយមានម្តងនោះលោកនៅពេលយប់ ហើយក្រោយមកទៀត លោកឮគេ -- ឮសំឡេងស្រែកយំ។ តើលោកអាចបញ្ជាក់ឲ្យបានលម្អិតបន្តិចបានទេ ថាតើឡានដែលលោកនិយាយកាលពីម្សិលមិញ តើឡានដែលគេដឹកហ្នឹងគេដឹកមកពីទិស ទីតាំងណា ឬក៏មកពីទិសដៅណាដែរ លោកអាចបញ្ជាក់ឲ្យលម្អិតបានដែរទេ?

**ឆ៖** ឡានវាយប់មើលមិនស្គាល់ឡានទេ ប៉ុន្តែឡានហ្នឹងឡានទ័ពហ្នឹងដែរ តែដឹកមកពីខាងភ្នំមកវិញ មកពីដូចថាក្បាលព្រលានមកវិញ ដូចថាដឹកមកវាផ្លូវហ្នឹងវាកាត់មុខកន្លែងខ្ញុំហ្នឹងឯង ព្រោះថ្ងៃហ្នឹងខ្ញុំនៅកន្លែង។ ឮតែស្នូរឡានយប់ហ្នឹងចេញទៅ ដល់ពេលមួយ ប្រហែលជាមួយកន្លះម៉ោងទៅក្រោយហ្នឹងដីក្រោយកន្លែងខ្ញុំហ្នឹងវាមានព្រៃឫស្សីព្រៃអីហ្នឹង ដល់មួយសន្ទុះទៅឮស្រែកឮអ៊ីចឹងទៅខ្ញុំវាចេះ -- ឮហ្នឹងមិនចាំអារម្មណ៍ថា ស្រែកស្អីទេ បានថាគេទៅដេញស្អីៗទេ។ ដល់ថ្ងៃក្រោយទៀត ខ្ញុំទៅអូសឈើត្រឡប់មកវិញ បានធុំក្លិនធុំអី ខ្ញុំដើរទៅក៏ធុំខ្លាំងនៅខាងក្រោយហ្នឹងឯង។ បានខ្ញុំដឹងថា ស្មានតែគេទៅបរបាញ់បរអីពីដើម ជំនាន់នុ៎ងវាច្រើនគេបើកឡានបរបាញ់សត្វបរបាញ់អី។ ដល់ឮស្រែកបានខ្ញុំចាប់អារម្មណ៍។

[១០:៤៨:៥៤]

**ស៖** តើលោកដឹងថា ក្លិនស្អុយហ្នឹងវាមានភាពពាក់ព័ន្ធអីជាមួយហ្នឹងការស្រែកហ្នឹង តើលោកដឹងដោយរបៀបណា?

**ឆ៖** ដឹងនៅពេលខ្ញុំដើរទៅក្រោយទៅរបងកន្លែងដែលស្នាក់នៅហ្នឹង ដឹងពេលហ្នឹង។ វាជិតដែរវាមិនឆ្ងាយប៉ុន្មានប្រហែលជាពីរបីរយម៉ែត្រ។ ខ្ញុំដើរដកអាដែង គេហៅ "ព្រះស្វា"។ ដើរដកព្រះស្វាហើយនិងក្រចកអណ្តើកហ្នឹងយកមកស្លហូបហ្នឹង ដល់ដើរទៅវាធុំក្លិន ព្រោះដីម្តុំហ្នឹងជិតខែហ្នឹងវាច្រើនដុះព្រះស្វា យកមកញុំា យកមកស្លអីហូបបាន បានខ្ញុំដឹង។

**ស៖** ខ្ញុំយល់ ប៉ុន្តែខ្ញុំចង់យល់អំពីអ្វីដែលលោកបាននិយាយ។ ខ្ញុំចង់ដឹងថាតើ ឡានដែលលោកបានឃើញនៅពេលយប់ ព្រមទាំងសម្លេងស្រែក តើវាអាចជាសម្លេងស្រែករបស់សត្វ ដូច្នេះបន្ទាប់មក

វាទៅដល់ក្លិនស្អុយហ្នឹង។ ដូច្នេះ ខ្ញុំចង់ដឹងថាតើ ដោយសារហេតុផលអ្វី ឬដោយសារមូលហេតុអ្វីដែល លោកនិយាយថា ដែលថាមានទំនាក់ទំនងរវាងឡានដឹកមនុស្ស រវាងឡាន និងសម្លេងស្រែក ហើយទាក់ទងជាមួយនឹងក្លិនស្អុយទាំងនោះ មានអ្វីដើម្បីបង្ហាញពីភាពទាក់ទងគ្នានេះ?

**ឆ៖** នៅជំនាន់នោះ មិនមែនថា ពួក១៧មេសា ឬអ្នកចាស់ អ្នកអីទេ ទូទៅអ៊ីចឹង ឲ្យតែគេ ដូចថាយើងធ្វើខុសស្អីមួយ ឬមិនគោរពភារកិច្ចគេ ឬក៏អី មិនថាអ្នកចាស់ អ្នកថ្មីទេ ត្រូវតែគេយកទៅកសាងអ៊ីចឹងទៅ។ កសាងពីរបីដងហើយយើងមិនដឹងរឿងអីទៀត អាហ្នឹងគេដកចេញទៅ។ ជួនកាលក្នុងពីរបីខែអ៊ីចឹងទៅបាត់មេមួយៗ ពីរបីខែបាត់មេក្រុម។ សំខាន់អ្នកដែលកាន់ទ័ព មេក្រុម មេកងអីៗ ហ្នឹងច្រើនតែបាត់ខ្លួន។ ហើយមិនត្រឹមតែនេះ វាច្រើនតែអ្នកដែលធ្វើការចាស់ៗអ៊ីចឹង។ យូរៗបាត់មួយអ៊ីចឹងទៅ។ មិនដឹងគេដកទៅធ្វើការនៅឯណា ខ្ញុំមិនដឹងទេ តែទៅបាត់ខ្លួនៗ។

[១០:៥២:០២]

**ស៖** លោកសាក្សី តើលោកចាំទេថា លោកបានប្រាប់អ្នកស៊ើបអង្កេតមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយលោកបានចង្អុលប្រាប់គាត់អំពីដើមឈើធំមួយនៅកន្លែងដែលលោកនិយាយថា លោកឮសំឡេងស្រែក ហើយនិងធុំក្លិនស្អុយនោះ តើលោកចាំទេ? ថាលោកបានប្រាប់ទីកន្លែងហ្នឹងទៅ អ្នកស៊ើបអង្កេតនោះ?

**ឆ៖** ខ្ញុំចាំបាន។ ពេលនោះ ខ្ញុំដើរទៅ ទៅដក ដូចខ្ញុំប្រាប់មិញ ទៅដកដកព្រះស្វា ទៅដល់ដើមឈើធំហ្នឹង ខ្ញុំដើរទៅឃើញដានឡានចូលទៅហ្នឹងហើយ។ ដល់ពេល ខ្ញុំដកព្រះស្វាបានមួយក្តាប់ហើយ ខ្ញុំដើរទៅវាធុំក្លិន ខ្ញុំដើរចូលទៅបានឃើញ ឃើញកន្លែងហ្នឹងឯងហើយ ខ្ញុំចំណាំបានថា នៅដើមឈើហ្នឹង ដល់ពេល គាត់ចុះទៅឲ្យខ្ញុំជួយរក គាត់ខាងគាត់ចុះទៅហ្នឹង ខ្ញុំជូនទៅ គេកាប់វាលអស់ ទៅ វាឃើញតែគ្រហុកៗ វាអត់ឃើញកន្លែងសាកសពហ្នឹង ដែលអង្គាល់ខ្ញុំឃើញហ្នឹង កន្លែងរណ្តៅសាកសពនោះ វាពីរបីកន្លែងឯណោះ រណ្តៅនៅហ្នឹង។ ដល់ពេលក្រោយដែលគាត់ឲ្យខ្ញុំជូនទៅរកហ្នឹង ក៏វាបាត់អស់ហើយ បាត់អារណ្តៅ វាឃើញដូចថា គ្រាន់តែមានប្រហែលៗនៅហ្នឹងឯង ព្រោះកន្លែងហ្នឹងគេកាប់ដើមឫស្សីដើមអីអស់ គេរុញដើមឫស្សីអស់ទៅ។ វាយូរហើយគិតមើលវាតាំងពីហ្នឹងមកដល់ដែលគាត់ហៅខ្ញុំទៅហ្នឹង វាយូរហើយ។ តែខ្ញុំចំណាំបានដើមឈើធំហ្នឹង ដែលគេហៅដើមផ្តៀក។ ចំណាំបានអាហ្នឹងឯង ខ្ញុំនាំគាត់ដើរទៅ។

[១០:៥៤:០៩]

**សៈ** តើលោកចាំទេថាអ្នកស៊ើបអង្កេតម្នាក់ហ្នឹង បានប្រាប់លោកថា អត់មានអ្វីដែលនៅសល់ ដូចជា អត់មានសំណល់សាកសព ដូចជាលលាដ៍ក្បាល ឬក៏ឆ្អឹងអី។ តើគាត់ -- តើអ្នកស៊ើបអង្កេតនោះ មានប្រាប់លោកអ៊ីចឹងទេ?

**ឆៈ** គាត់ប្រាប់ដែរ តែវាអត់មានមែន ខ្ញុំទៅរកហ្នឹងអត់មានឃើញសល់អីទេ អត់មានទេ កន្លែងហ្នឹង គ្រាន់តែឃើញរណ្ដៅ រណ្ដៅដែលក្រហេតៗចាស់ៗហ្នឹង ឃើញកន្លែងហ្នឹង។ ហើយដែលពីសម័យហ្នឹងគឺ ស្រែកឮស្នូរស្រែកអី ស្រែកចេញពីកន្លែងហ្នឹង។ ខ្ញុំចាំបានតែពេលខ្ញុំដើរទៅ ឃើញនៅហ្នឹងតែម្ដង ឃើញ។ ដល់ពេលយើងពីហ្នឹងមកដល់ហ្នឹងទៅវាបាត់អស់ មិនដឹងទៅណា ខ្ញុំ -- បើខ្ញុំចាកចេញពីហ្នឹងយូរដែរហើយ។

**សៈ** ហេតុអ្វីបានជាលោកនិយាយមុននេះថា សំឡេងស្រែកដែលលោកឮហ្នឹង តើវាមិនអាចទេ ឬថា សំឡេងស្រែកហ្នឹងជាសំឡេងរបស់សត្វ?

**ឆៈ** ខ្ញុំអាចថា សំឡេងហ្នឹងគឺសំឡេងសាកសពហ្នឹងឯង ព្រោះខ្ញុំដើរទៅគឺឃើញធុំក្លិននៅកន្លែងហ្នឹង ហើយដល់ស្រែកហ្នឹងមិនបានប៉ុន្មានថ្ងៃមក វាធុំក្លិន។ ហើយដល់ពេលក្រោយមកទៀតហ្នឹង វាកន្លែងហ្នឹងឃើញរណ្ដៅពីរបីរណ្ដៅដែរ ព្រោះឡានវាចេញមកតាមផ្លូវហ្នឹងហើយ។

[១០:៥៦:០១]

**សៈ** លោកសាក្សី តើលោកដឹងទេថា តើតំបន់ណាៗ ឬក៏ភូមិភាគណា ថាតើព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង ស្ថិតនៅក្នុងតំបន់ ឬក៏ភូមិភាគណាដែរ?

**ឆៈ** នៅព្រលានយន្តហោះភូមិភាគបស្ចិម នៅកន្លែងហ្នឹងគេហៅភូមិភាគបស្ចិម តំបន់ម្ភៃប៉ុន្មានទេ បើស្រុកគេហៅកន្លែងហ្នឹងគេហៅថា ស្រុក២០។ តំបន់មិនដឹងតំបន់ប៉ុន្មានទេ ខ្ញុំ -- តំបន់សាមប៉ុន្មានខ្ញុំភ្លេចបាត់ទៅអាហ្នឹង។ ភូមិភាគៗបស្ចិម។

**សៈ** លោកនិយាយត្រឹមត្រូវហើយគឺតំបន់។ ចុះឥឡូវ ខ្ញុំថាតំបន់៣២ តើលោកយល់ថាម៉េចដែរ? -- តំបន់៣១។

**ឆៈ** អាហ្នឹងលេខគេ លេខតំបន់៣១។ តែដល់ភូមិភាគគេហ្នឹង គេហៅភូមិបស្ចិម ស្រុកៗ២០ អាហ្នឹងខ្ញុំចាំមិនបានផង។

**សៈ** តើលោកចាំទេថា អ្នកណាជាប្រធានតំបន់៣១ហ្នឹង?

**ឆៈ** តំបន់៣១ហ្នឹង ខ្ញុំអត់ចាំទេ ភ្លេចបាត់ហើយ យូរឆ្នាំហើយ ចាំមិនអស់ទេ។

[១០:៥៧:៥៧]

**ស៖** ប្រសិនបើខ្ញុំថា តាសារុន តើលោកនឹកឃើញ ឬក៏លោកអាចចាំបានទេ?

**ឆ៖** បាទ ឮគេថាអ៊ីចឹងដែរ ឮគេនិយាយថា តាសារុន ឈ្មោះថា តាសារុន ជំនាន់ហ្នឹង។

**ស៖** តើលោកដឹងទេអំពីមន្ទីរសន្តិសុខ ឬក៏មន្ទីរឃុំឃាំងដែលស្ថិតក្រោមតំបន់៣១ហ្នឹង លោកចាំទេ?

**ឆ៖** តំបន់ហ្នឹង តំបន់៣១ហ្នឹង គេហៅសន្តិសុខគេហ្នឹងគេហៅ "មន្ទីរតាបេះ" – គេហៅមន្ទីរ "តាបេះ"ៗ។ ខ្ញុំចាំបានគេហៅថា "មន្ទីរតាបេះ" នៅខេត្តកំពង់ឆ្នាំងហ្នឹង។ អាហ្នឹងគេហៅមន្ទីរតាបេះ។

[១០:៥៩:០៤]

**ស៖** តើមន្ទីរសន្តិសុខតាបេះហ្នឹងមានចម្ងាយប្រហែលប៉ុន្មានដែរ ពីព្រលានយន្តហោះកំពង់ឆ្នាំង?

**ឆ៖** ពីៗព្រលានទៅឆ្ងាយ ទៅដល់ខេត្តណោះ បើពីសាលាខេត្តទៅមន្ទីរតាបេះហ្នឹង ប្រហែលជាប្រាំ-៦០០ម៉ែត្រទេ។ ហ្នឹងដល់សាលាខេត្តហ្នឹង ដល់អាផ្លូវចូលនេះហ្នឹង តែបើចេញពីព្រលាននេះទៅវាគិតទៅពីព្រលានទៅប៉ុន្មានគីឡូទេនេះ ភ្លេចបាត់ មិនបានចាំទេអាហ្នឹង អត់បានចាំ។

**ស៖** ដោយសារតែពេលវេលា ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត ខ្ញុំចង់ពិភាក្សាជាមួយលោកអំពីបញ្ហាបន្ថែមថ្មីទៀត។ គឺថាគេចោទប្រកាន់ថា លោកលួចស្រូវ។ មានម្តងនោះគេចោទថាលោកលួចស្រូវ។ តើលោកអាចពន្យល់បានទេ ហេតុអ្វីបានជាគេចោទប្រកាន់លោកបែបនេះ? ខ្ញុំចង់សួរថាហេតុអ្វីបានជាគេចោទប្រកាន់ថាលោកលួចស្រូវ?

[១១:០០:២៦]

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធានតាមដែលខ្ញុំចាំគឺថា គេចោទប្រកាន់គាត់ថា លួចផ្តល់ស្រូវអង្ករទៅឲ្យពួកខាងបូព៌ានោះទេ។ នេះបើតាមដែលខ្ញុំចាំអំពីការសាកសួរការស្តាប់ចម្លើយ ក៏ដូចជាការផ្តល់សក្ខីកម្ម។ ដូច្នេះហើយ ខ្ញុំចង់ឲ្យមេធាវីបញ្ជាក់ឲ្យបានច្បាស់ទៅលើសំណួរនេះ។

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំរីករាយនឹងនិយាយឲ្យបានច្បាស់លាស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** គេចោទប្រកាន់ថាលោកផ្តល់ស្រូវអង្ករទៅឲ្យពួកខាងបូព៌ា។ តើត្រឹមត្រូវដែរឬទេ?

**លោក ចាន់ ម៉ន៖**

**ឆ៖** ត្រឹមត្រូវហើយហ្នឹង ពេលខ្ញុំមកបើកអង្ករ បើកអង្ករហើយបានដឹកអង្ករយកទៅខាងបូព៌ាទៅកាប់ឈើនោះ។ ដល់អ៊ីចឹង ខ្ញុំដឹកទៅ អង្ករថ្ងៃនុំងខ្ញុំដឹកច្រើនដែរប្រហែលជា ៥០-៦០ការុងណោះ! ដល់ហើយខ្ញុំទៅបើកថ្នាំពេទ្យ ដល់ទៅបើកថ្នាំពេទ្យទៅ ទៅជួបនឹងប្រធានមន្ទីរហ្នឹង។ ជួបគេថា "ហ៊ឺអ្នា! អ្អែងដឹកអង្ករអីច្រើនម្ល៉េះ ដឹកទៅឯណា? ដឹកឲ្យខ្មាំងស៊ី?" ខ្ញុំថា "អើ!ៗ បើឲ្យខ្ញុំ ថាខ្ញុំដឹកអង្ករឲ្យខ្មាំងស៊ី មានតែខ្ញុំហ្នឹងខ្មាំងដែរ?" ខ្ញុំថាអ៊ីចឹង។ ដល់អ៊ីចឹងទៅខ្ញុំទៅនិយាយជាមួយពេទ្យ។ និយាយជាមួយពេទ្យហ្នឹង ពេទ្យក៏ថា "ថ្នាំហ្នឹងយកប៉ុន្មាន?" ខ្ញុំថា ថ្នាំគ្រុនចាញ់ហ្នឹងឲ្យបាន២០០កញ្ចប់មកអាកញ្ចប់សុងៗគេហ្នឹង។ ខ្ញុំសុំគេ ២០០ ហើយថ្នាំលេបសម្រាប់ឈឺចាប់ ហើយនិងថ្នាំរបួស ថ្នាំអីហ្នឹង។ ដល់ពេលទៅវាថាទៀត ថាឲ្យខ្ញុំទៀតថា "ហ៊ឹះ! អ្អែងទៅឈឺចាប់ស្អីអ្នា ដើមថ្នាំគគោកក្នុងព្រៃហ្នឹង មិនកាប់ធ្វើថ្នាំទៅ!" ខ្ញុំថា "អើ បើនិយាយអ៊ីចឹងដដែលៗ មានតែ បងចេង ឯងទៅធ្វើទៅ!" ខ្ញុំក៏និយាយលេងអ៊ីចឹង មិនបានចាប់ភ្លឹកថាគេចង់ធ្វើបាបខ្ញុំអី អត់ដឹង។ ដល់ខ្ញុំមកវិញបាន៣ថ្ងៃ បានគេចាប់ខ្ញុំហ្នឹងបណ្ដោយទៅ។

**ស៖** តើការចោទប្រកាន់ថាលោកបានយកអង្ករទៅ -- យកអង្កររបស់កងពល៥០២ ឬក៏យ៉ាងណា? គេចោទអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១១:០៣:១៨]

**ឆ៖** អង្ករហ្នឹង អង្ករនៅក្នុង៥០២ហ្នឹង ខាងសេដ្ឋកិច្ច។ តែពេលដែលខ្ញុំទៅហ្នឹង គេប្រាប់ថាបងល្វៃ ហ្នឹងគាត់ប្រាប់ថា "អង្ករស្អីៗ អ្អែងត្រូវទៅបើកនៅសេដ្ឋកិច្ច។ បើកដូចថាប៉ុន្មាននាក់ ទៅប៉ុន្មានកង ប៉ុន្មានក្រុម ឡានមានប៉ុន្មានអីប៉ុន្មានហ្នឹង ដាក់តាមហ្នឹងទៅ។ យកទៅប៉ុន្មានខែ ទៅកាប់ឈើហ្នឹង"។ ដល់ខ្ញុំទៅមុនដំបូង ខ្ញុំដាក់អង្ករតែ ១០ការុង វាអស់ទៅ ខ្ញុំត្រឡប់មកវិញ បានខ្ញុំដាក់អង្ករថែមទៅទៀតៗទៅ អង្ករហ្នឹងយកនៅក្នុង៥០២ ហ្នឹងឯង។ម្ហូបអីក៏យកនៅ៥០២ហ្នឹងដែរ យកទៅផ្ដល់ឲ្យខាងបូព៌ាហ្នឹង ព្រោះបូព៌ាហ្នឹងយកពីណោះមក គេយកមកចំណុះនៅក្នុងកង៥០២ហ្នឹងដដែលៗ យកមកដាក់ហ្នឹង យើងគេឲ្យធ្វើការដូចតែគ្នាហ្នឹង នៅកាប់ឈើហ្នឹង។

**ស៖** តើលោកមានការណែនាំជាលាយលក្ខណ៍អក្សរ ឬក៏ការបញ្ជាពី ល្វៃ ជាលាយលក្ខណ៍អក្សរដើម្បីឲ្យយកលិខិតទៅបង្ហាញអ្នកណាម្នាក់ដែលអាចបញ្ឈប់ក្បួនឡានរបស់ក្រុមលោក ឬក៏អត់ទេ?

**ឆ៖** សុំម្ដងទៀត ស្ដាប់អត់បាន។

**សៈ** តាមដែលខ្ញុំយល់ គឺថាគេបញ្ជាឲ្យលោកដឹកអង្ករហ្នឹងទៅឲ្យកងទ័ពមកពីភូមិភាគបូព៌ា។ តើលោកមានការបញ្ជាជាលាយលក្ខណ៍អក្សរណាមួយ លិខិតណាមួយដើម្បីបង្ហាញទៅឲ្យកងទ័ពណាមួយ បញ្ឈប់ឡានរបស់លោក បញ្ឈប់លោក នៅពេលដែលលោកធ្វើដំណើរលើផ្លូវនោះ ដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សី កុំទាន់អាលឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១១:០៥:៣៧]

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំមិនដឹងថា តើភស្តុតាងដែលគាត់ផ្តល់នោះ តើគាត់បញ្ជាទៅឲ្យផ្គត់ផ្គង់អង្ករទៅឲ្យកងទ័ពមកពីភូមិភាគបូព៌ា ឬក៏យ៉ាងណា? ខ្ញុំសូមឲ្យមេធាវីការពារក្តីបញ្ជាក់ថាតើអង្ករនេះគេមានបំណងចែកទៅឲ្យកងទ័ពមកពីភូមិភាគបូព៌ា ឬជាអង្ករសម្រាប់អ្នកធ្វើការផ្សេងទេ? វាអាចថា ជួនកាល ឬក៏ជួនកាលថាការចែកអង្ករនេះគឺថា គាត់មានសិទ្ធិក្នុងការធ្វើបែបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដឹងថាសក្ខីកម្មរបស់គាត់នេះ គឺអនុកងពល៥០២ ណែនាំឲ្យគាត់ដឹកអង្ករទៅកងទ័ពមកពីបូព៌ា។ អ៊ីចឹងបានជាខ្ញុំសួរថា តើគាត់មានការបញ្ជាជាលាយលក្ខណ៍អក្សរដែរទេ ឬក៏គ្រាន់តែមានការបញ្ជាផ្ទាល់មាត់ទេក្នុងការឲ្យដឹកអង្ករហ្នឹង។

[១១:០៦:០០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** លោកសាក្សីខ្ញុំសូមរៀបសំណួរនេះឡើងវិញ។ លោកបាននិយាយថា មេបញ្ជាការឈ្មោះល្វៃ នេះណែនាំឲ្យលោកធ្វើយ៉ាងដូច្នេះ។ តើគាត់មានចេញលិខិតជាលាយលក្ខណ៍អក្សរទៅឲ្យលោកដើម្បីឲ្យលោកដឹកអង្ករហ្នឹងទៅចែកកងទ័ពបូព៌ាហ្នឹងដែរឬទេ?

**លោក ចាន់ ម៉ន៖**

**ឆៈ** ដែលខ្ញុំមកបើកអង្ករហ្នឹង គ្រាន់តែទៅប្រាប់គាត់ គាត់ថាមិនបាច់ធ្វើអីទេ ទៅយកមក។ អង្ករដូចយកប៉ុន្មាន ដូចថា ២០ការុង ៣០ការុង ដាក់តាមហ្នឹងទៅ។ ហើយម្ហូប អំបិល ស្អីៗហ្នឹង ដាក់តាមហ្នឹង ទៅប្រាប់គេ យកប៉ុន្មានយកប៉ុណ្ណឹងទៅ យកឲ្យគេទៅ។ ខ្ញុំទៅប្រាប់គេអ៊ីចឹងទៅ។ ហើយដូចថា ថ្នាំពេទ្យ ថ្នាំអី ប្រាប់ទៅគាត់ចឹងទៅ គាត់ថាទៅៗឲ្យគេរៀបចំឲ្យទៅ យកអីយកទៅ។ មិន

ដែលថា គាត់ធ្វើសំបុត្រ ធ្វើអីស្នាមឲ្យ អត់ទេ អត់មាន។ ពេលបើកអង្គរ ពេលអីហ្នឹង អត់។ ពេលដែលបញ្ជូនខ្ញុំទៅ ក៏អត់មានធ្វើសំបុត្រស្នាមឲ្យខ្ញុំថា "ហ៎! ទៅកន្លែងនេះ កន្លែងនោះ" អត់ទេ គ្រាន់តែប្រាប់នឹងមាត់ថា "អ្នែងនាំទៅកន្លែងនេះ ទៅធ្វើការនៅកន្លែងនេះអ៊ីចឹង" អត់ដែលមានសំបុត្រអី។

[១១:០៧:៥៣]

**ស៖** ខ្ញុំយល់ហើយ។ តើអ្នកណាជាអ្នកចាប់ខ្លួនលោកហ្នឹង? ចាប់នៅពេលណា? ចាប់កន្លែងណា? មូលហេតុអីបានជាគេចាប់ខ្លួនលោក?

**ឆ៖** ពេលចាប់ ខ្ញុំដឹកឈើមកវិញ។ ដឹកឈើមកវិញហើយ បានខ្ញុំទម្លាក់ឈើទម្លាក់អីអស់ ខ្ញុំធ្វើរបាយការណ៍ឲ្យគេហ្នឹង ធ្វើអាឈើដែលដឹកមកបានប៉ុន្មានជើង ប៉ុន្មានដើម ធ្វើឲ្យគេ។ ដល់តែពេលថ្ងៃហ្នឹងធ្វើមិនទាន់ហើយផង គេមកហៅ។ ហៅថាឲ្យខ្ញុំហ្នឹងទៅប្រជុំ។ ហើយខ្ញុំថា "ប្រជុំនៅឯណា?" ប្រជុំនៅវត្ត គេហៅថាវត្ត ស្អីម៉េចទេ វត្តហ្នឹងភ្លេចឈ្មោះវាហើយ។ ខ្ញុំថា អ៊ីចឹងទៅមុន ខ្ញុំទៅតាមក្រោយគេ។ គេអត់សុខចិត្តទេ។ គេថា ទៅឡើងឡានទៅទាំងអស់គ្នា។ ឲ្យឡើងឡានទាំងអស់គ្នា។ ខ្ញុំក៏មិនបាននេះដែរ យកតែក្រដាសប៉ុន្មានសន្លឹកហ្នឹង ហើយកាន់ទៅ ហើយឡើងឡានទៅ។ ហើយស្លៀកខោខ្លី ពាក់អាវម៉ុងទីហ្គុយហ្នឹង អត់មានស្អីទេ ព្រោះខ្ញុំកាលហ្នឹងខ្ញុំចេះហូបបារីហ្នឹង ហូបថ្នាំខ្លាំង។ ហូបថ្នាំខ្លាំងអាមូលដៃ ប៉ុនធំៗហ្នឹង ស្លឹកកកោះហ្នឹង។ ខ្ញុំក៏ជក់ដើរទៅ។ ដល់ពាក់កណ្ដាលផ្លូវ គេថា "ឈប់ជក់ទៅហុយណាស់" ដល់អ៊ីចឹង ខ្ញុំបោះចាលៗ។ គ្រាន់តែគេឲ្យដល់ឡានហ្នឹង -- ដល់កន្លែងហ្នឹងចុះទៅ ឡើង -- វិហារហ្នឹងវាមានមាត់ច្រកពីរ។ គេឲ្យឡើងពីលិចទៅ។ គ្រាន់តែឡើង គេគ្រឹបហ្នឹងខ្ញុំអត់ដឹងថាគេចាប់។ មិនដឹងថាគេចាប់ឯណា អាងថាគេថាប្រជុំចូល ទៅដល់អត់មានឃើញមនុស្សអីផង។ គ្រាន់តែគ្រឹបចូលហ្នឹង មានដឹងថាស្អីៗ អត់ដឹងទេ។

[១១:០៩:៥៨]

**ស៖** ខ្ញុំមានការយល់ច្រឡំ។ លោកគួរតែត្រូវបានប្រាប់គេភ្លាមៗថា លោកបានទទួលបញ្ជាពីមេបញ្ជាការលំដាប់លេខ២ នៅក្នុងកងពលហ្នឹង។ ហេតុម៉េចក៏លោកមិនប្រាប់គេថា លោកបានទទួលបញ្ជាផ្ទាល់ពីអនុបញ្ជាការកងពល?

**ឆ៖** ខ្ញុំ មកពីខ្ញុំមិនប្រាប់ហ្នឹង ព្រោះម្នាក់ហ្នឹងវានៅក្រោមកងពលហ្នឹងដែរ ហើយណាមួយវាធ្លាប់និយាយលេងអ៊ីចឹងដែរ ខ្ញុំមិនចាប់ភ្លឹកដែរថាគេចង់ធ្វើបាបខ្ញុំ។ ហើយខ្ញុំអត់ដឹងថា ខ្ញុំវាមានរឿងអីផង ព្រោះដឹងថា គេបញ្ជូន គេបញ្ជាឲ្យទៅកន្លែងនេះ ខ្ញុំទៅកន្លែងហ្នឹងទៅ។ បញ្ជូនទៅណា បញ្ជាឲ្យទៅ

ត្រង់ណា ខ្ញុំទៅតែកន្លែងហ្នឹងទៅ មិនដឹងថា គេចង់ប៉ងធ្វើបាបខ្ញុំ ឬស្អីក៏ខ្ញុំអត់ដឹងដែរ។ វាអត់មានដឹងទេ។ អាងតែថាទៅ សុំគាត់ យកស្អី គឺគាត់ឲ្យយកហ្នឹងទៅ។ ទៅៗខ្វះស្អីយកហ្នឹង គាត់ឲ្យទៅ បើកទ្វារយកទៅ មិនដែលមានសំបុត្រស្នាមអីទេ អត់ដែរ។

**សៈ** មានពាក្យមួយម៉ាត់ពី ល្វៃ។ តើគ្រាន់តែប្រើពាក្យថា ល្វៃ ជាអ្នកបញ្ជាឲ្យលោកទៅប្រាប់គេហ្នឹង គឺថាតើគ្រប់គ្រាន់ដែរទេ? ខ្ញុំនៅតែមិនយល់ថា ហេតុអ្វីបានជាគេចាប់ខ្លួនលោក?

**ឆះ** ដែលគេចាប់ហ្នឹង ខ្ញុំក៏មិនដឹងថាមូលហេតុអ្វីដែរ ដឹងតែខ្ញុំនិយាយលេងជាមួយគេហ្នឹង អារឿងអង្ករហ្នឹងឯង។ និយាយរឿងដូចថា "បើលោកឯងថា យកឲ្យ -- ខ្ញុំយកអង្ករឲ្យខ្មាំងស៊ី មានតែខ្ញុំហ្នឹងខ្មាំងដែរ"។ និយាយលេងអាហ្នឹងឯង ព្រោះវាធ្លាប់និយាយលេងដែរ មិនចាប់ភ្លឹកដែលគេមានតម្រុយទុកឲ្យហើយស្អីមិនដឹង ព្រោះខាងបូព៌ាហ្នឹង គាត់សុទ្ធតែគេយកមកពីនោះមកហ្នឹង វាត្រូវមានរឿងរ៉ាវអីពីណោះ មិនដឹង អីមិនដឹង។ ដល់គេឲ្យខ្ញុំទៅអ៊ីចឹងទៀតទៅ ហើយខ្ញុំនិយាយលេងទៀតទៅ វាចូលក្នុងអាផ្លូងហ្នឹងទៅ បានគេកំពុងតែគុំខ្ញុំរឿងអីមួយក៏អត់ដឹងដែរ។

[១១:១២:៣៣]

**សៈ** បាទ ខ្ញុំយល់ហើយ។ អ៊ីចឹងកងទ័ពដែលមកនាំខ្លួនលោកទៅវត្ត ទៅវិហារមួយហ្នឹង តើគេបើកឡានអស់រយៈពេលប៉ុន្មានដែរពីកន្លែងដែលលោកគ្រាន់តែថានិយាយលេងហ្នឹងថា "បើដឹកអង្ករទៅឲ្យខ្មាំង លោកខ្មាំងដែរ" ហើយទៅដល់វត្តហ្នឹង តើលោកចាំទេ ដឹកហ្នឹងចម្ងាយពេលអស់ប៉ុន្មាននាទី?

**ឆះ** អាហ្នឹង អង្ករអីខ្ញុំដឹកយកទៅព្រៃហើយអស់ ថ្ងៃក្រោយមកទៀតនោះបានមកវិញ គេមកចាប់ខ្ញុំហ្នឹង ខ្ញុំមកវិញហើយ មិនទៅចាប់នៅកន្លែងព្រៃនោះទេ ខ្ញុំមកដល់កន្លែងវិញហើយ។ វា ឡានហ្នឹងវា -- ព្រោះខ្ញុំនៅខាងលិចកន្លែងរោងចក្រអារឈើហ្នឹង ទៅពីកន្លែងកងពលហ្នឹងទៅ គេប្រហែលជា ១គីឡូដីទេ ១គីឡូ ឬកន្លះគីឡូដីហ្នឹងឯង វាចេញពីរោងចក្រអារឈើហ្នឹង ព្រោះខ្ញុំនៅមិនជាប់អី មកអ៊ីចឹងជួនកាលយប់ទៅ ខ្ញុំដេកទៅ បើមិនយប់ទេ ខ្ញុំត្រឡប់ទៅវិញទៅ។

**សៈ** ប្រហែលជាខ្ញុំយល់ច្រឡំចម្លើយលោកទាំងស្រុង ដោយសារតែគេចោទថាលោកដឹកអង្ករទៅឲ្យខ្មាំង អ៊ីចឹងបានគេចាប់លោកទៅទួលស្លែង។ លោកឆ្លើយថាអ៊ីចឹង ឬក៏ខ្ញុំស្ដាប់លោកច្រឡំទេ? ឬក៏ចម្លើយរបស់លោកហ្នឹង គឺថាគេចាប់លោកក្នុងវត្ត ហើយលោកគិតថាអាចបានរួចខ្លួនមកវិញ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១១:១៤:២៨]

**ឆ៖** ពេលគេចាប់ហ្នឹង គេចាប់ពីកន្លែងខ្ញុំទៅ យកទៅកន្លែងវត្តហ្នឹង មិនដឹងគេចាប់ពីណាពីណីទៀតទេ ទៅកន្លែងវត្តហ្នឹង កន្លែងវិហារហ្នឹង ហើយខ្ញុំទៅហ្នឹង គេយកទៅកន្លែងវិហារហ្នឹងដែរ។ ដល់រួចគេដឹកពីបញ្ជូនពីវិហារហ្នឹងទៅមកភ្នំពេញ មកនេះ ដឹកមកទាំងយប់ ព្រោះគេចាប់ហ្នឹងវាចាប់ពីម៉ោងចាប់ខ្ញុំប្រហែលម៉ោងប្រាំជាងគេចាប់ខ្ញុំ ហើយដល់ដឹកមក ទម្រាំមកដល់នេះវាយប់ហើយ ព្រោះវាចងមុខរហូត ខ្ញុំមិនដឹងថាដល់ត្រង់ណា ត្រង់ណីទេ។ តែគេចាប់ៗនៅហ្នឹងវិហារហ្នឹងឯង។ ហើយមិនដឹងគ្នាប៉ុន្មាននាក់ៗ ខ្ញុំអត់ដឹងទេ ព្រោះមិនដឹងគេយកពីណាខ្លះៗគឺអត់ដឹងទេ គឺដល់ពេលគេបោះលើឡើងឡានតែម្តង បានខ្ញុំទៅប៉ះជើងប៉ះដៃគេហ្នឹងឯង។ គេបោះពីលើវិហារទៅចូលក្នុងឡានហ្នឹង បានប៉ះ ដឹងថាមានអ្នកនៅក្នុងឡានហ្នឹងទៀត។ អាហ្នឹង ខ្ញុំអត់ដឹងថាប៉ុន្មាននាក់ ឬប៉ុន្មាននាក់ អត់ដឹងទេ។ ប៉ុន្តែមកដល់នឹងកន្លែងគេដាក់ចុះហ្នឹង ឃើញគេធាក់ទម្លាក់ៗ ឃើញតែទៅដល់ព្រូស តិចព្រូសហ្នឹង ដល់ខ្ញុំហ្នឹងបានគេធាក់មក ដូចវាអត់មានដូចគេទេ គឺឈរនៅលើគេ ដូចមានស្អី -- អានេះ បើនិយាយទៅ ដូចមានអីទ្រខ្ញុំ អត់មានដួលទេ នៅឈរលើគេ។ បានគេស្គាល់ខ្ញុំ បើថាខ្ញុំដួលក៏គ្មានអ្នកណាស្គាល់ដែរ ព្រោះចងមុខអស់ហើយ។

**ស៖** តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេ ថានៅពេលហ្នឹង តើលោកពិតជាដឹងថានាំខ្លួនលោកទៅកន្លែងមួយហៅទួលស្លែងហ្នឹង ឬក៏អត់ទេ?

[១១:១៦:១៨]

**ឆ៖** ខ្ញុំដឹងថា អាអ្នកយកខ្ញុំ ឲ្យខ្ញុំរត់ហ្នឹងថា វាប្រាប់ថា "អាហ្នឹងទួលស្លែង កន្លែងហ្នឹងហើយទួលស្លែង" វាប្រាប់អ៊ីចឹង។ ហើយដល់ពេលរៀបចេញ ដែលវាឲ្យអានេះរត់ហ្នឹងនោះ វាគូសផែនទីឲ្យរត់ហ្នឹងវានិយាយថា "ហ្អែងមិនធម្មតាទេ" វាដឹកដៃខ្ញុំចេញពីរបងហ្នឹង វាថា "មិនធម្មតាទេ ស-២១ ដឹងតែងាប់ហើយ តែលើកនេះហ្អែងធ្វើយ៉ាងម៉េចឲ្យរួចខ្លួន អញនៅខាងនេះមិនដឹងជាយ៉ាងណាទេ" វានិយាយប៉ុណ្ណឹងថា "មុននឹងងាប់និងរស់ ហ្អែងធ្វើយ៉ាងម៉េចរត់ឲ្យរួច អញនៅនេះមិនដឹងយ៉ាងណាដែរ" គ្រាន់តែនិយាយប៉ុណ្ណឹងទេ និយាយបានតែប៉ុណ្ណឹង ក៏វាថា "ទៅឲ្យលឿនទៅ" ខ្ញុំក៏រត់លឿនមក គ្មាននេះទេ រត់ គ្រាន់តែឮមនុស្ស ឮតែមាត់ហ្នឹងមិនថា ប្រុសឬស្រីទេ ចូលក្នុងលូបណ្តោយ លូទឹកស្អុយតាមហ្នឹង។ កាលជំនាន់ហ្នឹងលូទឹកស្អុយអត់មានសួរបិទគម្របទេ គម្របគេបើកអ៊ីចឹងហើយ ឲ្យតែឃើញមនុស្សដឹងតែចូល។ ទម្រាំតែដល់ផ្ទះគេ ដែលវាដាក់ឲ្យ។ ហើយខ្ញុំវាឈឺផង វាររយះ វាបោះលើឡាននេះអីវាដាច់អស់ហើយ។ នេះរយះ ហើយមុខមាត់នេះវាអុជនឹងភ្លើងបារីអីអស់ហើយ។ ដែលអង្គុយសុំ

បារីគេជក់លើឡាន។ ខ្ញុំមិនអាចនិយាយតទៅទៀតបានទេ វាជីវិតខ្ញុំវា ដូចកើតពីរដងអ៊ីចឹង។

**ស៖** ខ្ញុំជិតអស់ពេលហើយលោកសាក្សី ខ្ញុំមានសំណួរតិចតួចទៀត។ តើគេចងមុខលោករហូតនៅពេលដែលលោកចូលទៅបរិវេណមួយដែលគេហៅថា "ទួលស្លែង"នោះ អ៊ីចឹងគេចងមុខលោករហូតទៅដល់ហ្នឹង?

**ឆ៖** គេចងតាំងពីវត្តនេះទៅ ពីចាប់ពីវត្តនេះរហូតទៅ តែខ្ញុំធុំក្លិនបារី។ នឹកឃើញថា មុននឹងងាប់ខ្ញុំសុំបារីគេជក់។ មានតែប៉ុណ្ណឹងទេ ខ្ញុំនិយាយអត់កើតទៀតទេ។

[១១:១៩:០០]

**ស៖** ចុះបើគេចងមុខលោកជិតអ៊ីចឹងទៅហើយ ធ្វើយ៉ាងម៉េចបានលោកដឹងថាកន្លែងដែលលោកមកដល់ជាភ្នំពេញ?

**ឆ៖** ពេលគេធាក់ទម្លាក់មក គឺអ្នកទោសគេមានចាប់អីត្រឹមត្រូវ បោះអីត្រឹមត្រូវទេ គឺថាធាក់ទម្លាក់ៗមកហ្នឹង មកដល់ហ្នឹងទៅវាចូលហ្នឹងហើយ ដល់ពេលធ្លាក់មកហ្នឹង អាកន្សែង -- ក្រណាត់ខ្មៅហ្នឹងវារាងភើយៗ ឃើញមើលសម្លឹងមើលឃើញបានហ្នឹង តែវាងងឹតដល់ពេលដែលវាចាប់ខ្ញុំទាញដឹកដៃចេញទៅវាប្រាប់ បានដឹងថាមកដល់ភ្នំពេញ ដល់ -- វាប្រាប់ថា "ហ្នឹងហើយទួលស្លែង" បានខ្ញុំដឹង។ ដល់ខ្ញុំនៅលើឡានខ្ញុំអត់ដឹងទេ មិនដឹងចូលកន្លែងណាអីកន្លែងណា ខ្ញុំអត់ដឹងទេ។

**ស៖** បើលោកពិតជាត្រូវបានគេនាំយកមកភ្នំពេញមែន តើលោកអាចច្រឡំថាគេនាំខ្លួនលោកទៅទីបញ្ជាការកងពល៥០២ មិនមែនជាទួលស្លែងទេ អាចច្រឡំអ៊ីចឹងទេ?

**ឆ៖** អត់មានច្រឡំទេ ព្រោះខ្ញុំរត់ទៅ ខ្ញុំរត់ទៅរក មករក៥០២វិញ ខ្ញុំរត់មកដល់ស្ពានជ្រោយចង្វានេះ រត់ពីហ្នឹងមក មកដល់ស្ពានជ្រោយចង្វានេះ។

**ស៖** ធ្វើម៉េចបានជាលោកដឹងពីកន្លែងដែលលោកចាប់ផ្ដើមរត់ចេញហ្នឹង ហើយទៅដល់កន្លែងទីបញ្ជាការរបស់កងពល២០២។ លោកមានចាំអីខ្លះដែរកាលហ្នឹង លោកមានចាំឈ្មោះផ្លូវ ចាំលេខផ្លូវចាំមហាវិថីអីទេ ទើបអាចឲ្យលោករកឃើញទីបញ្ជាការកងពល៥០២បាន?

[១១:២១:១២]

**ឆ៖** វាឲ្យអាដែងក្រដាសមក។ វាគូរក្រដាសហ្នឹងមក ត្រង់ណាៗ ភ្នំ -- ត្រង់ណាផ្លូវនេះ។ គេគូរតាមផ្លូវលេខ១ លេខ២អ៊ីចឹង អាផ្លូវចេញខាងណាវត្តភ្នំ ខាងណាស្ទឹងហ្នឹង វាដាក់តាមហ្នឹងទាំងអស់ វាគូរឲ្យ រត់ចេញមក។ ដល់ពេលចេញ វាគូរមានប្លង់នៅហ្នឹងស្រេច ក្រដាសនៅហ្នឹង។ វាថា កុំឲ្យបាត់

តែបាត់អាហ្នឹង អ្អែងតែរកអត់ឃើញហ្នឹង អ្អែងវង្វេងនៅក្នុងហ្នឹង គេចាប់បានមុខងាប់។ បើងាប់អ្អែងក៏ងាប់ អញក៏ងាប់។ អាហ្នឹងប៉ុណ្ណឹង គេប្រាប់តែប៉ុណ្ណឹង។

[១១:២២:០៥]

**ស៖** ខ្ញុំមានសំណួរច្រើនទៀតត្រូវសួរលោក ប៉ុន្តែខ្ញុំវាអស់ម៉ោងទៅហើយ។ អ៊ីចឹងខ្ញុំសូមអរគុណណាស់ ដែលលោកបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអស់ហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រម។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ជាមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ អ៊ីចឹង ខ្ញុំនឹងចោទសំណួរបន្ថែមមួយចំនួន។ ខ្ញុំជៀសវាងមិនសួរសំណួរដដែលៗ ហើយនិងសូមឲ្យលោកឆ្លើយមកឲ្យខ្ញុំ និងសំណួរខ្ញុំឲ្យច្បាស់។ ខ្ញុំសុំការបំភ្លឺមួយលោកសាក្សី។ លោកសាក្សីបាននិយាយអំពីអង្គការលេខ ឬក៏ឋានានុក្រមរបស់ព្រលានយន្តហោះ ដោយនិយាយអំពីលោក ល្វៃ។ ដោយមេនិយាយពីមេគាត់ដែលឈ្មោះ ម៉េត និងនិយាយអំពីប្រធានមន្ទីរឈ្មោះ យ៉េង។ តើយើងយល់ស្របនឹងគ្នាដែរឬទេ ក្នុងការនិយាយថា យ៉េង តូចជាង ល្វៃ ហើយនិង ម៉េត?

[១១:២៣:៥៤]

**លោក ចាន់ ម៉ន៖**

**ឆ៖** បីនាក់ហ្នឹង តាយ៉េង ហ្នឹងប្រធានមន្ទីរ វាមានសិទ្ធិត្រឹមប្រធានមន្ទីរ តែវាចាត់ចែងទាំងអស់ហ្នឹងឯង។ ប្រធានមន្ទីរហ្នឹងគេចាត់ចែងកម្លាំងអី មកពីកងពលមក នៅលើប្រធានមន្ទីរជាអ្នកចាត់ចែង។ ឲ្យទៅណា ធ្វើៗ អាហ្នឹងនៅលើប្រធានមន្ទីរ។

**ស៖** ក៏ប៉ុន្តែអម្បាញ់មិញនេះសំណួរខ្ញុំហ្នឹង គឺចង់ដឹងថាក្នុងឋានៈជាប្រធានមន្ទីរហ្នឹង គាត់មាន

អំណាចជាង ល្វៃ ហើយនិង ម៉េត ឬក៏យ៉ាងណា?

**ឆៈ** អំណាចហ្នឹងយកពី តាម៉េត – យកពី ម៉េត, យកពីបងល្វៃ មក ដូចថា បងម៉េត បញ្ជាមកខាងប្រធានមន្ទីរហ្នឹង ប្រធានមន្ទីរហ្នឹងគេបញ្ជាមកខាងពួកខ្ញុំហ្នឹងធ្វើការទៀត។ ដូចថាបញ្ជាខ្ញុំទៅណាទៅ ប្រធានមន្ទីរហ្នឹងគេចាត់ចែងទៅទៀត។ តែប្រធានមន្ទីរហ្នឹង បើបានពីកងពលហ្នឹងមកហើយ គេចាត់ចែងហ្នឹង គេសឹងតែថានិយាយមកវាចង់ខ្លាំងជាងកងពលទៀត។ វាច្រើនតែអ៊ីចឹងឯង។ គេមាននាទីចាត់ចែងទាំងអស់ហ្នឹងឯង។

[១១:២៥:៤៣]

**សៈ** អ៊ីចឹងយើងយល់ស្របគ្នាដែរឬទេថា យ៉េង ហ្នឹងត្រូវតែស្ដាប់តាមបង្គាប់ ល្វៃ ហើយនិង ម៉េត –ស៊ូ ម៉េត– តើលោកយល់ស្របនឹងខ្ញុំដែរឬទេ?

**ឆៈ** បាទ អ៊ីចឹងឯង យល់ស្របតាមហ្នឹងឯង ព្រោះគេនៅ តាយ៉េង ហ្នឹងវានៅក្រោមបង្គាប់របស់ ល្វៃ – បងល្វៃ ហើយនិង បងម៉េត ហ្នឹងឯង។

**សៈ** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក គឺឯកសារ E3/5278 ជាភាសាបារាំងគឺ 00 -- ជាភាសាអង់គ្លេស 00292823, ERN ជាភាសាខ្មែរគឺ 00287527 លោកបាននិយាយអំពីមនុស្សម្នាក់ទៀត ដែលឈ្មោះ សុង។ លោកនិយាយថា គាត់ឈ្មោះ សុង គាត់ជាអ្នកគ្រប់គ្រងផ្ទាល់លើកម្មករយោធា ហើយគាត់ស្ថិតនៅក្រោមបញ្ជារបស់ ល្វៃ។ តើលោកអាចនិយាយលម្អិតបន្តិចបានទេ អំពីឈ្មោះ សុង នេះ?

**ឆៈ** បងសុង ហ្នឹងគាត់ផ្នែកខាង ដូចថានៅក្នុងមន្ទីរហ្នឹងដែរ តែគាត់ផ្នែកខាងវាស់វែង ខាងស្ទង់ខាងអីហ្នឹងទាំងអស់។ កូនចៅគាត់ហ្នឹងខាងស្ទង់ ខាងវាស់កន្លែងណាឲ្យគេធ្វើ កន្លែងណាៗហ្នឹងគាត់ស្ទង់ហើយអីហើយ ឲ្យគេធ្វើហ្នឹង។ អាហ្នឹងផ្នែកគាត់ផ្សេង នៅហ្នឹងដែរ តែគាត់ផ្សេងគ្នា។ ការងារគាត់ផ្សេង។

**សៈ** យើងមានសាក្សីមួយទៀត ដែលនិយាយអំពី -- គឺសាក្សី E3/3959, ERN ជាភាសាបារាំងគឺ 00486100, ERN ជាភាសាខ្មែរ 00270118, ERN ជាភាសាអង់គ្លេស 00278625 គាត់និយាយអំពីឈ្មោះ ធួក។ តើឈ្មោះ ធួក នេះមានបាននិយាយអំពីអ្វីប្រាប់លោកដែរឬទេ?

**ឆៈ** ខ្ញុំភ្លេចបាត់ហើយ។ ចងចាំអត់អស់។

[១១:២៨:០០]

**ស៖** លោកបាននិយាយថា ក្នុងចំណោមការងារដែលគេឲ្យធ្វើនៅលើព្រលានយន្តហោះកំពង់-ឆ្នាំងហ្នឹង គឺលោកត្រូវដឹកយោធាទៅកន្លែងកាប់ឈើ លោកបើកឡាននៅពេលនោះ។ អ៊ីចឹងសំណួរខ្ញុំចង់ដឹងថាតើនៅពេលនោះ លោកមានរបបសាំង ឬម៉ាស៊ូតអ្វីដែរឬទេ? ហើយលោកគ្រប់គ្រងការផ្គត់ផ្គង់សាំង ឬម៉ាស៊ូតហ្នឹងតាមរបៀបណាដែរ?

**ឆ៖** សាំង ម៉ាស៊ូតហ្នឹង ពេលបើកហ្នឹង គេឲ្យ គេធ្វើក្រដាសទៅយកទៅឲ្យកន្លែងកាន់សាំងហ្នឹង កាន់ម៉ាស៊ូត កាន់អីហ្នឹងយកក្រដាសហ្នឹងទៅឲ្យទៅ យើងថា គេប៉ុន្មាន ក្នុងឡានមានប៉ុន្មានហ្នឹងគេចាក់ ដូចថាឡាន១០អ៊ីចឹង គេឲ្យឡានមួយ១០០ ឬឡានមួយ២០០ គេឲ្យក្រដាសហ្នឹងទៅ គេឲ្យបូមនៅកន្លែងហ្នឹង គេបូមដាក់ឲ្យយើងតែប៉ុណ្ណឹងមក។ អត់មានពិបាកអីទេ ប្រេសម៉ាស៊ីន ប្រេងអី ខ្វះប៉ុន្មានអីប៉ុន្មានហ្នឹង ធ្វើគេដាក់ក្រដាសឲ្យយកទៅឲ្យគេឲ្យតាមហ្នឹងមក។ អាហ្នឹងកន្លែងប្រេង។

[១១:៣០:៣៥]

**ស៖** មុននឹងសម្រាក ខ្ញុំមានចំណុចមួយទៀត ចង់លើកឡើង ព្រោះយើងឥឡូវនេះម៉ោងជិតដប់មួយកន្លះហើយ។ លោកបាននិយាយនៅក្នុងសវនាការម្សិលមិញ ម៉ោង១០:៣៩នាទី លោកបាននិយាយថា ម៉េត ហ្នឹង ឲ្យចេញ សេចក្តីណែនាំដល់លោកដោយផ្ទាល់ទាក់ទងនឹងការងារដែលលោកត្រូវធ្វើ។ អ៊ីចឹងសំណួរខ្ញុំចង់ដឹងថា ក្រៅពីគាត់សុំឲ្យទៅកាប់ឈើជាមួយយោធាមួយចំនួននោះ តើគាត់មានប្រគល់ការងារអ្វីមួយផ្សេងទៀតដល់លោកដោយផ្ទាល់ដែរឬទេ? ពីព្រោះថាកន្លងមកលោកបាននិយាយថា តាយ៉េង ហ្នឹង ជាអ្នកបែងចែកការងារឲ្យធ្វើ។ អ៊ីចឹងខ្ញុំចង់សួរថា ម៉េត នេះ ឈ្មោះម៉េត នេះចេញបញ្ជាឲ្យលោកធ្វើការដោយផ្ទាល់ហ្នឹងប៉ុន្មានដងដែរ ក្រៅពីបញ្ជូនទៅកាប់ឈើនោះ?

**ឆ៖** ក្រៅពីកាប់ឈើ គាត់បញ្ជាដូចថា ដឹកកម្លាំងទៅ ដឹកចិនដឹកអី អាហ្នឹងបញ្ជាពីគាត់ផ្ទាល់បានខ្ញុំទៅ។ ដូចថាបញ្ជាឲ្យដឹកចិនទៅមើលចុងព្រលាន វាស់កន្លែងធ្វើព្រលានទៅ អាចុងព្រលានត្រង់ណា ហើយទៅគេ ទៅធ្វើនៅថ្នល់រទេះភ្លើងអី គាត់បញ្ជាឲ្យទៅអ៊ីចឹងទៅ ដឹកគេទៅៗ។ អាហ្នឹងវាច្រើនកន្លែងដែរ ខ្ញុំចាំមិនអស់ទេ ឲ្យតែមានការអីចាំបាច់ហ្នឹង គាត់ប្រើទៅហើយ។ វាចាំមិនអស់។ ឲ្យតែចាំបាច់មានគេមកប្រាប់ថា គាត់ហ្នឹងប្រើខ្ញុំទៅហើយ។ ទី១ គាត់ឲ្យខ្ញុំទៅជួបហើយ គេមកហៅ គាត់ឲ្យទៅជួប។ ដល់ទៅជួបទៅ ទៅដល់ទៅ គាត់ឲ្យទៅនេះ ទៅនោះអ៊ីចឹងទៅ ទៅតាមគាត់ទៅ។ ទៅចាក់ប្រេង ចាក់អី ឡានអីក៏ដោយ ទៅៗ យកទៅតាមដំណើរ។ គ្មានចាំអស់ទេ ខ្ញុំចាំអត់អស់។

[១១:៣២:៤៤]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមើលទៅឃើញថា ម៉ោងដប់មួយកន្លះហើយលោកប្រធាន ខ្ញុំនឹងបន្តក្រោយពេលសម្រាកអាហារថ្ងៃត្រង់លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣៣:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរជាថ្មីម្តងទៀតលោកសាក្សី។ មុនពេលសម្រាក យើងបានឈប់នៅត្រង់កន្លែងដែលលោកពន្យល់ថា ម៉េត ហ្នឹងបង្គាប់បញ្ជាមកលោកដោយផ្ទាល់។ អ៊ីចឹងសំណួរខ្ញុំចង់ដឹងថា នៅពេលដែលទទួលការណែនាំពីគាត់ដោយផ្ទាល់នោះ តើ យ៉េង នោះគាត់មានបានទទួលដំណឹងទេ? គាត់ដឹងថា ម៉េត ហ្នឹងបង្គាប់បញ្ជាមកលោកដោយផ្ទាល់ដែរឬទេ?

**លោក ចាន់ ម៉ន៖**

**ឆ៖** ពេលដែលគាត់បំពេញ -- ប្រាប់ឲ្យខ្ញុំបំពេញភារកិច្ចហ្នឹងគឺ យ៉េង ហ្នឹងក៏នៅហ្នឹងដែរ ហើយហៅខ្ញុំមកហ្នឹងគឺ យ៉េង ហ្នឹងគេនៅហ្នឹងដែរ ព្រោះគេប្រធានមន្ទីរ។ ដល់ពេលទៅ គាត់ប្រើខ្ញុំទៅណា គឺខ្ញុំទៅហ្នឹង គ យ៉េង គេដឹងរឿងហ្នឹងដែរ។

**ស៖** ខ្ញុំមិនច្បាស់ចំណុចមួយ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់មេធាវី នួន ជា ខ្ញុំដូចជាយល់ថា យ៉េង ហ្នឹងជាប្រធានមន្ទីរមុនឆ្នាំ១៩៧៥។ ខ្ញុំយល់ច្រឡំ ឬយ៉ាងណា? តើលោកធ្វើការនៅក្រោមការបង្គាប់បញ្ជារបស់ យ៉េង ហ្នឹងចាប់ពីពេលណាមកដែរ?

**ឆ៖** នៅតាំងពីឆ្នាំតាយ៉េង នៅហ្នឹង វាឆ្នាំមួយពាន់ -- ៧៤, ៧៣ ពាក់កណ្តាល៧៣ ហ្នឹង។ តាំងពីហ្នឹងមកគឺ តាយ៉េង ហ្នឹងនៅកាន់ខាងតេអូ ប្រធានមន្ទីរហ្នឹងរហូតមកទល់ហ្នឹង ៧៥-៧៦។

**ស៖** រហូតដល់ឆ្នាំ១៩៧៦ ទេ ហេតុអីក៏មកដល់តែឆ្នាំ១៩៧៦ទេ ដែលលោកធ្វើការជាមួយ យ៉េង ហ្នឹង?

**ឆ៖** ពេលនុ៎ងចុះមកនៅខាងព្រលានថ្មីហ្នឹង មកជាប់គ្នារបូតហ្នឹងមក គេនៅខាងប្រធានមន្ទីរហ្នឹងរហូតហ្នឹងមក ខ្ញុំក៏ធ្វើការជាប់គ្នារហូតតាំងពីហ្នឹងមករហូត។ តាំងពីនៅពោធិ៍ចិនតុងរហូតចុះទៅនៅព្រលានថ្មីហ្នឹង ជាប់របូតមករហូត។

[១៣:៣៦:៥២]

**ស៖** ខ្ញុំដូចជាវង្វេងបន្តិចហើយ លោកនិយាយថាមានការដ្ឋានថ្មីនៅព្រលានយន្តហោះនោះ លោកកំពុងនិយាយអំពីព្រលានយន្តហោះកំពង់ឆ្នាំង ឬក៏យ៉ាងម៉េច?

**ឆ៖** ព្រលានធ្វើថ្មីហ្នឹង ព្រលានកំពង់ឆ្នាំងហ្នឹងហើយ។ គេមកចុះមកហ្នឹងទាំងអស់គ្នាហ្នឹងគេធ្វើការនៅហ្នឹង គឺព្រលានហ្នឹងរហូត។

**ស៖** បាទ ឥឡូវ ខ្ញុំព្យាយាមលោកបំភ្លឺចំណុចហ្នឹងមួយ។ លោកបាននិយាយថា លោកធ្វើការនៅ

ព្រលានយន្តហោះកំពង់ឆ្នាំងរហូតដល់ពេលដែលលោកត្រូវបានគេចាប់ខ្លួន ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅធ្វើការនៅកន្លែងរ៉ាដា។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីកាលៈទេសៈនៃការចាប់ខ្លួនរបស់លោកនៅពេលក្រោយ។ អ៊ីចឹង បើធៀបនឹងពេលដែលលោកចាប់ផ្តើមធ្វើការនៅកន្លែងរ៉ាដាហ្នឹង តើគេចាប់ខ្លួនលោកនៅពេលណាដែរ? រយៈពេលប៉ុន្មាន? ធៀបនឹងក្រោយមក ឬក៏មុនពេលដែលគេចាប់ខ្លួនលោកហ្នឹង?

**ឆ៖** មកនៅកន្លែងរ៉ាដាដែលគេចាប់ខ្លួនហើយ ដែលវិលពេលគេចាប់ខ្លួនមកវិញហ្នឹង បានគាត់ឱ្យខ្ញុំទៅនៅកន្លែងរ៉ាដា។ ក្រោយគេចាប់ខ្លួនមកហើយហ្នឹង រត់ចេញមកវិញហ្នឹង គាត់លែងឱ្យទៅនៅជាមួយក្រុមគេ ក្រុមតាយ៉េង ក្រុមអី ខ្ញុំមកនៅកន្លែងរ៉ាដាគេ នៅឯកំពូលភ្នំហ្នឹងរហូតទាល់តែ៧៩ រត់ហ្នឹងមកបានចុះ សម្ភារៈហ្នឹង រត់ទៅនឹងគេនឹងឯង។

**សៈ** ក៏ប៉ុន្តែពេល -- អ៊ីចឹងលោកចង់និយាយថា លោកចាប់ផ្តើមធ្វើការនៅកន្លែងរ៉ាដាហ្នឹងនៅក្នុងឆ្នាំ១៩៧៦ ឬក៏យ៉ាងណា?

**ឆ៖** ចេញពីកន្លែងព្រលានហ្នឹងមកនៅកន្លែងរ៉ាដាហ្នឹង ដូច៧៧ ចិតអី។ វាប្រហែលជាបីបួនខែទៅបានចាប់ផ្តើមរៀបចំដែលវៀតណាមចូលមកហ្នឹង រត់ហ្នឹង ខ្ញុំចុះ -- ដែលដឹកជញ្ជូនសម្ភារៈចេញគេឱ្យយកទៅបាត់ដំបង។ វាមិនចាំទេ ភ្លេចអស់ វាមិនដឹងជាខែណាថ្ងៃណាពិតប្រាកដ គឺអត់បានចាំ។ ៧៧ មិនដឹង, ៧៦មិនដឹង ព្រោះពេលរត់ហ្នឹងគឺមានតែចិត-- ទៅនៅហ្នឹង ទៅនៅលើភ្នំហ្នឹង ដឹងតែ៧៧ហ្នឹង មិនដឹងខែប៉ុន្មានទេ ខ្ញុំភ្លេច អត់ចាំទេ។

**សៈ** ខ្ញុំសូមឱ្យលោកបំភ្លឺចំណុចមួយ លោកបាននិយាយជាមួយលោកចៅក្រម ឡាវែន៍ អំពីអ្នកបច្ចេកទេសទាំង១២៥នាក់ -- ១២០នាក់ ដែលលោកជូនដំណើរពួកគេដែល ម៉េត ហ្នឹងគាត់ជាអ្នកផ្ញើអ្នកប្រគល់អ្នកទាំង១២០នាក់ហ្នឹងមកឱ្យលោក ហើយលោកបាននិយាយពីអ្នក១២០នាក់ហ្នឹង។ អ៊ីចឹងខ្ញុំចង់ដឹងថា តើអ្នកណាជាអ្នកទទួលខុសត្រូវលើអ្នកបច្ចេកទេសចិនទាំង១២០នាក់នេះ?

**ឆ៖** អ្នកទទួលខុសត្រូវចិនហ្នឹង នៅកន្លែងហ្នឹងគេមាននេះមួយ មានអ្នកបកប្រែហ្នឹង គេបកប្រែហ្នឹង វាចេះបកប្រែផង ហើយនិងគេដឹកនាំភ្ញៀវចិនហ្នឹងផង។ ហើយកន្លែងដែលគេនៅហ្នឹងចេញពីនេះមក អ្នកបកប្រែហ្នឹងចេញពីកន្លែង ម៉េត ហ្នឹងឯង តែខ្ញុំភ្លេចឈ្មោះហើយ មិនដឹងឈ្មោះអីទេ អ្នកដឹកនាំចិនទៅណា ទៅណី ដែលទៅ ដែលខ្ញុំទៅជាមួយហ្នឹង វាមានអ្នកបកប្រែហ្នឹងឯង អ្នកចាត់ចែង។ តែខ្ញុំមិនបានចាំឈ្មោះទេ ភ្លេចឈ្មោះ។

[១៣:៤២:០២]

**ស៖** ពេលដែលលោកនិយាយថា គាត់ហ្នឹងជាអ្នកមើលការខុសត្រូវអ្នករៀបចំចាត់ចែងការងារឲ្យចិនទាំងអស់ហ្នឹង លោកចង់សំដៅថាគាត់ហ្នឹងជាមេចិន ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំមិនដឹងដែរ មិនដឹងមេ មិនដឹងអីគេ គេមករក ឃើញមកហ្នឹង ដូចថាពេលណាចេញដើរទៅ គេប្រាប់ឡានទៅថា "មិត្តឯងយកឡានដាក់មនុស្សប្រាំនាក់ ឬ១០នាក់ អ៊ីចឹង" ឃើញម្នាក់ហ្នឹងឯងអ្នកបកប្រែហ្នឹង គេមកប្រាប់អ៊ីចឹង យកឡានទៅ ទៅដាក់កន្លែងជិតបន្ទប់គេហ្នឹង គេចេញមក ឡើងឡានយើងឡានទៅ ហើយឃើញតែម្នាក់ហ្នឹងឯងចេញចូល ប្រាប់ថាឲ្យយកឡានទៅដាក់ដឹកភ្ញៀវទៅនេះទៅនោះ កន្លែងនេះ កន្លែងនោះអ៊ីចឹង តែគេអ្នកបកប្រែ។

**ស៖** អ្វីដែលលោកកំពុងតែប្រាប់យើងហ្នឹង គឺថាគាត់ជាអ្នកបកប្រែ ហើយគាត់នឹងរៀបចំការងារតាមតម្រូវការរបស់អ្នកបច្ចេកទេសចិនហ្នឹងទេ គឺអ្នកបច្ចេកទេសចិនហ្នឹងហើយ ដែលប្រាប់គាត់ថា ឥឡូវត្រូវជូនគាត់ទៅកន្លែងនេះ កន្លែងនោះ គាត់ត្រូវការអ្វីមួយជាមួយដើម លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំនិយាយអ៊ីចឹងឯង និយាយពេលដែលគេមកប្រាប់ខ្ញុំហ្នឹងឲ្យយកឡានទៅដាក់ដឹកទៅនេះ ទៅនោះអ៊ីចឹង មានតែម្នាក់ហ្នឹងហើយ អ្នកបកប្រែផង អ្នកប្រាប់ឲ្យយកឡានទៅដឹកគេ។

**ស៖** តើលោកដឹងដែរឬទេថា មានទំនាក់ទំនងជាមួយនឹងអ្នកបច្ចេកទេសចិនទាំងអស់ហ្នឹង ជាមួយនឹង ល្វៃ ហើយនិង ម៉េត ហ្នឹងពួកគាត់ទាំងអស់គ្នាហ្នឹងមានទំនាក់ទំនងនឹងគ្នាយ៉ាងដូចម្តេចដែរ គឺ ល្វៃ, ម៉េត ហើយនិង ចិនទាំងអស់ហ្នឹង?

**ឆ៖** ឃើញតែពេលដែលខ្ញុំដឹកមកហ្នឹង ឃើញជួនកាលទៅ ម៉េត ហ្នឹងទៅជួបទៅ។ ជួនកាលបងល្វៃ ហ្នឹងគាត់ទៅជួបទៅ។ ចុះពីលើឡានអ៊ីចឹង ចូលទៅកន្លែងសម្រាកហ្នឹង ឃើញគេដើរទៅជួបគ្នាទៅ ខ្ញុំមិនបាននៅខាងក្នុងហ្នឹងទេ ខ្ញុំនៅខាងក្រៅឯណោះហ្នឹង មិនបានស្តាប់គេនិយាយអីស្អី អត់បានស្តាប់ទេ ព្រោះខ្ញុំនៅតែកន្លែងឡាន ដឹកទៅដល់ហើយ ខ្ញុំក៏ចតឡាន ចតអីអ៊ីចឹងទៅ អង្គុយនឹងឡាន អត់បានស្តាប់អី ឃើញតែគេទៅ ទាក់ទងគ្នា ធ្វើអីៗ ខ្ញុំអត់ដឹង។

[១៣:៤៥:០០]

**ស៖** តើលោកដឹងដែរឬទេ ថាតើចិនទាំង១២០នាក់ហ្នឹងធ្លាប់គ្រប់គ្រងលើក្រុមយោធាខ្មែរក្រហមដែរឬទេ?

**ឆ៖** គេមកដូចថាគេគ្រប់គ្រងទាំង -- ដូចថាតាមអាដែងទិសដៅគេ កន្លែងគេនីមួយៗ ដូចថាចិនហ្នឹងខាងអាដែងវ៉ែថ្ម ខាងចុចថ្ម។ ហ៏! មួយប៉ែកទៀត មួយក្រុមគេហ្នឹង មានចិនពីរបីនាក់អ៊ីចឹងទៅដែលខ្ញុំដឹកទៅដាក់អ៊ីចឹងមានខាងតភ្លើង ហើយគេគ្រប់គ្រងតែខាងយោធាបី បួន នាក់ ឬ១០នាក់ដែលទៅជាមួយហ្នឹង គេហៅយោធាហ្នឹងទាំងអស់ហ្នឹង ទាញខ្សែ ទាញអីហ្នឹងនៅលើគេៗប្រាប់ធ្វើម៉េចធ្វើតាមគេហ្នឹង តាមចិនហ្នឹង។ កប់ទុយោ កប់អី ទុយោទឹក ទុយោអីហ្នឹង អាហ្នឹងគេចិនគេអ្នកប្រាប់អ៊ីចឹងទៅ កប់ម៉េច តម៉េចអាហ្នឹងគេប្រាប់អ៊ីចឹង។

**ស៖** នៅក្នុងចម្លើយរបស់លោកស្រី គឺឯកសារ E3/5275, ERN ជាភាសាបារាំងគឺ 00292862, ជាភាសាខ្មែរគឺ 00287525, អង់គ្លេសគឺ 00355821។ លោកបានពន្យល់ថានៅពេលដែលគេឱ្យលោកធ្វើការនៅព្រលានយន្តហោះពោធិ៍ចិនតុង លោក -- ខ្ញុំដកស្រង់ដូចតទៅនេះ៖ "ពីរសប្តាហ៍ក្រោយមក ខ្ញុំឃើញយន្តហោះចិនដឹកសម្ភារៈ១តោន ហើយនិងស្បៀង សម្ភារៈយោធា មុង ភួយ ហើយនិងគ្រឿងកំប៉ុងផ្សេងៗមកចុះនៅព្រលានយន្តហោះពោធិ៍ចិនតុង"។ សូមបញ្ចប់ការដកស្រង់។ កាលពីម្សិលមិញ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់លោកចៅក្រម ឡាវែន៍ លោកបាននិយាយថា លោកនិយាយអំពីអាហារដែលចិនហូបនោះ ដូចជា គុយទាវ -- ហើយនិង មីគាវ ហើយនិងប៊ីយែរ ជាដើម។ អ៊ីចឹងខ្ញុំសួរលោកថាតើ មីគាវ ឬក៏អាហារទាំងអស់ហ្នឹងត្រូវបញ្ជូនមកពីប្រទេសចិន ឬក៏យ៉ាងណា?

[១៣:៤៧:៤២]

**ឆ៖** ខ្ញុំឃើញកន្លែងដែលគេធ្វើចុងភៅហ្នឹង អាកន្លែងចុងភៅហ្នឹង ចុងភៅខ្មែរ ៗហ្នឹងគេធ្វើសម្រាប់ទទួលចិនហ្នឹង គឺនៅបន្ទាយចាន់សារិហ្នឹងសុទ្ធតែខ្មែរ ហើយខ្ញុំចូលទៅកន្លែងគេហ្នឹង ចូលទៅហូបទឹកហូបអីហ្នឹង សួរគេ។ ទៅដល់ពេលជប់លៀង ពេលជប់អីហ្នឹង ខ្ញុំច្រើនតែបានចូលទៅដែរ ចូលទៅកន្លែងចុងភៅហ្នឹង ដែលគេដឹកភ្ញៀវមក គេដាក់ ជប់លៀងហ្នឹង ខ្ញុំដឹកមក ចូលហ្នឹង ក៏បានអង្គុយឃើញគេធ្វើ អាមីគាវ មីអីហ្នឹង ខ្មែរយើងធ្វើហ្នឹង ហើយនិងស្រាបៀរហ្នឹង គឺគេយករបស់គេមកពីនោះមក គេដបខៀវៗអាហ្នឹង ខ្ញុំចំណាំបាន គេហៅថាបៀរស្ព៊ីគេទេអាហ្នឹង។ មាននំប៉ុង មានស្ព៊ីគ្រប់មុខរបស់គេ អារឿងគ្រឿងកំប៉ុង គ្រឿងអីដែលគេយកមក មិនដឹងយកពីណាពីណី ខ្ញុំអត់ដឹងទេ តែពេលជប់លៀង ជប់អី គឺឃើញអ៊ីចឹង ឃើញមានមីគាវ មីអីហ្នឹង។

**ស៖** បាទ បើធៀបនឹងសម្រង់ដែលខ្ញុំទើបតែអានអម្បាញ់មិញនេះ ដែលលោកបានឆ្លើយថាមានស្បៀងដែលត្រូវបានផ្ញើមកពីចិនផងដែរ។ អ៊ីចឹងលោកមិនដឹងថាស្បៀងទាំងអស់នេះផ្ញើជូនទៅជនជាតិ

ចិនដែលធ្វើការនៅព្រលានយន្តហោះ ឬក៏ចិនដែលនៅស្រុកខ្មែរ ឬក៏យ៉ាងណានោះទេ លោកអាចបញ្ជាក់បានទេត្រង់ចំណុចនេះ។ តើអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ស្បៀងទាំងអស់នេះ គេយកមកសម្រាប់តែចិនដែលមកធ្វើការនៅខ្មែរហ្នឹងទាំងអស់ហ្នឹង ដែលគេយកមកកាលពីសម័យហ្នឹង ខ្ញុំឃើញ -- ពេលដែលជប់លៀង ជប់អីបានខ្ញុំឃើញប៊ីយែរ ឃើញមានប៊ីយែរ មានអី។ គេយកមកពី -- ស្រុកយើងដូចគ្មានទេអង្គាល់ហ្នឹង គ្មានប៊ីយែរអីផង អត់មានទេ ឃើញតែពេលដែលជប់លៀងហ្នឹងឯង។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកដដែល លោកបាននិយាយថា អ្នកដែលធ្វើការជាមួយចិនហ្នឹង ហូបបាយជាមួយចិនហ្នឹងតែម្តង។ គឺឯកសារ E3/5278, ERN ជាភាសាបារាំង 00355866, ERN ជាភាសាខ្មែរគឺ 00287530, ERN ជាភាសាអង់គ្លេសគឺ 0025-- អ៎! ជាភាសាបារាំង។ អ៊ីចឹង ខ្ញុំសួរលោកថាតើអ្នកដែលធ្វើការជាមួយគណៈប្រតិភូចិនហ្នឹង គឺគេមានរបបអាហារខុសពីអ្នកធ្វើការផ្សេងៗទៀត នៅព្រលានយន្តហោះហ្នឹង។ អ៊ីចឹងមែនទេ?

[១៣:៥១:០២]

**ឆ៖** ដូចថាអ្នកបើកឡាន អ្នកដើរតាមការពារហ្នឹង ទៅជាមួយចិនហ្នឹង ដោយតាមរៀងៗខ្លួនដូចថា តាមទិសដៅដែលគេធ្វើការរៀងៗខ្លួន មកវិញអ្នកឡានហ្នឹង គឺហូបជាមួយចិន តែមិនមែនជាមួយចិនហ្នឹងទេ គេដាក់ហូបឲ្យផ្សេង តែម្ហូបហ្នឹងគឺម្ហូបជាមួយគ្នា ម្ហូបចិនហ្នឹងដែរ នៅក្បែរហ្នឹង មានកន្លែងគេឲ្យហូបផ្សេង។ ហ្នឹងអ្នកឡាន ហើយនិងអ្នកកងការពារហ្នឹង។ វាបីពេលដែរ ដូចថាព្រឹកឡើងអ៊ីចឹងទៅ គេហូបនំប៉័ងហើយ យើងហូបនំប៉័ងនឹងគេទៅ។ គេហូបមី យើងហូបមីហ្នឹងគេទៅ។ អាហ្នឹងអ្នកទៅតាមចិនហ្នឹង។ តែបើអ្នកនៅធ្វើការដូចថាតាមក្រុម នៅឯនេះនោះ អត់មានទេ មានតែអ្នកកងការពារហ្នឹង បានហូបជាប់នៅនឹង។

**ស៖** ទាក់ទងនឹងរបបអាហារដដែល ជាពិសេសរបបអាហារសម្រាប់យោធា។ ម្សិលមិញ គេសួរសំណួរទៅលោក គឺសហព្រះរាជអាជ្ញាអន្តរជាតិសួរសំណួរទៅលោក ហើយខ្ញុំសូមឲ្យលោកធ្វើអត្ថាធិប្បាយលើចំណុចមួយបើសិនជាលោកដឹង គឺឯកសារ E3/5807, ERN ជាភាសាបារាំងគឺ 00233929, ERN ជាភាសាខ្មែរ 00052311, ERN ជាភាសាអង់គ្លេស 00183955។ ឯកសារនេះគឺជាកំណត់ហេតុប្រជុំនៃលេខាកងពល ហើយនិងកងវរសេនាធំស្វយ័ត ចុះនៅឆ្នាំ១៩៧៧។ គេពន្យល់អំពីជីវភាពយោធា "ត្រូវតែថែរក្សាជាប្រចាំ បីកំប៉ុងក្នុងម្នាក់"។ អ៊ីចឹង ទាក់ទងទៅនឹងសំណង់នៅ

ព្រលានយន្តហោះកំពង់ឆ្នាំងនេះ លោកបាននិយាយថាមានតែយោធានោះទេ ព្រោះថាវាជាព្រលានយន្តហោះយោធា។ តើលោកដឹងដែរឬទេ ថាមានវិធានការយ៉ាងដូច្នេះ ដែលគេចាត់ទុកថា ត្រូវឱ្យមាន ២៣កំប៉ុងសម្រាប់យោធា១០នាក់។ គេមានចាត់ចែងយ៉ាងដូច្នេះទេ ទាក់ទងនឹងរបបអាហារ?

[១៣:៥៤:២៣]

**ឆ៖** អាហ្នឹង ខ្ញុំអត់ដឹងដែរ វាភ្លេច។ អារឿងខាងសេដ្ឋកិច្ច គេចែកហ្នឹង មិនដឹងគេចែករបបយ៉ាងម៉េច អីយ៉ាងម៉េច ព្រោះព្រឹកឡើងហ្នឹង ដែលថាអ្នកធ្វើការ ដូចខ្ញុំអីហ្នឹង ទៅចេញផុតៗអស់ហើយ អត់មានដឹងថាគេចែកប៉ុន្មាន អីប៉ុន្មាន គឺអត់ដឹងដែរ។ វាភ្លេចអស់ហើយ។ ការចងចាំហ្នឹងវាមិនបានចាំទាំងអស់ទេ។

**ស៖** ឥឡូវខ្ញុំសូមចូលទៅចំណុចមួយទៀត។ លោកបាននិយាយពីវត្តមានយោធាមកពីភូមិភាគបូព៌ានៅក្នុងចម្លើយរបស់លោកដដែល គឺឯកសារ E3/5278, ERN 00355866 ERN ជាភាសាបារាំង ហើយជាភាសាខ្មែរគឺ 00287529, ជាភាសាអង់គ្លេសគឺ 00292825។ លោកបានពន្យល់ដូចតទៅនេះទាក់ទងទៅនឹងអ្នកមកពីខាងភូមិភាគបូព៌ា។ លោកបាននិយាយថា "ពេលដែល ល្វៃ ឱ្យខ្ញុំបញ្ជូនអ្នកមកពីបូព៌ាទៅកាប់ព្រៃឈើនោះ គេបានប្រាប់ថាពួកហ្នឹងជាប់និន្នាក្បត់អង្គការ ដោយសារតែមេៗភូមិភាគបូព៌ាហ្នឹងគេបានរត់ លួចរត់ចូលទៅប្រទេសវៀតណាម"។ សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកដឹងថាពួកគាត់ទាំងអស់នេះ និយាយអំពីមេណាដែលរត់ទៅវៀតណាមនេះ? ពួកយោធាដែលមកពីភូមិភាគបូព៌ានេះណ៎ះ គាត់និយាយ "មេ" ហ្នឹង គាត់សំដៅលើមេណាដែលរត់ទៅវៀតណាមនុ៎ង?

**ឆ៖** ខ្ញុំមិនដែលសួរនាំអីផង គ្រាន់តែសួរថា បើបានជាមកអីចឹងហើយកុំឱ្យរត់លួន កុំឱ្យគេចវេះពីកន្លែងដែលយើងធ្វើការ ហើយវាមានគ្រោះថ្នាក់អី។ មិនដែលបានសួរនាំថា "អូ៎! អ្នកឯងកូនចៅអ្នកណា ឡើងអ្នកណា អីណា រត់លួនទៅណាអីណាៗ" ខ្ញុំមិនសូវដែលសួរអីចឹងទេ មានតែខំការពារឱ្យគ្នាបានសុខសាន្ត។ អត់ដែលបានសួរនាំថា មេហ្នឹងឈ្មោះអីស្អីៗ គឺអត់ទេ។ មានតែលាក់ការណ៍ ជួយលាក់ ជួយបំពួនគ្នា នៅនឹងព្រៃហ្នឹងមាន។ បើសួរនាំបង្អើលស្អីៗ គឺអត់មានទេ។ មិនដឹងថាអ្នកណា អ្នកណពីគឺអត់។ បើមានតែណែនាំ អាហ្នឹងមាន។

**ស៖** រូបលោកផ្ទាល់ ធ្វើការនៅព្រលានយន្តហោះយោធាហ្នឹង តើលោកមានដឹងថា មានជម្លោះជាមួយប្រដាប់អាវុធជាមួយវៀតណាមដែរឬទេ ពេលដែលលោកធ្វើការនៅទីហ្នឹង លោកមានដឹងថាមានជម្លោះទេ?

[១៣:៥៧:៤៨]

**ឆ៖** ដឹង ៗមាន ដឹងថាគេ -- ព្រោះខ្ញុំដឹងតាមរយៈដែលប្អូនខ្ញុំជីដូនមួយទៀត គេនៅកងចល័តហ្នឹងដែលគេយកទៅ វា -- ខ្ញុំដឹងថាគេយកទៅវ៉ៃនៅព្រំប្រទល់វៀតណាម។ ដឹងពេលដែលខ្ញុំទៅមើលគេកាយខ្សាច់។ អាហ្នឹងខ្ញុំចេញមកនៅនេះហើយ នៅវ៉ាដាហើយ ទើបគេឡានខូចអីហ្នឹង គេហៅខ្ញុំទៅជួយធ្វើ ក៏បានដឹង។ អាហ្នឹងមានជម្លោះជាមួយវៀតណាម។

**ស៖** លោកសាក្សី ខ្ញុំសូមចូលទៅនិយាយពីចំណុចមួយទៀត ហើយខ្ញុំចង់ដឹងថាតើចម្លើយរបស់សាក្សីមួយទៀតធ្វើឱ្យលោកចងចាំ -- អម្បាញ់មិញលោកឆ្លើយតបទៅនឹងមេធាវី នួន ជា លោកហាក់ដូចជានិយាយថា លោកមិនចាំថាមានកងពលណាខ្លះទេដែលនៅ -- ដែលការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងនោះ។ ឥឡូវមានសាក្សីមួយ គឺសាក្សី TCW-910, ឯកសារ E3/5273, ERN ជាភាសាបារាំងគឺ 00355856, ERN ជាភាសាខ្មែរ 00282939, ERN ជាភាសាអង់គ្លេស 00296500។ នៅក្នុងកំណត់ហេតុរបស់គាត់នេះ គាត់ឆ្លើយថាគាត់ធ្លាប់បានធ្វើការនៅព្រលានយន្តហោះហ្នឹង។ គាត់និយាយថា គេបញ្ជូនមនុស្សពីភូមិភាគបស្ចិម និងបូព៌ា ហើយគ្រាន់តែមនុស្សភាគច្រើននោះ យោធាភាគច្រើនត្រូវបានបញ្ជូនមកពីភូមិភាគបូព៌ា។ អ៊ីចឹងសំណួរខ្ញុំចង់សួរថាតើលោកធ្លាប់ចាំថា មានគេបញ្ជូនមនុស្សទៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងពីភូមិភាគបូព៌ា និងភូមិភាគបស្ចិមដែរឬទេ?

**ឆ៖** ខ្ញុំដឹងថាគេបញ្ជូនមកពីភូមិភាគបូព៌ាហ្នឹង ដល់ពេលបានពាក់កណ្ដាលនេះហើយ ខ្ញុំមានរឿងមានរ៉ាវទៅក៏បែកគ្នាហ្នឹងទៅ ក៏មិនដឹងជាគេជញ្ជូនក្រោយមកទៀតប៉ុន្មាន អីប៉ុន្មានខ្ញុំអត់ដឹង។ ដឹងតែត្រឹមខ្ញុំនៅជាមួយគេបានប៉ុន្មានហ្នឹង។ ដល់ក្រោយទៀត ខ្ញុំអត់ដឹង ព្រោះខ្ញុំទៅនៅឯណោះហើយខ្ញុំផុត អត់មានដឹងរឿងអីទៀត។

**ស៖** តើខ្ញុំយល់យ៉ាងម៉េចដែរ គឺថា យល់ថា លោកត្រូវយល់យ៉ាងម៉េច ត្រូវយល់ថាលោកហ្នឹងមិនបានដឹងថាគេបញ្ជូនមនុស្សពីបូព៌ា ពីបស្ចិមមកទេ ឬក៏យ៉ាងណា?

**ឆ៖** ដឹងតែគេបញ្ជូនអាមុនដំបូងមកទេ អាលើកក្រោយទៀត ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំមានរឿងហើយ ពេលដែលខ្ញុំមកវិញ ក៏មិនបាននៅហ្នឹងដែរ អត់មានបានដឹងអីទៀតទេ។

[១៤:០១:៣៨]

**ស៖** ឥឡូវខ្ញុំចូលទៅនិយាយចំណុចមួយទៀត។ លោកបាននិយាយអំពី លក្ខខណ្ឌការងារនៅការដ្ឋាននោះ ហើយលោកបាននិយាយពីគ្រោះថ្នាក់ដែលកើតឡើងបន្ទាប់ពីមានការបំផ្ទុះថ្ម បំបែកថ្ម។

នៅក្នុងឯកសារ D166/194 គឺជាកំណត់ហេតុ កំណត់អត្តសញ្ញាណទីតាំង។ សាក្សីមួយបានបង្ហាញរូបថតមួយដែលក្នុងរូបថតនោះមានជញ្ជាំងបេតុង។ ERN ជាភាសាបារាំង 00368581, ERN ជាភាសាអង់គ្លេស (00)378445, ERN ជាភាសាខ្មែរគឺ 00384449។ សំណួរខ្ញុំដូចតទៅនេះ តើលោកមានចាំដែរឬទេ ថាមានជញ្ជាំងបេតុងដែលគេធ្វើនៅទីនោះ សាងសង់នៅលើការដ្ឋាននោះដើម្បីការពារកុំឲ្យមានគ្រោះថ្នាក់នៅពេលដែលគេដាក់គ្រឿងបំផ្ទុះ ផ្ទុះបំបែកថ្មទៅហ្នឹងកុំឲ្យមានគ្រោះថ្នាក់ដល់ពលករ។ លោកមានចាំទេ ថាមានគេសាងសង់ជញ្ជាំងបីហ្នឹង ធ្វើអំពីបេតុង?

**ឆ៖** គេធ្វើនៅជើងភ្នំមែន តែសម័យនោះធ្វើ ហៅថាធ្វើ តែដល់ពេលចុចទៅ អ្នកចុចវានៅឆ្ងាយជួនកាលរត់មិនទាន់ដល់អាជញ្ជាំងហ្នឹងផង វាស្ទានចេះតែទៅឆ្ងាយទៅៗ វាមាន ឆ្ងាយពីអាជញ្ជាំងហ្នឹងទៅ វាមានអាអំបែងហ្នឹង មានថ្ម មានអី ធ្លាក់មកវិញ។ ហ្នឹង វាធ្វើនៅជិតនេះ ជិតជញ្ជាំងជើងភ្នំ។

**សៈ** លោកក៏បាននិយាយផងដែរអំពីការធ្វើអត្តឃាតខ្លួននៅលើការដ្ឋានការងារ ដោយលោកនិយាយថាវាទាក់ទងទៅនឹងស្ត្រីទេ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកបានឃើញការធ្វើអត្តឃាតបែបនេះដោយផ្ទាល់ភ្នែក ឬក៏យ៉ាងណា?

**ឆ៖** ព្រោះខ្ញុំនៅឆ្ងាយពីកន្លែងហ្នឹងដែរ ស្រាប់តែដល់ពេលរៀបចេញឡានដឹកពួកចិនហ្នឹង ក៏គេប្រាប់ ឃើញឡានពេទ្យមកដឹកទៅ គេថា “នារីមួយហ្នឹង អាឡូកិនស្លាប់បាត់ហើយ គេកំពុងតែលើកដាក់ទៅឡានពេទ្យយកទៅ”។ អាហ្នឹងខ្ញុំឃើញពេលគេសែងទៅដាក់។ អត់មានបានឃើញជាន់នៅហ្នឹងទេ ព្រោះខ្ញុំធ្វើការឆ្ងាយពីហ្នឹងបន្តិចដែរ។ គ្រាន់តែដល់ពេលខ្ញុំដឹកភ្ញៀវចេញមក បានឃើញគេសែង ឃើញគេអី ដាក់ឡាន។

[១៤:០៥:០០]

**សៈ** តើហេតុ -- តើមានមូលហេតុអ្វីដែលអនុញ្ញាតឲ្យលោកទាញការសន្និដ្ឋានថា គាត់ហ្នឹងធ្វើអត្តឃាត ហើយមិនមែនជារឿងគ្រោះថ្នាក់ដោយចៃដន្យនោះទេនោះ?

**ឆ៖** មិត្តភក្តិហ្នឹងគេប្រាប់ថា ឃើញដើរចូល ឃើញអ៊ីចឹង គេប្រាប់អ៊ីចឹង។ មិត្តភក្តិអ្នកដែលធ្វើការនៅហ្នឹង ខ្ញុំសួរគេ ថាម៉េច! មូលហេតុអីៗអ៊ីចឹងទៅ គេប្រាប់ខ្ញុំអ៊ីចឹង។ វាមិនបានឃើញផ្ទាល់ដែលរត់ចូលអីខ្លួនឯង គឺអត់ទេ គ្រាន់តែអ្នកជិតខាងហ្នឹង ខ្ញុំសួរគេថាមូលហេតុអីៗ គេប្រាប់តាមហ្នឹង ព្រោះកន្លែងខ្ញុំនៅឆ្ងាយពីគេ ខ្ញុំបើកឡានមកដល់ហ្នឹងឃើញអ៊ីចឹងទៅ គេប្រាប់។

**សៈ** តើសហការីរបស់លោក ដែលនិយាយពីរឿងហ្នឹងប្រាប់លោកហ្នឹងឈ្មោះអ្វីដែរ?

**ឆ៖** អ្នកដែលប្រាប់ហ្នឹង ខ្ញុំមិនស្គាល់ឈ្មោះគេទេ ដែលអ្នកធ្វើការនៅជិតៗគ្នាហ្នឹង វា អង្គភាពៗហ្នឹងវាច្រើនគ្នា គ្រាន់តែសួរគេទៅ មិនបានស្គាល់ឈ្មោះគ្នាទេ។ គ្រាន់តែសួរអ៊ីចឹងទៅ តាមដែលឃើញឈរមើល អ្នកនេះហ្នឹង សួរគាត់ទៅ គាត់ប្រាប់ទៅ មិនអាចចាំឈ្មោះអស់ទេ មនុស្សវាច្រើនពេកតាម។

**ស៖** តើលោកដឹងថា អ្នកធ្វើការជាមួយលោកហ្នឹង ដែលនិយាយពីរឿងគ្រោះថ្នាក់ហ្នឹងគាត់នៅក្នុងអង្គភាពណាដែរឬទេ?

**ឆ៖** គាត់នៅក្នុងអង្គភាព៥០២ដែរ តែអង្គភាព៥០២ វាមានច្រើនផ្នែក វាច្រើនតាមក្រុម តាមកងតូចៗហ្នឹងទៀត។ ខ្ញុំមិនអាចស្គាល់អស់។

**ស៖** ក្រៅពីគ្រោះថ្នាក់មួយហ្នឹង ដែលអ្នកធ្វើការជាមួយលោកបានរៀបរាប់ប្រាប់នោះ តើលោកមានឮគេនិយាយអំពីគ្រោះថ្នាក់ដូចគ្នាអ៊ីចឹងដែរទេ ប្រភេទដូចគ្នាហ្នឹងនៅលើការដ្ឋានហ្នឹង។ ហើយបើសិនជាមាននោះ នៅ -- កើតឡើងនៅពេលណាដែរ។ សូមរៀបរាប់?

**ឆ៖** ច្រើនតែកើតឡើងពេលម៉ោងដប់ ម៉ោងដប់កន្លះ ម៉ោងអី អាហ្នឹងច្រើនមានជួបប្រទះហ្នឹងកើតហេតុ រឿងហេតុច្រើនៗតែពេលនុំងឯង ពេលម៉ោងដប់ ម៉ោងដប់កន្លះអីមាន ច្រើនតែឃើញឡានពេទ្យមកបន្តបន្ទាប់ដឹកអីហ្នឹង ឃើញអាពេលហ្នឹងឯងម៉ោងចន្លោះពេលម៉ោងដប់ ដប់កន្លះ។

[១៤:០៨:២៩]

**ស៖** បញ្ជាក់សំណួរខ្ញុំឡើងវិញម្តងទៀត។ លោកបាននិយាយអំពីការធ្វើអត្តឃាតនៅលើការដ្ឋានហ្នឹង ហើយអម្បាញ់មិញនេះលោកបានថាមានករណីមួយ លោកមិនបានឃើញដោយផ្ទាល់ទេ គឺអ្នកធ្វើការជាមួយលោកបានប្រាប់លោក។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកមានធ្លាប់ឮគេប្រាប់លោក ឮគេនិយាយអំពីអត្តឃាតផ្សេងទៀតដែរឬទេ? ខ្ញុំ ពេលដែលសួរអម្បាញ់មិញថានៅពេលណានោះ ខ្ញុំមិនមែនចង់សំដៅលើពេលណាក្នុងថ្ងៃ ដប់ពីរម៉ោង ម៉ោងប៉ុន្មានៗនោះទេ ខ្ញុំសំដៅទៅលើរយៈពេលថាចន្លោះពី៧៥ ដល់ ៧៩ ហ្នឹង គឺថានៅពេលណាដែរ ហើយគឺធៀបនឹងពេលដែលលោកធ្វើការនៅលើការដ្ឋានហ្នឹងដែលៗធៀបទៅពេលលោកចូលធ្វើការហ្នឹង តើរឿងករណីបែបហ្នឹងកើតឡើងនៅពេលណា?

**ឆ៖** ក្នុងពេលឆ្នាំ៧៦ ច្រើនក្នុងពេលឆ្នាំ៧៦ ចុងឆ្នាំ៧៦ ហ្នឹងច្រើន។

**ស៖** ពេលលោកនិយាយអំពីពាក្យថា "គ្រោះថ្នាក់"ហ្នឹង តើលោកសំដៅទៅលើអត្តឃាតដែរឬក៏យ៉ាងម៉េច? ខ្ញុំសួរលោកនេះដើម្បីចង់ដឹងថា តើលោកឮគេនិយាយពីករណីអត្តឃាតហ្នឹងប៉ុន្មានដែរ?

**ឆ៖** អត្តឃាតប៉ុន្មានដងអ៊ីចឹង? ខ្ញុំអត់យល់ដែរ។ សួរប៉ុន្មានដែរ ខ្ញុំអត់យល់។

[១៤:១០:២៤]

**ស៖** បើតាមខ្ញុំយល់ពីចម្លើយរបស់លោកហ្នឹង គឺលោកនិយាយថាមានការធ្វើអត្តឃាតហ្នឹងញឹកញាប់។ អ៊ីចឹង តែដល់ពេលលោកផ្តល់ឧទាហរណ៍ឲ្យខ្ញុំតែមួយអ៊ីចឹង តែករណីតែមួយអ៊ីចឹង។ ខ្ញុំសួរលោកថា តើមានប៉ុន្មានករណីអត្តឃាតពេលដែលលោកធ្វើការនៅការដ្ឋានហ្នឹង?

**ឆ៖** វាឮថាច្រើនដងដែរ មិនមែនតែម្តងហ្នឹងតែមួយថ្ងៃហ្នឹងទេគឺច្រើនដងដែរ តែចាំមិនបានទេ វាញឹកញាប់ដែរ ឃើញថាញឹកញាប់ ស្លាប់ របួស គឺញឹកញាប់ដែរ។ នៅក្នុងធ្វើការហ្នឹងវាមិនទៀងទាត់ មួយថ្ងៃវាជួនកាលក៏មានរបួសពីរបីដងអ៊ីចឹង ពីរបីនាក់អ៊ីចឹងទៅ វាអត់ទៀងទាត់ទេ។ ដែលខ្ញុំធ្លាប់ឃើញ ធ្លាប់នៅហ្នឹងធ្វើការនៅកន្លែងហ្នឹង ជួនកាលវាឃើញថាបាក់ដើមឈើទៅ ប៉ះទៅ របួសទៅ ស្លាប់ទៅ អាហ្នឹងវា --

**ស៖** លោកសាក្សី ខ្ញុំមិននិយាយអំពីគ្រោះថ្នាក់ក្នុងការងារនោះទេ។ សំណួរខ្ញុំច្បាស់ជាងហ្នឹង។ លោកបាននិយាយថាមានអត្តឃាតញឹកញាប់។ អ៊ីចឹង ខ្ញុំចង់សួរលោកថាតើអ្នកដែលនិយាយប្រាប់លោកនោះ ដែលលោកមិនស្គាល់ឈ្មោះនោះ តើតាមរយៈគាត់ហ្នឹង លោកមានឮគេនិយាយអំពីអត្តឃាតផ្សេងទៀតទេ មានករណីអត្តឃាតផ្សេងទៀតទេនៅការដ្ឋានព្រលានយន្តហោះហ្នឹង? ខ្ញុំមិននិយាយពីគ្រោះថ្នាក់ក្នុងការងារទេ។

[១៤:១២:១៩]

**ឆ៖** ក្នុងការងារហ្នឹងដែលធ្វើអត្តឃាត ច្រើនតែ នៅកន្លែងហ្នឹង ច្រើនតែខាងនារី នារីច្រើន។ ព្រោះយុវជនអត់សូវមានប៉ុន្មានទេ ច្រើននារីដែលធ្វើអត្តឃាត ព្រោះនារីច្រើនតែនៅតាមផ្លូវ ដែលធ្វើផ្លូវ ធ្វើអី ចាក់បេតុងបេអីហ្នឹង វាច្រើន។ ហើយធ្វើអត្តឃាតហ្នឹង វាច្រើនតែខាងនារីទេ ខាងបុរស វាមានភាគតិចណាស់។

**ស៖** លោកសាក្សី ខ្ញុំចង់បានចម្លើយច្បាស់លាស់ជាងហ្នឹង ព្រោះលោកនិយាយថាគេប្រាប់លោកហ្នឹងកើតឡើងញឹកញាប់។ ហើយអ៊ីចឹងខ្ញុំសួរលោកថាអ្នកណាជាអ្នកប្រាប់លោក ហើយកើតឡើងនៅពេលណាដែរ បើសិនជាលោកចាំ? អ្នកណាអ្នកប្រាប់លោក ហើយនៅពេលណា? រឿងហ្នឹងកើតឡើងនៅពេលណា?

**ឆ៖** ច្រើនកើតនៅចុងឆ្នាំ៧៦ និងពាក់កណ្តាលឆ្នាំហ្នឹង ព្រោះឆ្នាំហ្នឹងច្រើនធ្វើតែនេះទេ ខាងកងនារីធ្វើផ្លូវ ហើយនិងចាក់បេតុងចាក់អីហ្នឹង មានមិត្តម្នាក់ដែលគាត់ដើរតាមហ្នឹង ច្រើនតែនាំនារីធ្វើ

ហ្នឹង តែឥឡូវគាត់ស្លាប់បាត់ហើយ ឈ្មោះ បើឈ្មោះគេហៅនៅហ្នឹង កាលហ្នឹងគេហៅ អាក្អុត១ ហ្នឹង គាត់ច្រើនតែនិយាយប្រាប់ខ្ញុំ ឲ្យតែមកដល់កន្លែងថា "មួយទៀតហើយអ្ហា! មិនដឹងយ៉ាងម៉េចទេ ភ្លាត់ជើងមិនដឹងធ្វើម៉េចមិនដឹងទេ វាអត្តឃាតហើយ សម្លាប់ខ្លួនឯងបាត់ទៀតហើយ នារី" មានបានតែប្រាប់តែអ៊ីចឹង។ ឲ្យតែមានការស្លាប់អីគាត់ប្រាប់។ ដល់ឥឡូវគាត់ស្លាប់ដែរអស់ហើយ អត់មានសល់ទេ។

**ស៖** ហើយតាឃុត ហ្នឹងគាត់ធ្វើការនៅអង្គភាពណាដែរ នៅព្រលានយន្តហោះហ្នឹង?

[១៤:១៤:៣៧]

**ឆ៖** គាត់នៅហ្នឹងគាត់ គេហៅកងការពារ ខាងកងការពារគេ។ គាតដើរត្រួតពិនិត្យតាមគ្រប់កន្លែងដូចថា កន្លែងធ្វើការនៅឯណាអ៊ីចឹងទៅ គាត់ដើរមើលគេមើលឯងហ្នឹង ទៅតាមហ្នឹងឯង។ គេហៅកងការពារគេ សម្រាប់មើលទាហាន ហើយនិងក្រុមការងារផ្សេងៗហ្នឹង ដូចថាគេឲ្យទៅជាមួយចិនហ្នឹង ចិនទៅហ្នឹង គាត់ហ្នឹងទៅតាមចិនហ្នឹង។ ចិនគេឲ្យធ្វើអីៗហ្នឹង គាត់ដើរទៅកងការពារចិនហ្នឹង។ ដើរទៅឃើញ។

**ស៖** ហើយ តាឃុត ហ្នឹងគាត់ធ្វើការនៅក្រោមការបង្គាប់បញ្ជារបស់អ្នកណាដែរ?

**ឆ៖** គាត់នៅក្នុង៥០២ហ្នឹងដែរ តែគាត់នៅកងការពារ តាមកងការពារចិន នៅនឹង៥០២ហ្នឹង។ កងគាត់ហ្នឹងវាមានមួយក្រុមហ្នឹងសម្រាប់ដើរតាមចិនទៅ មួយកន្លែង ដូចថាឡានហ្នឹងទៅបែកគ្នា ឡានដឹកចិនទៅ។ ឡានមួយហ្នឹងមានគ្នាគាត់ ជូនកាលចិនច្រើន ទៅពីរនាក់។ ចិនតិចទៅតែម្នាក់អ៊ីចឹងទៅ។ អាហ្នឹងគ្នាគាត់ខាងកងការពារ។

**ស៖** លោកសាក្សី ខ្ញុំសូមអរគុណដែលឆ្លើយបានលម្អិតនោះ ព្រោះខ្ញុំ -- សំណួរខ្ញុំចង់បានចម្លើយលម្អិតច្បាស់លាស់។ អ៊ីចឹងសូមលោកឆ្លើយឲ្យត្រង់ៗហ្នឹងសំណួរ ឲ្យចំហ្នឹងសំណួរតែម្តង។ ខ្ញុំចង់សួរថា មេផ្ទាល់របស់ តាឃុត ហ្នឹង ឈ្មោះអីដែរ ព្រោះពេលវេលាខ្ញុំនោះជិតអស់ហើយ។ អ៊ីចឹងសូមលោកឆ្លើយឲ្យចំៗហ្នឹងសំណួរតែម្តង។

[១៤:១៦:៣៦]

**ឆ៖** ខ្ញុំឆ្លើយឲ្យចំម្តង មេដែលចេញពីហ្នឹងមក គឺមកពី តាល្វៃ, តាម៉េតហ្នឹង តែមួយទេ មេតែមួយហ្នឹងឯង ពីរនាក់ហ្នឹង។ ហើយកូនចៅហ្នឹងដែលគាត់ទៅបែងចែក ដូចថាឲ្យកងការពារហ្នឹង មានប៉ុន្មាននាក់ៗ សម្រាប់ទៅតាមឡានមួយៗដែលដឹកចិនហ្នឹងឯង។

**ស៖** ឥឡូវ ខ្ញុំសូមចូលទៅនិយាយពីចំណុចមួយទៀត គឺទាក់ទងនឹងថ្នាក់ដឹកនាំដែលត្រូវធ្វើ

ទស្សនកិច្ចនៅការដ្ឋានហ្នឹង។ ម្សិលមិញហ្នឹង សហព្រះរាជអាជ្ញាពេលនិយាយថា នៅពេលដែលដឹងថា ខៀវ សំផន, អៀង សារី ទៅដល់កន្លែងហ្នឹង រូបលោកផ្ទាល់នោះ លោកមិនបានឃើញគាត់ទាំងពីរនោះទេ ព្រោះថាលោកនៅឆ្ងាយ ហើយមានមនុស្សនៅពីមុខគាត់ច្រើន ក៏ប៉ុន្តែលោកដឹងថាគាត់ទាំងពីរនាក់ហ្នឹងនៅទីនោះ តាមរយៈអ្នកនៅទីនោះគេឃើញ។ អ៊ីចឹងលោកអាចជម្រាបជូនតុលាការបានដែរទេ ថាតើអ្នកដែលឃើញ ខៀវ សំផន និង អៀង សារី នៅទីនោះៗ ឈ្មោះអ្វីដែរ?

**ឆ៖** ជំនាន់ហ្នឹងបាត់ខ្លួនអស់ សព្វថ្ងៃហ្នឹងវាភ្លេចអស់ហើយ ភ្លេចឈ្មោះ ព្រោះអ្នកធ្វើការជាមួយខ្ញុំហ្នឹងវា រកចងចាំមិនបាន វាផ្លាស់ប្តូររហូត ដល់ហើយអត់មាន។ មានតែអ្នក ដូចដែលខ្ញុំប្រាប់អ៊ីចឹង ដែលអ្នកកងការពារចិនអ៊ីចឹង ទៅអ៊ីចឹងទៅ នៅជិតខ្ញុំអី គេប្រាប់អ៊ីចឹងទៅ អ្នកនេះអ្នកនោះអ៊ីចឹងទៅ។ ខ្ញុំនៅអត់ហ៊ានដើរចោលពីឡានឆ្ងាយអីទេ ខ្លាចមានការណ៍ទៅ គេរកមិនទាន់ រកមិនឃើញអ៊ីចឹងទៅ។ ចាំឈ្មោះមិនអស់ទេ ខ្ញុំភ្លេចអស់ហើយ។

[១៤:១៨:៤៧]

**ស៖** បើអ៊ីចឹងអ្វីដែលលោកនិយាយហ្នឹង គឺថាពត៌មានដែលលោកទទួលបាននេះ ដឹងថាមាន ខៀវ សំផន, អៀង សារី ហ្នឹង គឺដោយអ្នកយាម អ្នកប្រាប់លោកទេ ឬក៏យ៉ាងម៉េច?

**ឆ៖** អ្នកកងការពារហ្នឹងឯងដែលគេបានដើរតាមចិន តាមអីឆ្ងាយអ៊ីចឹងទៅ ពីឡានអីទៅ គេដឹងទៅ ខ្ញុំសួរគេទៅ គេប្រាប់អ្នកនេះអ្នកនោះមកអ៊ីចឹងទៅ។ អាហ្នឹងគេ បានតែសួរតាមគេអ៊ីចឹងឯង ព្រោះខ្ញុំមិនហ៊ានដើរចោលឡានឆ្ងាយទេ មានតែអ្នកកងការពារហ្នឹងឯងដែលគេដើរទៅ។

**ស៖** លោកដូចជានិយាយថាមានក្បួនឡាន។ តើលោកមានបានឃើញក្បួនឡានហ្នឹងទេ? ហើយក្បួនឡានហ្នឹង ទៅចតនៅកន្លែងណាដែរ នៅលើការដ្ឋានហ្នឹង?

**ឆ៖** ពេលអ្នកធំគេមក ខ្ញុំឃើញគេចូលទៅតាមអាផ្លូវធំហ្នឹង គេហៅថាផ្ទះ អាកន្លែងផ្ទះទីបញ្ជាការហ្នឹង កន្លែងផ្ទះទីបញ្ជាការដែលចិនដំឡើង ដែលចិនធ្វើថ្មីហ្នឹង ឃើញតែឈប់នៅមុខហ្នឹងឯង ច្រើនតែចូលទៅឈប់នៅមុខហ្នឹង។ ទៅសម្រាកហ្នឹង ឃើញអែអង់នៅហ្នឹងហើយ ដែលខ្ញុំ ពួកខ្ញុំមិនដែលបានទៅនៅជិតហ្នឹងទេ នៅឆ្ងាយណាស់ គេមិនឲ្យទៅជិតកន្លែងគេទេ។ ឡានអីមកចតនៅផ្លូវធំនេះ ដល់តែមានការណ៍ បានគេហៅប្រាប់ទៅ ទៅយកគេ។ តែមានអ្នកធំចូលអីហ្នឹង គេមិនឲ្យទៅជិតទេ។

**ស៖** លោកនិយាយថា "ជាទូទៅនៅពេលដែលមានអ្នកធំមកនោះ" លោកចង់និយាយថាម៉េច គឺសំដៅថា មានអ្នកមេដឹកនាំធំៗហ្នឹងមកធ្វើទស្សនកិច្ចញឹកញាប់នៅទីហ្នឹង ឬក៏យ៉ាងម៉េច?

[១៤:២១:១៧]

**ធ៖** មកពេលណាខ្ញុំនៅ អាហ្នឹងឃើញអ៊ីចឹងដែរទៅ។ ខ្ញុំទៅឆ្ងាយៗអ៊ីចឹងទៅ ក៏មិនសូវដឹងទេ។ គ្រាន់តែខ្ញុំនៅហ្នឹង ក៏ឃើញដែលតាំងពីខ្ញុំចុះមកធ្វើការនៅហ្នឹង ខ្ញុំឃើញតែបីដងពិតប្រាកដ តែឃើញហ្នឹង មិនបានឃើញជិតទេ ឃើញតែមកបីដង។ មិនដែលបានឃើញជិតនឹងគេទេ ដែលគេចុះមកហ្នឹង ហើយមិនដែលស្គាល់ថា អូ្ហ! លោកណា លោកណី អត់ដែលស្គាល់ លោកធំហ្នឹងគេមិនដែលស្គាល់ទេ។ អស់ស្គាល់ត្រឹមកងអង្គភាពខ្លួនឯងហ្នឹងមក ហើយនេះហ្នឹងបានស្គាល់ បើថាអ្នកធំ អ្នកអីអត់ដែលស្គាល់ទេ។ ស្គាល់តែ ដូចថាចិនណាធ្លាប់ខ្ញុំទៅដឹកហ្នឹង ស្គាល់តែចិនហ្នឹងឯង។

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេ ថានៅថ្ងៃទស្សនកិច្ចរបស់មេដឹកនាំទាំងពីរនាក់នោះ គឺជាថ្ងៃដែលគេធ្វើធម្មតា ឬក៏មិនមានពលករណាធ្វើការនៅលើការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងទេ ថ្ងៃដែលគាត់ចុះទៅធ្វើទស្សនកិច្ចហ្នឹង?

**ធ៖** ពេលគាត់ចុះទៅ មានតែអ្នកធ្វើឆ្ងាយៗពីកន្លែងហ្នឹង អាកន្លែងដែលជិតហ្នឹងអត់មានទេ។ មានមកធ្វើនៅចុងព្រលាន មានធ្វើនៅឯណោះ កន្លែងគេហៅថា ប្រឡាយនេះណោះ អត់សូវមាននៅជិតហ្នឹងទេ ដែលគេចុះមកហ្នឹង អត់សូវមាន។ ក្បែរៗហ្នឹងអត់មានទេ ស្ងាត់។

**ស៖** តើលោកដឹងថាអ្នកណាជាអគ្គមេបញ្ជា -- នាយសេនាធិការនៅសម័យហ្នឹងដែរឬទេ?

**ធ៖** សុំម្តងទៀតស្តាប់អត់បាន។

[១៤:២៣:៤៨]

**ស៖** តើលោកដឹងទេថា នៅសម័យហ្នឹងអ្នកណាជានាយសេនាធិការនៃកងទ័ពទូទាំងប្រទេសតែម្តង? លោកដឹងថា អ្នកណាជានាយសេនាធិការដែរឬទេ?

**ធ៖** អត់ អត់ដឹងសោះ អត់មានដឹង ដឹងតែអង្គភាពខ្លួនឯង។

**ស៖** ឥឡូវខ្ញុំសូមចូលទៅនិយាយអំពីការចាប់ខ្លួនរបស់លោក។ ខ្ញុំនឹងនិយាយសង្ខេបឡើងវិញ។ នៅក្នុងចម្លើយរបស់លោក គឺឯកសារ E3/5278, ERN ជាភាសាបារាំងគឺ 00355867, ERN ជាភាសាខ្មែរគឺ 00287530, ERN ជាភាសាអង់គ្លេសគឺ 00292825។ លោកបានឆ្លើយដូចតទៅនេះ៖ "គេបានចាប់ខ្ញុំ ពីព្រោះខ្ញុំឈ្លោះជាមួយឈ្មោះ យ៉េង រឿងដឹកអង្ករឲ្យពួកបូព៌ាហូប ដែលគេចោទថាខ្ញុំហ្នឹងដឹកអង្ករឲ្យខ្មាំង។ យ៉េង បាននិយាយថា "អ្អែងដឹកអង្ករឲ្យខ្មាំងស៊ីច្រើនម្ល៉េះ" ហើយក្រោយមកពេលខ្ញុំដឹកឈើចំនួន១០ឡាន ពីក្រាំងស្គារ ប្រហែលជានៅកំពង់ឆ្នាំង ដាក់ព្រលានការដ្ឋានកំពង់ឆ្នាំងហ្នឹង

នៅវេលាម៉ោងមួយរសៀល ក៏មានកងការពាររបស់ យ៉េង ហ្នឹងមកចាប់ខ្ញុំយកទៅប្រជុំនៅវត្តព្រះធាតុ ហើយនៅខាងកើតព្រលានយន្តហោះ ហើយទៅដល់ គេក៏ដឹកតាមឡានទៅដាក់វត្តនោះ ហើយពេលទៅដល់ទីនោះ គេក៏ឲ្យខ្ញុំចូលទៅវិហារ ហើយគេចាប់ខ្ញុំចងស្លាបសេកនឹងក្រមានឹងខ្សែអង្រឹង ហើយចងមុខនិងដាក់ក្រណាត់ខ្មៅ រួចបោះចូលទៅក្នុងឡានហ្ស៊ីបចិន"។ តើខ្ញុំត្រូវយល់យ៉ាងម៉េចដែរ? ខ្ញុំត្រូវយល់ថាគេចាប់ខ្លួនលោកនេះ គឺចាប់លោកនៅពេលដែល -- នៅថ្ងៃដែលលោកនិយាយជាមួយ យ៉េង ផ្ទាល់តែម្តងថ្ងៃហ្នឹងតែម្តង ទាស់សម្តីគ្នាជាមួយគ្នាគាត់ថ្ងៃហ្នឹងតែម្តង ឬក៏ពេលក្រោយមកទេ?

[១៤:២៦:២២]

**ឆ៖** ពេលក្រោយៗបីថ្ងៃ។ ខ្ញុំទៅ ខ្ញុំដឹកអង្ករ ដឹកអីដល់នោះហើយ បានដេកឯណោះបានពីរយប់ៗបានដឹកឈើមកវិញ មកដល់កន្លែងឯណេះវិញ។ ខ្ញុំរាប់ឈើ រាប់អីហើយ រឿងឈើដឹកមុន ដឹកអីហ្នឹងខ្ញុំធ្វើរបាយកាណ៍ប្រាប់គេ កុំឲ្យគេថាដឹកមកប៉ុន្មាន នៅប៉ុន្មាន ហើយធ្វើបានប៉ុន្មានហ្នឹង ខ្ញុំធ្វើអាហ្នឹងឲ្យគេទៅ។ ដល់ថ្ងៃហ្នឹងឯង ម៉ោងមួយ ពីរ ហ្នឹងគេមកហៅទៅប្រជុំតែហ្នឹងតែម្តង។

**ស៖** លោកបានឆ្លើយថា គឺកងសន្តិសុខ យ៉េង ហ្នឹងដែលមកជួបលោក។ អ៊ីចឹងលោកអាចប្រាប់ឈ្មោះគាត់បានទេ លោកចាំឈ្មោះគាត់ទេ ដែលកងការពារ កងសន្តិសុខរបស់ យ៉េង ហ្នឹង?

**ឆ៖** កងសន្តិសុខហ្នឹង គឺមិនរបស់តែ យ៉េង គឺមិនដឹងមកពីណាមក ខ្ញុំអត់ដឹង អត់ដែលស្គាល់ទេព្រោះគេហៅថាពួកតម្រួតហ្នឹង តម្រួតហ្នឹងគឺមិនដឹងគេយកពីណាមក ខ្ញុំមិនដែលស្គាល់ទេ តម្រួតហ្នឹងដែលទៅហៅហ្នឹង គេៗដឹងថានេះហ្នឹង គេទៅប្រាប់អ៊ីចឹងទៅ គេថាឲ្យទៅប្រជុំនោះ ដឹង។ គ្រាន់តែប្រាប់ប៉ុណ្ណឹង ទៅជួបជុំគ្នាប្រជុំនៅនឹងវត្តហ្នឹងឯង។

**ស៖** អម្បាញ់មិញនេះ ដូចខ្ញុំអាន ឃើញខ្ញុំអានស្រាប់ហើយថា ឃើញអានអំមិញនេះ គឺថាគឺកងការពារ យ៉េង ហ្នឹងហើយដែលប្រាប់ឲ្យលោកទៅប្រជុំនៅវត្ត។ អ៊ីចឹងចង់ -- លោកសំដៅថាអ្នកកងការពារ យ៉េង ហ្នឹងដែលធ្វើការនៅលើការដ្ឋានព្រលានយន្តហោះហ្នឹងដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំចេញមកនៅអ៊ីចឹងហើយ វាមិនដឹងថាកងការពារហ្នឹងវានៅជាមួយ តាយ៉េង ហ្នឹង ឬនៅជាមួយអ្នកណាគេ គឺខ្ញុំអត់ដឹងទេ។ ស្រាប់តែដឹងតែពេលគេទៅហៅហ្នឹង មិនដឹងថាកងការពារហ្នឹងមកពីខាងណាៗ អត់ដឹងទេ ព្រោះខ្ញុំអត់ដែលស្គាល់មុខដែលអ្នកទៅហៅហ្នឹង អត់ដែលស្គាល់មុខទេ វាក្មេងៗនោះ។

[១៤:២៨:០៨]

**ស៖** អ៊ីចឹងហេតុអ្វីក៏លោកនិយាយនៅក្នុងចម្លើយរបស់លោកហ្នឹង លោកនិយាយថា គឺកងការពាររបស់ យ៉េង ជាអ្នកដែលមកហៅលោកហ្នឹង?

**ឆ៖** ព្រោះខ្ញុំសំដៅលើហ្នឹង សំដៅថា រឿងហ្នឹងជារឿងដែលខ្ញុំនិយាយលេងជាមួយគេហ្នឹងឯង។ ដល់និយាយលេងទៅ ដល់វាប៉ះពាល់លើគេអ៊ីចឹងទៅ ហើយគេយកពួកអាហ្នឹងមកហ្នឹង ព្រោះកងការពារហ្នឹងវា ខ្ញុំវាមិនដែលដឹងថាគេចេញមកពីច្រកណាៗ គឺអត់ដឹងទេ កងការពារហ្នឹង មិនដឹងហ្នួង។ ពេលមកហ្នឹង មកដល់គេហៅទៅហ្នឹង មិនដឹងគេ គ្រាន់តែដើរប្រាប់។ អ្នកប្រាប់ ដើរៗប្រាប់មក ប្រជុំទៅប្រជុំ ឬទៅអីហ្នឹង អាហ្នឹងគេប្រាប់តាមតេអូតេអីមក ហៅប្រជុំអីហ្នឹង គេហៅតាមតេអូអីហ្នឹង។ ដល់ថ្ងៃហ្នឹង គេថាហៅទៅប្រជុំហ្នឹង មានអ្នកទៅហៅហ្នឹង វាមិនដឹងថាកងណាៗ អាហ្នឹងអត់ដឹងដែរ។ ចុះវាកងការពារ វានៅក្រោយៗមក វាចេះតែ គេដាក់តាមដំណើររបស់គេ ខ្ញុំអត់ដឹងដែរ។

**ស៖** ខ្ញុំមិនសុំឱ្យលោកនិយាយលម្អិត ទាក់ទងនឹងព័ត៌មានដែលលោកបានផ្តល់កាលពីព្រឹកមិញ ពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃការដកខ្លួន ឬក៏ការចាប់ខ្លួនលោកនោះទេ។ ខ្ញុំយល់តាមរយៈចម្លើយរបស់លោក ថាលោកបានទៅដល់កន្លែងមួយដែលលោកមិនស្គាល់នៅពេលយប់ ហើយក៏ប៉ុន្តែដោយសំណាងល្អលោកជួបយោធាម្នាក់ដែលធ្លាប់ធ្វើការជាមួយលោកមុនឆ្នាំ១៩៧៥ គឺឈ្មោះ ម៉ៅ ដែលគាត់ហ្នឹងឯងពេលភ្លាមៗនោះ គាត់បានលាក់លោកនៅក្នុងបង្គន់ ហើយគាត់ឱ្យផែនទីមួយមកលោក ដើម្បីឱ្យលោករត់គេចខ្លួនពីគុកទួលស្លែង។ សំណួររបស់ខ្ញុំគឺចង់ដឹងថា តើគឺជាផែនទីហ្នឹង ជាផែនទីដែលគាត់គូរដោយខ្លួនឯង ឬក៏ជាផែនទីមានតាំងពីណាពីណីមកហើយ ផែនទីមានស្រាប់?

[១៤:៣១:៤៧]

**ឆ៖** គាត់គូរហ្នឹងនេះតែម្តង គូរនឹងក្រដាសយើងធម្មតា ក្រដាសសៀវភៅធម្មតា។ គូរនឹងដៃខ្មៅទៀត អត់មានប៊ិកទេ គូរនឹងដៃខ្មៅ ហើយគាត់សរសេរប្រាប់ដាក់នៅហ្នឹងឯង។ កន្លែងនេះៗហ្នឹង គាត់ដាក់នៅហ្នឹង។ ទៅដល់កន្លែងនេះ មានផ្លូវបែកទៅណេះៗ គាត់ដាក់តាមហ្នឹងឯង។ គឺអត់មានប៊ិកគូរទេ គឺគូរនឹងខ្មៅដៃ ក្រដាសហ្នឹង ក្រដាសសៀវភៅយើងធម្មតា។ ហើយមកដាក់ដល់ផ្ទះ មកដល់ស្ពានជ្រោយចង្វាហ្នឹង ដាក់ប៉ុន្មានម៉ែត្រៗ ចម្ងាយប៉ុន្មានៗ គឺគូរតាមហ្នឹងឯង អត់មាននេះទេ គូរក្រដាសហ្នឹងឯង។ ក្រដាសមិនបានប៉ុនបាតដៃផង គាត់គូរមក។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំឃើញថាឥឡូវនេះ ម៉ោងពីរកន្លះហើយ។ ខ្ញុំសួរជិតចប់ហើយ ក៏ប៉ុន្តែខ្ញុំត្រូវនៅ

សល់ប្រធានបទមួយនឹងត្រូវបញ្ចប់ ហើយនិងមានចំណុចមួយទៀត ដែលទាក់ទងទៅនឹង ល្វៃ ហើយនិង ម៉េត។ ហើយលោកមេធាវី គង់ សំអុន ក៏មានសំណួរត្រូវសួរដែរ គឺគាត់ត្រូវការពេលប្រហែលជាប្អូនដប់នាទីអីប៉ុណ្ណោះ។ អ៊ីចឹង ខ្ញុំសួរលោកប្រធាន ថាតើលោកប្រធានអាចបន្ថែមពេលវេលាឲ្យក្រុមយើងខ្ញុំ ១០នាទីអីទៀតបានដែរឬទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឈ្មោះ ម៉ៅ ដែលពេលនោះ ដោយសំណាងល្អ គាត់ផ្តល់ប្លង់ហ្នឹងឲ្យលោក ឲ្យទៅផ្ទះតាវិន ដែលជាកូនប្រសារបស់ តាម៉ុក។ ហើយលោកបាននិយាយថា គាត់ហ្នឹងហើយជាអ្នកទាក់ទងជាមួយមេរបស់លោកគឺឈ្មោះ ល្វៃ ហើយនិងឈ្មោះ ម៉េត។ អ៊ីចឹង សំណួរខ្ញុំចង់ដឹងថា -- សំណួរទី១ ព្រោះនៅក្នុងចម្លើយរបស់លោកស្រីនោះ លោកនិយាយថា "តាវិន ហ្នឹង ជាមេបញ្ជាការកងពលតូចថ្មើរជើង"។ អ៊ីចឹង ខ្ញុំសួរលោកថា តើគាត់ហ្នឹងនៅក្នុងកងពលធំលេខប៉ុន្មានដែរ? គាត់កងពលលេខ២។ អ៊ីចឹងសួរថា កងពលលេខ២ហ្នឹង នៅក្នុងកងពលធំលេខប៉ុន្មាន?

[១៤:៣៤:៤៦]

**លោក ចាន់ ម៉ន៖**

**ឆ៖** ខ្ញុំមិនបានដឹងដែរ កងពលធំរបស់គាត់មិនដឹងលេខប៉ុន្មាន អីប៉ុន្មានទេ តែកាលនៅសង្គ្រាមនៅឡើយ វើជាប់ៗតែគ្នា នៅជាប់ៗតែគ្នាហ្នឹង ខ្ញុំមិនដឹងថាកងពលធំ ចំណុះកងពលតូចរបស់គាត់ហ្នឹង ចំណុះកងពលធំណា ខ្ញុំអត់ដឹងទេ។ តែដល់ពេលហ្នឹងៗ គ្រាន់ថាវាធ្លាប់ដូចថា ម៉ៅ ហ្នឹងវាធ្លាប់រស់នៅជាមួយ បងវិន ហ្នឹងទៅ ហើយវាហ្នឹងធ្លាប់ទាក់ទងជាមួយខ្ញុំហ្នឹង ហៅគ្នាទៅវិញទៅមក ដើរអី ដូចថានៅនីរសារន៉ុង ទាក់ទងគ្នា និយាយគ្នាទៅរាប់អានគ្នាអ៊ីចឹងតាំងពីនៅតូចៗដូចគ្នាហ្នឹងរហូតមកទាល់តែចូលភ្នំពេញក៏បានជួបគ្នាពីរបីដង--

**ស៖** លោកសាក្សីខ្ញុំសូមកាត់លោក។ សំណួរខ្ញុំអម្បាញ់មិញនេះ សួរទាក់ទង តាវិន ទេ។ អ៊ីចឹង សូមឲ្យលោកឆ្លើយឲ្យចំៗសំណួរ។ អ៊ីចឹងលោកបានឆ្លើយថា -- នៅក្នុងចម្លើយរបស់លោកនោះគឺ ERN

ជាភាសាបារាំងហ្នឹង 00355868, ជាភាសាអង់គ្លេសគឺ 00292826, ជាភាសាខ្មែរគឺ 00287531-32។ លោកបាននិយាយដូចតទៅនេះ "តើគេតេអូទៅ ល្វៃ ហើយបន្ទាប់មកទៀត ល្វៃ ហើយនិង ម៉េត ហ្នឹងដែលជាមេទាហានកងអាកាស ក៏ជិះកន្ទុំរុយមកពីកំពង់សោមមកជួបលោក គេក៏បានសម្រេចជួយលោក ដោយឲ្យលោកទៅធ្វើការនៅផ្នែកវ៉ាដានៅកំពង់ឆ្នាំង"។ អ៊ីចឹងគឺ ល្វៃ ជាមេបញ្ជាការរង ហើយមាន ម៉េត ជាមេបញ្ជាការធំនុ៎ង បានជិះយន្តហោះពី -- ជិះឧទ្ធម្ភាគចក្រពីកំពង់សោម មកជួបលោកនៅពោធិ៍ចិនតុង ហើយលោកហ្នឹងគ្រាន់តែជានីរសារកំប៉ិកំប៉ុកប៉ុណ្ណោះទេ។ តើខ្ញុំត្រូវយល់ថាអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១៤:៣៧:២៤]

**ឆ៖** គាត់ពីដើមមក តាំងពីខ្ញុំនៅនីរសារតូចៗហ្នឹង គាត់ ដូចថាខ្ញុំមិនដែលធ្វើអីឲ្យខុសឆ្គងស្អីទេ ហើយមួយទៀតគាត់ចូលចិត្តខ្ញុំ ធ្វើ ដូចថាម្ហូបអី ធ្វើលឿនពេលហូបពេលអីហ្នឹង មានតែខ្ញុំទេអ្នកធ្វើម្ហូបយកទៅឲ្យយក ទៅអីអ៊ីចឹងទៅ។ តាំងពីខ្ញុំនៅតូចៗម្ល៉េះ ចេះតែ -- ហើយគាត់ស្រឡាញ់ខ្ញុំ ហើយខ្ញុំមិនដែលធ្វើបាបអ្នកណាទេ។ ជំនាន់នុ៎ង គឺខ្ញុំ--

**ស៖** សូមទោស លោកសាក្សីលោកកំពុងតែនិយាយអំពីអ្នកណាដែរឥឡូវនេះ?

**ឆ៖** គាត់សួរខ្ញុំពីរឿង ម៉េត ខ្ញុំឆ្លើយពីរឿង ម៉េត ហ្នឹង។

**ស៖** អ៊ីចឹងដោយសារតែលោកហ្នឹងពូកែធ្វើម្ហូបហ្នឹងហើយ បានជាគាត់ជិះយន្តហោះមក -- ជិះឧទ្ធម្ភាគចក្រមកជួបលោកហ្នឹង។ ក៏ប៉ុន្តែអ្វីដែលខ្ញុំមិនសូវយល់នោះ ដែល យ៉េង គាត់ដែលជាកូនចៅគាត់ដែរហ្នឹង កូនចៅ ម៉េត ដែរនោះ គឺបានប្រថុយប្រថានឲ្យគេចាប់លោក ហើយទន្ទឹមនឹងហ្នឹង យ៉េង ហ្នឹងក៏ដឹងថាលោកហ្នឹងមានទំនាក់ទំនងពិសេសជាមួយហ្នឹង ស៊ូ ម៉េត – ជាមួយ ម៉េត ហ្នឹងដែរ។ ហេតុអីក៏គាត់ធ្វើយ៉ាងដូច្នេះ? អ៊ីចឹងខ្ញុំមិនយល់ សូមលោកពន្យល់បន្តិចបានទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

ខ្ញុំទទួលស្គាល់ថាវាជាបញ្ហាស្មុគស្មាញ ប៉ុន្តែខ្ញុំមិនច្បាស់ថា ល្វៃ គាត់ដឹងថាសាក្សីរូបនេះត្រូវបានគេចាប់ខ្លួននៅភ្លាមៗនោះឡើយ។ ដូច្នេះ ខ្ញុំគិតថាគួរតែគិតទៅតាមបរិបទនៃភស្តុតាងដែលសាក្សីគាត់

និយាយអំពីទំនាក់ទំនងរវាងគាត់ ហើយនិង ម៉េត។ ដូច្នេះ ខ្ញុំគិតថាប្រហែលជាគេមិនដឹងថាសាក្សីត្រូវបានគេចាប់ខ្លួនភ្លាមៗនោះឡើយ។ ដូច្នេះ យើងគួរតែគិតអំពីបរិបទផង។

[១៤:៣៩:៥៤]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអរគុណដល់សហព្រះរាជអាជ្ញាដែលបានបំភ្លឺនេះ ក៏ប៉ុន្តែសំណួរខ្ញុំនោះ ខ្ញុំសួរទៅសាក្សីទេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំដឹងហើយថា គាត់មានទំនាក់ទំនងល្អពិសេសមួយជាមួយនឹង ម៉េត។ អ៊ីចឹងហើយបានខ្ញុំចង់ដឹងថាហេតុដូចម្ដេចបានជាគាត់ ដែលគាត់ធ្វើការតាំងពីឆ្នាំ៧៣មកជាមួយ ស៊ូ ម៉េត ហ្នឹង។ យ៉េង ហ្នឹង គាត់ធ្វើជា ម៉េត ហ្នឹងតាំងពីឆ្នាំ៧៣មក ហើយក៏ដឹងថាលោកសាក្សីនេះមានទំនាក់ទំនងពិសេសជាមួយ ម៉េត ហ្នឹងដែរ។ អ៊ីចឹងហេតុអីបានជាគាត់នុំងបញ្ជាឲ្យចាប់ខ្លួនគាត់ ហើយអ៊ីចឹងក៏គាត់ក៏ដឹងផងដែរថា សាក្សីនេះទទួលបញ្ជាដោយផ្ទាល់ពី ម៉េត ហ្នឹងដែរ ពេលមុននឹងទៅធ្វើការនៅព្រលានយន្តហោះហ្នឹង? អ៊ីចឹងហេតុអីក៏ យ៉េង ហ្នឹងប្រថុយប្រថានចេញបញ្ជាឲ្យចាប់ខ្លួនសាក្សីនេះ ដោយមិនប្រាប់ ម៉េត ហើយនិង លៃ្វ នេះ? អ៊ីចឹងខ្ញុំសួរថាម៉េចក៏ទៅរួច ម៉េចក៏ប្រថុយ ឬក៏ហ៊ានៗចេញបញ្ជាឲ្យចាប់ខ្លួនលោកនុំងដោយមិនសុំការអនុញ្ញាតពី ម៉េត ហើយនិង លៃ្វ នេះសិន?

[១៤:៤១:២៥]

**លោក ចាន់ ម៉ន៖**

**ឆ៖** ជំនាន់ហ្នឹងគឺឲ្យតែគេឆ្លៀតឱកាសបាន គេចង់ធ្វើយើងយ៉ាងម៉េចក៏បានដែរ ព្រោះឲ្យតែមេអ្នកណាដែលរាប់អានយើងៗ ស្រឡាញ់យើង រាប់ចាត់ទុកថាអ្នកហ្នឹងដែលធ្លាប់ល្អជាមួយយើងហើយបែកពីយើង ហើយទៅនៅឆ្ងាយ គេអាចធ្វើម៉េចក៏បានដែរ។ ព្រោះគេទៅដល់នុំងហើយមានតែគេវិញហើយ ព្រោះអ្នកធំហ្នឹងនៅឆ្ងាយ ហើយគេមកក្ដាប់រួមដូចថា គេជាប្រធានមន្ទីរហើយ គេចង់ធ្វើអីយើងក៏បានដែរ ឲ្យតែអ្នកធ្លាប់ -- ទោះបីស្រឡាញ់គ្នា ឱបគ្នា ប្រឡែងគ្នាលេងរាល់ថ្ងៃ ឲ្យតែអ្នកហ្នឹងចេញផុតពីកន្លែងហ្នឹងឆ្ងាយ យើងមិនអាចទុកចិត្តគេបានទេ នោះសម័យនុំង។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំលោកប្រធាន ព្រោះជិតដល់ពេលសម្រាកហើយៗ សូមបញ្ជាក់ម្ដងទៀតលោក គង់ សំអុន គាត់ត្រូវការពេលវេលា១០នាទីដើម្បីសួរ។ ទាក់ទងនឹង តាវិន ដែលលោកបាននិយាយអម្បាញ់មិញនេះ ដែលគាត់ជួយលោក ពេលដែលលោករត់គេចខ្លួនពីមន្ទីរស-២១។

តើលោកដឹងមានរឿងអីកើតឡើងចំពោះគាត់ដែរឬទេ នៅក្រោយពីគាត់ជួយលោកហើយហ្នឹង នៅក្នុងរបបខ្មែរក្រហមហ្នឹងមាន -- លោកមានដឹងថា គាត់មានរឿងអីកើតឡើងចំពោះគាត់ដែរឬទេ?

[១៤:៤៣:២០]

**ឆ៖** ក្រោយមកខ្ញុំអត់ដឹង អត់មានដឹងអីទាំងអស់។ ទើបដឹងតែពេលជួបជុំគ្នានៅហ្នឹងហើយដល់ពេលគាត់ ម៉េត ឲ្យខ្ញុំទៅណោះវិញទៅៗកន្លែងរ៉ាដាអីៗវិញទៅ គឺបែកបាក់តាំងពីហ្នឹង មិនដែលបានជួបដំណឹងថា អ្នកនេះធ្វើអីៗ អ្នកនេះនៅឯណា គាត់នៅឯណា នៅឯណី គឺអត់ដឹង។ គាត់មានរឿងហេតុអីក៏ខ្ញុំអត់ដឹង ព្រោះសម្ងំយកសុខវិញហើយ អត់មានចេញមុខឲ្យគេឃើញឲ្យនេះទេ គឺទៅកន្លែងណាគឺសម្ងំនៅកន្លែងហ្នឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសួរចប់ហើយ សូមអរគុណលោកប្រធានដែលបានបន្ថែមពេលវេលាឲ្យក្រុមយើងខ្ញុំលោកប្រធាន។ ហើយលោកមេធាវី គង់ សំអុន នឹងសុំសួរ១០នាទី ពេលចូលសម្រាកមកនេះគាត់សុំសួរ ១០នាទីលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ផ្តល់ឲ្យឥឡូវនេះតែម្តង។ អញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

[១៤:៤៤:៣៦]

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក ចាន់ ម៉ន ខ្ញុំចង់បញ្ជាក់ពីតួនាទីរបស់លោកនៅកំពង់ឆ្នាំង។ តាមខ្ញុំចាំបានអ្វីដែលលោកបានផ្តល់សក្ខីកម្មនៅទីនេះរយៈពេល២ថ្ងៃកន្លងមក។ ដំបូងលោកធ្វើជាអ្នកដឹកនាំរថយន្ត ដឹករថយន្តដឹកចិន អ្នកជំនាញចិនទៅធ្វើការនៅព្រលាន។ ហើយទី២ លោកទៅធ្វើការផ្នែកកាប់ឈើ ហើយទី៣លោកធ្វើនៅខាងផ្នែករ៉ាដានៅលើកំពូលភ្នំ។ តើខ្ញុំសង្ខេបនេះត្រឹមត្រូវទេ ការងារទាំងបីរបស់លោកនៅព្រលានយន្តហោះកំពង់ឆ្នាំង?

**លោក ចាន់ ម៉ន៖**

**ឆ៖** បាទ ត្រឹមត្រូវ។ អត់ខុសទេ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពេលវេលាដែលលោកធ្វើជាអ្នកបើកបរដឹកចិនទៅធ្វើការនៅការដ្ឋានកំពង់ឆ្នាំបានទេថា ចាប់ពីពេលដែលលោកទៅដល់ភ្នាមរហូតដល់ពេលណា លោកចាំបានទេ?

**ផ៖** ចាំមិនបាន។ ទៅ តាំងពីទៅហ្នឹង ដឹកតែចិនហ្នឹងវាទៅ មិនដឹងប៉ុន្មានខែ។ ១ខែមិនដឹង ២ខែមិនដឹង ខ្ញុំចាំអត់បានទេ។ ដល់ក្រោយមកបានមានបញ្ហាឲ្យខាងនាំគេ ដូចថាខ្ញុំស្គាល់ព្រៃស្គាល់អីអ៊ីចឹងទៅ កាប់ឈើ ស្គាល់កន្លែងណាដែលឈើធំៗអីហ្នឹង ចេះតែទៅទៅ។ អត់ចាំបានទេ។

[១៤:៤៦:៣០]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង តាមចម្លើយរបស់លោកអម្បាញ់មិញនេះ គឺការដឹកនាំភ្ញៀវចិនទៅធ្វើការនៅការដ្ឋានហ្នឹងគឺមានរយៈពេលខ្លីទេ។ មិនឆ្លងឆ្នាំទេ គឺរយៈដែលអាច២ខែ ៣ខែប៉ុណ្ណឹង។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ផ៖** ត្រឹមត្រូវហើយ។ វាមិនបានយូរទេ ខ្ញុំដឹកអត់បានយូរទេ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង បានន័យថារយៈពេលដែលលោកទៅកាប់ឈើនៅក្នុងព្រៃគឺមានរយៈពេលវែងជាងពេលវេលាដទៃទៀតទាំងអស់ ការងារក្នុងចំណោមការងារទាំងបីរបស់លោក។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ផ៖** ការងារដឹកឈើហ្នឹងគឺវា ច្រើនកន្លែងៗ ខ្ញុំមានពេលវែងណាស់ រកដាក់នៅដែលគេហៅថាស្រុក២០ផង ស្រុក១០ផង ស្រុក១២ផង វាពីរបីស្រុកហ្នឹងវាដើរទៅតាម ដើរកាប់ឈើអូសឈើហ្នឹងវាច្រើនថ្ងៃច្រើនខែ។ ខ្ញុំវាមិនអាចចាំបានពេលហ្នឹង អត់ អត់ចាំបានទេ។ មិនដឹងប៉ុន្មានខែៗ គឺថានៅនឹងឈើហ្នឹងវាច្រើនខែដែរ ហើយអង្គរធ្វើព្រៃហ្នឹងដែលគេឲ្យដឹកហ្នឹង វាច្រើនជើងដែរ អ៊ីចឹង។

[១៤:៤៧:៥៥]

**ស៖** បាទ សូមអរគុណ។ ក្នុងពេលដែលលោកធ្វើការដឹកឈើ គឺតាមសក្ខីកម្មរបស់លោក លោកមិនសូវនៅព្រលានកំពង់ឆ្នាំងទេ ដោយលោកធ្វើដំណើរចូលក្នុងព្រៃច្រើនថ្ងៃ អាចពីរបីថ្ងៃ ឬក៏លើសពីនេះ បានលោកមកការដ្ឋានម្តង ហើយត្រូវត្រឡប់ទៅវិញទៀត។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ផ៖** បាទ ត្រឹមត្រូវហើយ។ ខ្ញុំមិនសូវបាននៅនឹងការដ្ឋានទេ។ ខ្ញុំនៅតែព្រៃ។

**ស៖** បាទ សូមអរគុណ។ ក្នុងអំឡុងពេលដំបូងនៃការទៅកាប់ព្រៃ កាប់ឈើរបស់លោក តើពេលនោះមានអ្នកបូព៌ាទៅជាមួយដែរទេ? ក្នុងដំណាក់កាលដំបូង។

**ផ៖** ដំណាក់កាលដំបូង អត់មានទេ។ ដំណាក់កាលដំបូងមានទ័ពនៅក្នុង៥០២ទាំងអស់ហ្នឹងទៅ។ ហ្នឹងដំណាក់កាលដំបូង តែនៅពាក់កណ្ដាលហ្នឹងបានមាន។

**ស៖** បាទ សូមអរគុណ។ ហើយក្នុងដំណាក់កាលដំបូងលោកទៅគ្នាប៉ុន្មាននាក់ទៅកាប់ព្រៃ ទៅកាប់ឈើក្នុងព្រៃ?

**ផ៖** ពេលទៅដំបូងហ្នឹងគ្នាតិចទេ អត់សូវមានគ្នាទេ ទៅ១០-២០នាក់។ មួយកន្លែងទៅ ១០នាក់អី មួយក្រុមៗទេ ទៅដំបូង។

**ស៖** បាទ សូមអរគុណ។ ចុះនៅពេលដែលលោកទៅកាប់ឈើក្នុងព្រៃជាមួយអ្នកបូព៌ាមានគ្នាប៉ុន្មាននាក់ដែរ?

[១៤:៥០:០០]

**ផ៖** ទៅ ដែលទៅជាមួយបូព៌ាវាមាន ដាក់មួយកន្លែង៣០នាក់ៗ កន្លែងខ្លះក៏ចូល៥០នាក់អីចឹង។

**ស៖** មានប៉ុន្មានកន្លែង លោកអាចសរុបចំនួនអ្នកដែលចូលព្រៃកាប់ព្រៃជាមួយលោកបានទេ?

**ផ៖** ចូលទៅកាប់ឈើហ្នឹង មានប្រាំកន្លែង ដាក់ប្រាំកន្លែង តែមិនដាក់ឆ្ងាយពីគ្នាទេ គ្រាន់តែថាដាក់ប្រាំកន្លែងហ្នឹង ដូចថាស្រុកមួយហ្នឹងមានពីរកន្លែង ស្រុកមួយមានបីកន្លែងអីចឹងទៅ។ ដល់រួចទៅបានម្ដុំហ្នឹង ដូចថាអស់ឈើកន្លែងហ្នឹងហើយ បានដឹកអាហ្នឹងចេញ បានយកទៅដាក់កន្លែងផ្សេងទៀត។

**ស៖** បាទសូមអរគុណ។ អីចឹងតាមសក្ខីកម្មរបស់លោកអម្បាញ់មិញនេះ ចំនួនសរុបនៃអ្នកទៅកាប់ឈើក្នុងព្រៃនោះ ប្រហែលជាពី១៥០នាក់ ទៅ២០០នាក់។ តើចំនួនហ្នឹងត្រឹមត្រូវទេ?

**ផ៖** ចំនួនដែលទៅហ្នឹងវាមានពីលើស ព្រោះខ្ញុំបើកដូចថា សម្ភារៈឯណា ង៉ោងគេហ្នឹង អាណាកាត់អីចឹងទៅ ជួនកាលខ្ញុំបើកទៅ៥០០ទៅ ខូចទៅអីចឹងទៅ បើកទៅ៥០-៦០ បន្ថែមទៅ។ អាហ្នឹងវាអត់ទៀង។

[១៤:៥១:៤៥]

**ស៖** លោកអាចបញ្ជាក់ចំនួនពិតប្រាកដបានទេថាប្រហែលប៉ុន្មាន ពីព្រោះមុននេះអំមិញ លោកថាក្នុងមួយក្រុមអាច៣០នាក់ ឬក្រុមខ្លះអាចមាន៥០នាក់ ហើយមានប្រាំក្រុម។ អីចឹងបើមួយក្រុម ៣០នាក់ វាអាចខ្ទង់ថា១៥០ចុះ បាទ ហើយលោកថាអាចលើសពីហ្នឹង។ លោកអាចបញ្ជាក់បានទេថាចំនួនលើសហ្នឹងប៉ុនណាដែរ?

**ផ៖** លើសពីហ្នឹង គឺដូចអ្នកតែកុងឡានហ្នឹងឯង អ្នកតែកុងឡានលើស វាអ្នកកាប់ទៅផ្សេង

អ្នកតែកុងឡានផ្សេង។

**ស៖** បាទសូមអរគុណ។ លោកអាចបញ្ជាក់ថា អ្នកណាជាអ្នកដឹកនាំក្នុងការចូលព្រៃហ្នឹងទេ?

**ឆ៖** អ្នកចូលព្រៃមានតែខ្ញុំហ្នឹង អ្នកនាំគេចូលទៅ ដែលខ្ញុំស្គាល់ព្រៃ។

**ស៖** បាទ នាំចូលនេះក្នុងនាមជាមេបញ្ជាការក្នុងការដឹកនាំ ឬមួយក៏ជាអ្នកដឹកនាំ ដោយសារគ្រាន់តែស្គាល់ព្រៃ?

**ឆ៖** ជាអ្នកដឹកនាំជាស្គាល់ព្រៃទេ អត់មានជាបញ្ជាការ ជាមេទ័ព មេអី គឺគ្មានទេ។ គ្រាន់តែដឹកនាំថាស្គាល់ព្រៃនេះ ស្គាល់ស្រុកនេះ--

**ស៖** បាទសូមអរគុណ។ ចុះអ្នកណាជាមេបញ្ជាការ លោកចាំបានទេ ឬក៏អត់មានមេបញ្ជាការទេ?

**ឆ៖** មេបញ្ជាការដែលចេញទៅប្រាប់បញ្ជាពីក្រោយហ្នឹងមានតែ បងល្វៃ និង ម៉េត ហ្នឹងដែលប្រាប់។

[១៤:៥៣:៣៨]

**ស៖** បាទ សំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងអ្នកដែលទៅជាមួយ មេបញ្ជាការដែលទៅជាមួយលោក លោកអាចបញ្ជាក់បានទេ?

**ឆ៖** គេមានមេក្រុមគេ មេក្រុមតាមក្រុមគេមួយៗហ្នឹង គេទៅហ្នឹង មេក្រុម មេកងគេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងការបើកសម្ភារៈ លោកបានបញ្ជាក់ពីខាងដើមមុននេះថា មុនពេលដែលលោកត្រូវបានគេចាប់ខ្លួនហ្នឹង លោកបានបើកអង្ករ១០ការុង ដើម្បីយកទៅព្រៃ ទៅជាមួយអ្នកបូព៌ាហ្នឹង ប៉ុន្តែក្រោយមក លោកបានស្នើសុំទៅ តាល្វៃ ហើយដែលគាត់ថាឲ្យយកប៉ុន្មានយកទៅ ហើយលោកបានស្នើសុំរហូតដល់៥០ការុង។ ខ្ញុំចង់សួរថា តើចំនួនអង្ករដែលលោកយកទៅ ៥០ការុងនេះ បើគិតជាគីឡូក្រាមវិញក្នុង១ការុង មានប៉ុន្មានគីឡូដែរ?

**ឆ៖** មានតែ៥០គីឡូ ក្នុង១ការុងហ្នឹងមាន៥០គីឡូ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ មិនមែនជាការជំទាស់ទេ ប៉ុន្តែខ្ញុំមិនច្បាស់ទេ ពាក់ព័ន្ធនឹងសក្ខីកម្ម

របស់សាក្សីហ្នឹង។ មិនដឹងថាអង្ករដែលដឹកជញ្ជូនទៅឲ្យកងទ័ពមកពីភូមិភាគបូព៌ាហ្នឹង ថាតើជាបន្ទុកសាក្សីរូបនេះ ឬក៏ត្រូវយកទៅប្រគល់នៅកន្លែងផ្សេងទេ។ ដូច្នេះ មេធាវីការពារក្ដីគួរសួរថា តើអង្ករដែលដឹកទៅហ្នឹង គឺដឹកទៅឲ្យតែអ្នកធ្វើការជាមួយសាក្សីទេ ឬក៏ដោយសារសាក្សីដឹកអង្ករហ្នឹងទៅឲ្យអ្នកដទៃនៅកន្លែងផ្សេង ដើម្បីឲ្យទទួល -- ឲ្យដឹងច្បាស់អំពីការទទួលខុសត្រូវនេះ។

[១៤:៥៥:៥១]

**លោក គង់ សំអុន៖**

បាទ ខ្ញុំកំពុងតែចាប់ផ្ដើមសួរហើយ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ឥឡូវលោកៗបានបញ្ជាក់អម្បាញ់មិញនេះ លោកថាមួយការុង ៥០គីឡូ។ អ៊ីចឹងអង្ករទាំង ៥០ការុងដែលលោកយកទៅហ្នឹង លោកចែកទៅអ្នកណាខ្លះ? លោកអាចបញ្ជាក់បានទេ?

**លោក ចាន់ ម៉ន៖**

**ឆ៖** ចែកទៅតាមក្រុមគេ ដែលដូចថាកន្លែង វាមានប្រាំកន្លែងហ្នឹងចែកគេតាមកន្លែងហ្នឹងទៅកន្លែងណាតិច ចែកតាមតិចអ៊ីចឹង កន្លែងណាច្រើនទៅ ចែកតាមច្រើនអ៊ីចឹង តាមក្រុមគេ តាមដែលនៅដូចថា ខ្លះនៅ១០នាក់ ខ្លះនៅ២០នាក់ ខ្លះនៅអ៊ីចឹងទៅ ចែកតាមហ្នឹងឲ្យគេទៅ។

**ស៖** អង្ករហ្នឹង លោកចែកទាំងអស់ ឬក៏មានលោក មានឃ្លាំងនៅក្នុងព្រៃសម្រាប់ទុកនៅពេលក្រោយទៀត?

**ឆ៖** ខ្ញុំអត់មានឃ្លាំងទុកទេ មានតែចែកទាំងអស់ៗ។ គ្រប់ពេលណាចែកទៅ ចេញពីឡានអស់ដើម្បីយកឡានហ្នឹងត្រឡប់មកវិញមកដឹកឈើវិញ អត់មានចែក យកទៅមានឃ្លាំង មានអី គឺអត់ទេ។

**ស៖** បាទ សូមអរគុណ។ ចុះស្ថានភាពហូបចុក សម្រាប់ក្រុមកាប់ឈើរបស់លោកនេះ កាប់ព្រៃរបស់លោកហ្នឹង មានស្ថានភាពយ៉ាងម៉េចដែរ លោកអាចបញ្ជាក់ពីលក្ខណៈទូទៅបានទេ?

**ឆ៖** ពេលដែលខ្ញុំនៅចែកអង្ករ ចែកអីដឹកប្រហុកអំបិលអី យកទៅឲ្យគាត់ហ្នឹង គឺគ្រប់គ្រាន់ ខ្ញុំអត់ដែលអត់ អត់ដែលថា អ៊ូ! ហូបបបរ ហូបអីទេ។ គឺអាហ្នឹងពេលដែលខ្ញុំនៅ គឺខ្ញុំដឹកអង្ករទៅគ្រប់គ្រាន់ ពេលណាខ្វះ ខ្ញុំមកយក ខ្ញុំអត់មានទៅកេងប្រវ័ញ្ច ឬស្អីពីបងប្អូននោះទេ អត់ទេ ពេលខ្ញុំនៅ។ ដល់ពេលក្រៅពីហ្នឹង ខ្ញុំអត់ដឹងទេ។

[១៤:៥៨:០២]

**សៈ** បាទ សូមអរគុណ។ លោកបានបញ្ជាក់អំពីអាវុធដែលយកទៅក្នុងឡានមួយមានកាំភ្លើងមួយដើម ហើយលោកបានថាប្រើកាំភ្លើងហ្នឹងដើម្បីបរបាញ់សត្វ។ លោកចាំបានទេ ថាសត្វអីខ្លះដែលក្រុមការងាររបស់បាញ់សម្លាប់យកមកធ្វើជាម្ហូបហ្នឹង?

**ផៈ** ក្រុមការងារខ្ញុំច្រើនតែ ដូចថាទៅដល់ហ្នឹង ទៅជាមួយគ្នាទាំងអស់ហ្នឹងទៅ តែខ្ញុំវាមិនដែលបានដើរទៅតាមគេទេ ដែលគេទៅហ្នឹង គេបានទៅ ជួនកាលឈ្លូសទៅ ជួនកាលទន្សាយប្រាំប្រាំមួយមកវា ហើយនិងអាដែងឈ្លូស រមាំង វាច្រើនតែអ៊ីចឹងឯងយកមក តែបងប្អូននៅហ្នឹងវាច្រើនតែបានហូបអ៊ីចឹងដែរ វាមិនដែលខានប៉ុន្មានទេ។ ហើយនៅជិតមាត់ស្ទឹងអ៊ីចឹងទៅ ត្រីអីទៅ ចាប់អីបានអ៊ីចឹង បរិបូរដែរ វាអត់អីទេ នៅក្នុងព្រៃហ្នឹងនោះ។ អាហ្នឹងជំនាន់ខ្ញុំដែលខ្ញុំទៅ។

**សៈ** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមនិយាយពីឈ្មោះ យ៉េង ដែលលោកថាជាប្រធានកាប៊ីនេជាប្រធានមន្ទីរនៅកងពល៥០២។ លោកស្គាល់គាត់ច្បាស់ទេ?

**ផៈ** អ្ហែ! ពីដើមខ្ញុំស្គាល់ច្បាស់ ដល់ឥឡូវនេះ បើថានៅរស់ក៏មើលគ្នាមិនស្គាល់ច្បាស់ទេ ព្រោះខ្ញុំវា -- គាត់ដឹងតែចូលប៉ុន្មានហើយ ខ្ញុំវាឡើង៦០ទៅហើយ វាពិបាកមើល។

[១៤:៥៩:៥០]

**សៈ** បាទ សូមអរគុណ។ លោកស្គាល់ពីអត្តចរិតរបស់គាត់ជាមនុស្សយ៉ាងម៉េចដែរទេ?

**ផៈ** មនុស្សហ្នឹងនិយាយមួយម៉ាត់ៗមក កាចណាស់មនុស្សហ្នឹង វាមិនចេះនិយាយពាក្យគួរសមទេ គេហៅថាពាក្យ “ខ្លាំងតែម្តង” និយាយប្រដៅមកវាខ្លាំងៗ មិនដូចគេខ្លះ គេនិយាយគេដឹងថាសីលធម៌រស់នៅនេះ ក្មេងៗអីរស់នៅជាមួយ គេដឹងតែចរិតរបស់គាត់គឺកាច។ ម៉ាត់ណាម៉ាត់ហ្នឹង ព្រោះអ្នកចេះ។ គាត់និយាយថាគាត់អ្នកចេះ។

**សៈ** បាទ សូមអរគុណ។ ក្រៅពីករណីដែលកើតឡើងចំពោះលោកផ្ទាល់ លោកមានដឹងថាឈ្មោះ យ៉េង ហ្នឹងមានបានធ្វើអ្វីឃោរឃៅទៅលើអ្នកដទៃទៀតទេ?

**ផៈ** ព្រោះក្រោយមកហ្នឹងទៀត ខ្ញុំចេញមកបាត់អ៊ីចឹងទៅ ខ្ញុំនៅឆ្ងាយ ខ្ញុំអត់មានដឹងអីទេ។ អត់មានដឹងអីទៀត។ សួរគេដែរ ក៏គេថាមិនដែលបានចុះទៅហ្នឹងដែរ ខ្ញុំនៅតែឯលើ ហើយខ្ញុំមិនសូវដែលចុះទៅកន្លែងហ្នឹងទៀតទេ ច្រើនតែមកខេត្ត ងូតទឹកងូតអីឯខេត្តនេះ។

[១៥:០១:២៤]

**សៈ** បាទ សំណួររបស់ខ្ញុំ គឺថាមិនចាំបាច់ពេលក្រោយទេ គឺពេលមុនក៏ដោយដែលការប្រព្រឹត្ត

របស់ឈ្មោះ យ៉េង ទៅលើអ្នកដទៃទៀតហ្នឹង ដែលមានលក្ខណៈឃោរឃៅ លោកមានកត់សម្គាល់ដែរទេ?

**ឆ៖** វាច្រើនតែនិយាយខ្លាំងៗ ហើយនិយាយហ្នឹងវាឃើញយើងនិយាយអីមិនស្រួលហ្នឹង គាត់លេងមុំាងៗមកបណ្តោយ ពិបាក--

**ប្រធានអង្គជំនុំ៖**

លើសពេលច្រើនហើយ។

បាទ សវនាការស្តាប់សក្ខីកម្មសាក្សី ចាន់ ម៉ន ដល់ទីបញ្ចប់ហើយ ហើយសវនាការបន្តនៅរសៀលនេះ បន្ទាប់ពីសម្រាកអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-910។ សូមភាគីជ្រាប។

អង្គជំនុំជម្រះអរគុណលោក ចាន់ ម៉ន ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេល២ថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ការផ្តល់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ វត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសំណាងល្អ ហើយមានសេចក្តីសុខ សេចក្តីចម្រើន និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី និងដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៥:០៣ នាទី ដល់ម៉ោង ១៥:១៥ នាទី)*

[១៥:១៦:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី 2-TCW-910 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលមកកាន់បន្ទប់សវនាការ)*

[១៥:១៧:៣៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក កែវ គីន៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ កែវ គីន មកពីឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

**ស៖** លោកកើតនៅថ្ងៃខែឆ្នាំណាលោកចាំដែរទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាលទាន់ឆ្លើយតប!

**ឆ៖** កើតនៅឆ្នាំ១៩៦៥។

**ស៖** បាទ អរគុណ។ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាលទាន់ឆ្លើយតប!

**ឆ៖** ខ្ញុំនៅភូមិក្រាំងស្គារ ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

**ស៖** ចុះលំនៅបច្ចុប្បន្នរបស់លោកនៅកន្លែងដដែលហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** បាទ នៅកន្លែងដដែល អត់មានទៅណាទេ នៅកន្លែងភូមិដដែល។

**ស៖** តើលោកប្រកបមុខរបរធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** បាទ ខ្ញុំធ្វើស្រែ។

**ស៖** បាទអរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះអី? ម្តាយបង្កើតរបស់លោកឈ្មោះអី?

[១៥:១៩:១៧]

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ កែវ ហម ម្ដាយឈ្មោះ សោម ស៊ុន។

**ស៖** ប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធឈ្មោះ ខាំ ថ មានកូនពីរនាក់ (កូនដើម)។ ខ្ញុំមានប្រពន្ធពីរ ប្រពន្ធមុនស្លាប់ យកប្រពន្ធមួយទៀត។

**ស៖** អរគុណលោក កែវ គីន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញថា តាមសមត្ថភាពដែលលោកអាចដឹងបាន លោកមិនមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺ នួន ជា និង ខៀវ សំផន និងបុគ្គលដែលត្រូវទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ នេះទេ។ តើពិតមែនដែរទេ?

**ឆ៖** ពិតមែន។ ខ្ញុំអត់មានជាប់ពាក់ព័ន្ធអីជាមួយចុងចោទទេ អត់។

**ស៖** ហើយរបាយការណ៍ដដែលថាលោកបានសម្បថរួចហើយ មុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។ តើពិតមែនដែរទេ?

**ឆ៖** ពិតមែន។ ខ្ញុំបានស្បថរួចហើយ។

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចលោកក្នុងនាមលោកជាសាក្សី។ លោក កែវ គីន ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ចលោក កែវ គីន ក្នុងនាមលោកជាសាក្សី លោកត្រូវតែឆ្លើយតបទៅរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោក ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់សាក្សីរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក កែវ គីន តើលោកធ្លាប់ផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងមក? ហើយប្រសិនបើធ្លាប់ ប៉ុន្មានដង

ដែរ? ហើយធ្វើនៅទីកន្លែងណា?

**ឆ៖** ខ្ញុំបានធ្វើតែម្តងគត់នៅផ្ទះ ដែលក្រុមការងារគេទៅចុះទៅធ្វើសម្ភាសន៍ខ្ញុំ នៅភូមិខ្ញុំផ្ទាល់តែម្តង។

[១៥:២២:២៤]

**សៈ** បាទ អរគុណ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងលោកចងចាំថា តើលោកអាចបញ្ជាក់បានដែរទេថាមុនពេលនេះ តើលោកបានពិនិត្យមើល ឬអានន្ទូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុន ជាមួយនឹងអ្នកស៊ើបអង្កេតនៅនឹងផ្ទះរបស់លោកនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំចាំខ្លះ អត់ខ្លះ ព្រោះវាយូរដែរហើយ មិនមែន១ខែ ២ខែឯណា វាជិតបានពីរឆ្នាំជាងហើយតាំងពីទៅ។ ខ្ញុំមិនសូវចាំច្បាស់លាស់។ បាទ គាត់ទៅសម្ភាស ទៅជាមួយទៅ ឃើញគាត់ទៅ។

**សៈ** តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំថា តើលោកអាចបញ្ជាក់បានដែរទេកំណត់ហេតុដែលស្តាប់សក្ខីកម្មរបស់លោក ដែលលោកបានអានដើម្បីរំឭកការចងចាំហ្នឹង គឺពិតជាត្រឹមត្រូវវាសមស្រម ឬក៏វាស៊ីចង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៅនឹងផ្ទះរបស់លោកកាលពី២ឆ្នាំមុននោះដែរឬទេ? ពីរបីឆ្នាំមុននោះដែរឬទេ?

**ឆ៖** បាទ តាមចម្លើយខ្ញុំបាទហ្នឹងវាដូចដែល -- តាមកំណត់ហេតុហ្នឹង ដូចគាត់ទៅសម្ភាសខ្ញុំអ៊ីចឹងដែរ។ អត់មានសម្ភាសអីទៀតកាលពីសម្ភាសខ្ញុំរឿង កាលណាដែលដឹងការពិត រឿងពិត និយាយតែការពិត បាទ។

**ប្រធានអង្គជំនុំ៖**

ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន ៩១ ស្ទួននៃវិធានផ្ទៃក្នុង នៃ អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៅថ្ងៃសវនាការ ក្នុងការសួរសាក្សីរូបនេះ។

ហើយថ្ងៃនេះអង្គជំនុំជម្រះផ្តល់លទ្ធភាពក្នុងការសួរសាក្សីនេះរហូតដល់ម៉ោង បួនដប់នាទី។ សូមអញ្ជើញ!

[១៥:២៤:៤៧]

**វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

ជម្រាបសួរលោក កែវ គីន យើងមានសំណួរជាច្រើនដើម្បីចោទសួរលោក ក៏ប៉ុន្តែយើងមានពេលកម្រិត។ ដូច្នេះ ខ្ញុំនឹងអានសម្រង់មួយចំនួននៃចម្លើយរបស់លោកពីមុន ហើយនិង ខ្ញុំនឹងសុំឲ្យលោកឆ្លើយបន្ថែមទៅនឹងចម្លើយរបស់លោក។

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីប្រគល់ជូនកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ជាភាសាខ្មែរទៅឲ្យគាត់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[១៥:២៥:៥៦]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី តើលោកចេះអានទេ លោកភ្នែកលោកនៅល្អ នៅអាចមើលអក្សរបានទេ?

**លោក កែវ គីន៖**

**ឆ៖** ខ្ញុំមើលអត់ច្បាស់ទេ ព្រោះជាប់គ្នារវែ មើលអត់ឃើញទេ។

**ស៖** មិនជាបញ្ហាអ្វីទេ ខ្ញុំនឹងចាប់ផ្តើមសួរសំណួរមួយចំនួន អំពីប្រវត្តិលោកមុនថ្ងៃទី១៧ មេសា ៧៥។ ខ្ញុំនឹងអាននូវចម្លើយរបស់លោក គឺនៅឯកសារ E3/5273 គេសួរលោកថា “តើមុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ លោកធ្វើអ្វី និងរស់នៅឯណា?” លោកបានឆ្លើយថា “ខ្ញុំជាទាហានខ្មែរក្រហម ក្នុងកងវរសេនាធំ ៥០២ កងពលលេខ១ ដែលមានមេកងពលឈ្មោះតាសឿង។ ប្រធានវរសេនាធំ៥០២ ឈ្មោះល្វៃ។ វរសេនាធំលេខ៥០២ បោះទីតាំងនៅព្រៃមិច ស្រុកថ្ពង ខេត្តកំពង់ស្ពឺ”។ ខ្ញុំសូមបញ្ចប់ត្រឹមនេះសិន។ តើលោកធ្វើជាទាហាននៅក្នុងកងវរសេនាធំ៥០២ កងពលលេខ១ នៅកំពង់ស្ពឺក្រោមបញ្ជារបស់ តាល្វៃ ហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** បាទ ខ្ញុំធ្វើជាទាហានខ្មែរក្រហម ក្រោមការគ្រប់គ្រងរបស់ ល្វៃ ហ្នឹងចំនួន -- តាំងពីឆ្នាំ ៧២១ មកដល់ឆ្នាំ៧៥។ បានខ្ញុំឈប់ ៗនៅក្រោមហ្នឹង។

**សៈ** តើលោកជានីរសាររបស់ តាល្វៃ ដែរឬទេ ពីចន្លោះឆ្នាំ ៧៤ ដល់ ឆ្នាំ៧៥នោះ?

**ឆៈ** ខ្ញុំនៅជានីរសារ ល្វៃ ហ្នឹងជាមួយៗគ្នាច្រើនដែរ បី បួន ដប់នាក់ដែរ ដែលខ្ញុំនៅមួយក្រុមធ្វើនីរសារមែន។

**សៈ** តើលោកធ្វើអ្វីខ្លះឲ្យ ល្វៃ ក្នុងនាមជានីរសារហ្នឹង ហើយលោកត្រូវលោកសារទៅណាខ្លះ?

**ឆៈ** បាទ ខ្ញុំទៅយកសារ ខាងកើតពីព្រលានពោធិ៍ចិនតុង ជួនកាលយកទៅឲ្យនៅខេត្តកំពង់ឆ្នាំង ប៉ុនសារហ្នឹង នៅក្នុងគេដាក់ថាម៉េច ខ្ញុំមិនបានមើលបានអីដែរ ជិះម៉ូតូទៅយកទៅឲ្យហ្នឹង។ ម្តងពីរដងអ៊ីចឹង។ ក្នុង១ខែ ជួនកាលម្តង ជួនកាលអត់។

**សៈ** នៅពេលដែលលោកមិនយកសារទៅណានោះ លោកធ្វើជាកងអង្គរក្ស ឬក៏កងការពាររបស់ តាល្វៃ មែនទេ?

**ឆៈ** បាទៗ ខ្ញុំបានធ្វើកងការពាររបស់លោក ល្វៃ ហ្នឹង។

[១៥:៣០:០៨]

**សៈ** តើនៅពេលនុ៎ង នៅសម័យនុ៎ង តាល្វៃ គាត់ទុកចិត្តលើលោកទេ?

**ឆៈ** បាទ មុនដំបូងទុកចិត្តដែរ ប៉ុន្តែដល់តែក្រោយមក ខ្ញុំជាប់ពាក់ព័ន្ធនិន្នាការឪពុកខ្ញុំធ្វើជំទប់ពីជំនាន់លន់នល់ ជំនាន់អីហ្នឹង គេលែងទុកចិត្តខ្ញុំ គេដកខ្ញុំចេញឲ្យនៅក្រៅពីកន្លែងគាត់ហ្នឹង។ ប៉ុនអត់នៅឆ្ងាយ នៅក្រុមក្បែរៗហ្នឹង ប៉ុន្តែលែងដើរជាមួយគាត់ទៀតហើយ។

**សៈ** តើចាប់ពីណាមកដែល តាល្វៃ ដឹងថាឪពុករបស់លោកជាអនុប្រធានភូមិនោះ មុនពេលវាយយកភ្នំពេញបាន ឬក្រោយពេលវាយយកភ្នំពេញបាន?

**ឆៈ** ក្រោយវាយភ្នំពេញបាន បានដឹងថាប្រវត្តិរូបខ្ញុំមានឪពុកធ្វើជំទប់ ធ្វើអីអ៊ីចឹងទៅបានគាត់ដកចេញ លែងឲ្យនៅជាមួយ។ យើងជាប់ចោទ ជាប់ពាក់ព័ន្ធជាមួយនឹងនិន្នាការ សម័យហ្នឹងគេហៅនិន្នាការ។

**សៈ** តើការបញ្ចុះស័ក្តិលោក ឬក៏គេមានដាក់ទណ្ឌកម្មអីឲ្យដល់លោកទេនៅពេលនុ៎ង?

**ឆៈ** ខ្ញុំពីជំនាន់ហ្នឹង ខ្ញុំអត់មានស័ក្តិ មានយស មានអីនឹងគេទេ ប៉ុន្តែគេដកពីសេចក្តីទុកចិត្តពីគេហ្នឹង ប៉ុន្តែគេអត់ធ្វើទារុណកម្មដែរ គេអត់ធ្វើវាយដំអីទេ គ្រាន់តែគេថាឲ្យលត់ដំ លត់អី ជីកប្រឡាយជីកអីហ្នឹង ហើយខ្ញុំទៅធ្វើជាហ្កាវ៉ាសឡាន ហ្កាវ៉ាសអី ដាក់កន្លែងអាត្រាក់ កន្លែងរ៉ូឡូ កន្លែងអីហ្នឹង។

[១៥:៣២:៣០]

**ស៖** ពេលដំបូងនោះ គឺលោកធ្វើការនៅជិតពោធិ៍តុងមែនទេ ហើយនៅពេលនៅធ្វើការនៅជិតពោធិ៍តុងហ្នឹង លោកមានមុខងារអ្វីដែរ? ខ្ញុំនិយាយអំពីពេលចប់ ពីពេលដែលវាយយកភ្នំពេញបានភ្លាមៗ?

**ឆ៖** ខ្ញុំ វាយយកភ្នំពេញបាន ខ្ញុំនៅមុខផ្សារពោធិ៍ចិនតុង នៅកន្លែងផ្លូវបត់ខាងកើតពោធិ៍ចិនតុងហ្នឹង គេឲ្យខ្ញុំជម្រះស្មៅ ហើយនិងយាមសម្ភារៈឃ្លាំងស្បៀង នៅយាមប្រដាប់ប្រដានៅកន្លែងហ្នឹងនៅជម្រះស្មៅ ជម្រះអីនៅហ្នឹង។

**ស៖** អម្បាញ់មិញនេះ ខ្ញុំអានសម្រង់នូវចម្លើយរបស់លោក លោកនិយាយអំពីវរសេនាធំ៥០២។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់ថា វរសេនាធំនេះ ក្រោយមកក្លាយជាកងពលធំមែនទេ? ហើយកងពលធំហ្នឹងជាកងពលធំរបស់មជ្ឈិមមែនទេ?

**ឆ៖** ៥០២ហ្នឹង ក្លាយជាកងពលធំ៥០២ តែដឹង -- ខ្ញុំទៅនៅវរសេនាធំជាមួយ តាល្វៃ។ មេកងពលឈ្មោះអីខ្ញុំមិនសូវស្គាល់ដែរ ខ្ញុំថាឈ្មោះ ម៉េត។ មានស្គាល់តែប៉ុណ្ណឹង ផុតពីហ្នឹងអត់ស្គាល់ទៀត។

[១៥:៣៤:៣០]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនិយាយអំពីរយៈកាលដែលលោកត្រូវបានបញ្ជូនទៅកំពង់ឆ្នាំង។ ខ្ញុំនឹងដកស្រង់ចម្លើយរបស់លោកពាក់ព័ន្ធនឹងចំណុចនេះ គឺកំណត់ហេតុលេខ E3/5273 ទំព័រជាភាសាខ្មែរ 00282941, ជាភាសាបារាំងគឺ 00355856, ជាភាសាអង់គ្លេស 00290500។ នៅពេលនោះគេសួរលោកថា៖ "នៅពេលដែលលោកចូលដល់ភ្នំពេញនៅថ្ងៃទី១៧ មេសា ៧៥ តើគេឲ្យលោកធ្វើអ្វីទៀត?" លោកបានឆ្លើយដូចតទៅ៖ "គេឲ្យជម្រះស្មៅ យាមឃ្លាំងស្បៀងខាងកើតព្រលានយន្តហោះពោធិ៍ចិនតុងជាមួយឈ្មោះ ម៉េង។ ខ្ញុំនិង ម៉េង ត្រូវបានគេចោទថាមាននិន្នាការ ព្រោះឪពុកខ្ញុំជាជំទប់ឃុំសម័យលន់ នល់។ បន្ទាប់មកនៅក្នុងខែ២ ឆ្នាំ១៩៧៦ តាល្វៃ បានដកខ្ញុំឲ្យមកធ្វើការនៅព្រលានយន្ត-ហោះក្រាំងលាវ ខេត្តកំពង់ឆ្នាំង ដែលខ្ញុំត្រូវទទួលបន្ទុកធ្វើរោងដាក់ឡាន ត្រាក់ទ័រ រ៉ូឡូ។ល។ ដោយសារតែខ្ញុំត្រូវគេចោទថាមាននិន្នាការ"។ សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកអាចជម្រាបបានទេ ថានៅខែកុម្ភៈ ឆ្នាំ១៩៧៦ គឺមានមេដឹកនាំមក -- មេដឹកនាំនៃកងពល៥០២ នៅកំពង់ឆ្នាំងហ្នឹងស្រាប់នៅពេលដែលលោកទៅដល់នោះ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើអ្នកណាដែលជាអ្នកដឹកនាំការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងនេះ តាំងពីដំបូងមកនោះ?

**ឆ៖** បាទ ខ្ញុំដូចអត់ដឹងដែរ ប៉ុន្តែវាឃើញដល់នោះ ឃើញ តាល្វៃ គាត់ធ្វើ អ្នកនាំធ្វើព្រលានហ្នឹង រួចជាទៅដំបូងដែហ្នឹងវាគ្នាតែបីបួន -- ថា១២នាក់ចុះ ទៅដល់ព្រលានកំពង់ឆ្នាំងហ្នឹង រួចទៅដល់សុទ្ធតែ

ព្រៃ សុទ្ធតែដើមត្នោតដើមអីហ្នឹង នាំគ្នាកាប់គាស់ដី គល់ត្នោត គល់ដូង គល់អីដែលទើសព្រលានហ្នឹង នាំគ្នាអារ គ្នាមួយក្រុម គ្នា១០នាក់។ រួចក្រោយមកទៀត បានខ្ញុំឃើញអាត្រាក់ ឃើញអី គេទៅពង្រាបដី ពង្រាបអីហ្នឹង។ បានឃើញតែប៉ុណ្ណឹង ហើយខ្ញុំគាស់គល់ គាស់អីហ្នឹង ធ្វើ។

[១៥:៣៧:៥១]

**ស៖** លោកបានឆ្លើយថា តាឡៃ បានមកដល់ក្នុងពេលតែមួយជាមួយលោក។ អ៊ីចឹងមែនទេ ចម្លើយលោកអម្បាញ់មិញនេះ?

**ឆ៖** បាទ គាត់នាំមកដាក់ហ្នឹង មកៗនៅធ្វើព្រលានហ្នឹង ហើយនាំគ្នា១០នាក់ហ្នឹងមក។

**ស៖** ចុះក្នុងចំណោមអ្នកទាំង១០ហ្នឹង អ្នកណាជាអ្នកបញ្ជា អ្នកណាជាមេ? លោកអាចផ្តល់ឈ្មោះបានទេ?

**ឆ៖** បាទ ក្នុងចំណោម១០នាក់ហ្នឹង មានឈ្មោះ សុង គាត់ជាមេក្រុម ដឹកនាំកាប់ដើមឈើ ដើមត្នោត ដើមអី គាស់គល់ គាស់អីហ្នឹង ហើយជីកដី ជីកអី។ ពិសោធជាមួយក្រុមចិនមកប្រមាណ -- ខ្ញុំវាមិនសូវបានរាប់ពិតប្រាកដផង ១០នាក់មិនដឹង អីមិនដឹង ខ្ញុំមកនៅដើរជាមួយក្រុមខ្ញុំហ្នឹង វាស់វែងដី ហើយពិសោធដីហ្នឹង។

**ស៖** នៅពេលដែលលោកទៅដល់ដំបូងហ្នឹង តើ សុង គាត់មានរៀបរាប់ប្រាប់លោកថា លោកត្រូវធ្វើអ្វីខ្លះទេ? ហើយគេមានប្រាប់ថាគោលដៅដែលគេឲ្យលោកធ្វើហ្នឹង ដើម្បីអ្វីទេ?

**ឆ៖** បាទ ទៅដល់ដំបូង គេអត់មានប្រាប់អីឲ្យដឹងផង។ គាត់ប្រាប់ គ្រាន់តែៗគាស់គល់ឈើ ហើយនិងកាប់ព្រៃហ្នឹង តែគេធ្វើព្រលានដើម្បីអីខ្ញុំអត់ដឹងដែរ ព្រោះដឹងតែធ្វើគ្នា១០នាក់ហ្នឹង អត់មាននិយាយប្រាប់ គេធ្វើស្អីៗផង ខ្ញុំអត់ដឹងណា គេអត់ប្រាប់។

[១៥:៤០:០៥]

**ស៖** តើក្រុមរបស់លោកទាំង១០ហ្នឹង ធ្វើការបានប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ ទើបមានកម្មករជំនួយមកបន្ថែមទៀតនោះ?

**ឆ៖** បាទ ធ្វើទាល់តែដល់ឆ្នាំ៧៦ បានគេឃើញមនុស្សម្នាពីភូមិភាគបូព៌ា ភូមិភាគបស្ចិម ភូមិភាគនិរតីទៅ ច្រើន ខ្ទង់ពាន់ដែរតាមមើល ពាន់នាក់ តាមមើល៍ ប៉ុន្តែគេធ្វើការដោយឡែករៀងៗខ្លួន បានឃើញតែប៉ុណ្ណឹង ឃើញមនុស្សច្រើនមកពីបូព៌ា។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន យើងអត់ស្តាប់ឮការបកប្រែជាភាសាបារាំងចំពោះចម្លើយចុងក្រោយរបស់សាក្សីទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ តាំងសំណួរចុងក្រោយអម្បាញ់មិញម្តងទៀត សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** សំណួរចុងក្រោយអម្បាញ់មិញនេះ ខ្ញុំចង់ដឹងថា តើលោកធ្វើការជាមួយក្រុមទាំង១០នាក់របស់លោកហ្នឹងបានប៉ុន្មានខែដែរ ទើបមានកម្មករមកជំនួយបន្ថែមមកជួយលោកនោះ?

[១៥:៤២:០៩]

**លោក កែវ គីន៖**

**ឆ៖** បាទ ខ្ញុំធ្វើតាំងពី៧៥ ទល់៧៦ បាទ ឃើញជំនួយៗមកជួយធ្វើប្រហែលជា១.០០០នាក់ទេមើលទៅ។ ខ្ញុំអត់បានរាប់ អត់បានដឹងដែរ។ រួចឃើញមនុស្សធ្វើតែប៉ុណ្ណឹង។ ធ្វើទាល់តែទល់ ធ្វើរហូតដល់ឆ្នាំ៧៧ ទល់៧៨ បានរត់មក បានវៀតណាមចូលហ្នឹង ហើយក៏រត់បែកគ្នីបែកគ្នាអស់ទៅ ដឹងគេទៅខាងណាខាងណី។

**ស៖** បាទ សូមអរគុណ។ ខ្ញុំយល់ហើយ គឺលោកនៅដល់ឆ្នាំ៧៨ ក៏ប៉ុន្តែក្នុងសម្រង់ដែលខ្ញុំអាននោះ លោកបានបញ្ជាក់ថា លោកបានទៅដល់ក្នុងខែ២ ឆ្នាំ១៩៧៦។ អ៊ីចឹងក្នុងខែ២ ៧៦ហ្នឹងជាកាលបរិច្ឆេទត្រឹមត្រូវទេ ឬក៏លោកគ្រាន់តែប្រហាក់ប្រហែលទេ?

**ឆ៖** បាទ ខ្ញុំប្រហែលជាខែ២ហ្នឹងហើយ ព្រោះដើមខែច្រូតរួចទៅបណ្តោយ។ ខ្ញុំមិនបានចាំគិតខែគិតអីដែរ។ អរដែលគេដកចេញពីកន្លែងនេះទៅនៅនឹងកងវិញ នៅឯនេះពិបាក ហើយមិនដឹងជាខែប៉ុន្មាន ខ្ញុំមិនសូវជាច្បាស់លាស់ទេ។ បាទ ប្រហែលជាខែ២។

**ស៖** ក្នុងសម្រង់ដែលខ្ញុំបានអានមុននេះ លោកបាននិយាយថា លោកធ្វើការនៅរោងដាក់ឡានត្រាក់ទ័រ រ៉ូឡូ។ លោកបានបញ្ជាក់ថា ដំបូងឡើយគឺលោកជម្រះស្មៅ។ អ៊ីចឹងតើប៉ុន្មានសប្តាហ៍ ឬក៏ប៉ុន្មានខែក្រោយមកដែរ ដែលលោកបានធ្វើការនៅក្នុងរោងដាក់ឡានហ្នឹង?

**ឆ៖** ក្រោយគេយកខ្ញុំពីពោធិ៍ចិនតុងទៅ យកទៅដាក់ឯហ្នឹងបានចាប់ផ្ដើមធ្វើរោងដាក់ឡាន រោងដាក់រ៉ូឡូ រោងដាក់អាត្រាក់ ហើយធ្វើ -- ខ្ញុំវាភ្លេចទៅ ប្រហែលជាខែ២ហ្នឹងហើយមើលទៅ វាមិនបានចាំច្បាស់លាស់ដែរ។ បានទៅដើមខែធ្វើព្រលានមុនគេ ហើយចាប់ផ្ដើមគាស់ដីគាស់អីហ្នឹង។

[១៥:៤៥:១៥]

**សៈ** ចម្លើយលោកដូចជាមិនសូវច្បាស់ទេ។ រោងឡាន ដាក់ត្រាក់ទ័រហ្នឹង ស្ថិតនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ឬក៏នៅកន្លែងណាផ្សេង?

**ឆ៖** រោងដាក់ឡាន ដាក់រ៉ូឡូនៅកំពង់ឆ្នាំង នៅក្រាំងលាវហ្នឹងតែម្ដង អត់មាននៅណា ធ្វើកន្លែងហ្នឹងដាក់។ នៅក្រាំងលាវកំពង់ឆ្នាំងហ្នឹងតែម្ដង អត់មានធ្វើនេះ ធ្វើនៅកំពង់ឆ្នាំង។

**សៈ** តើលោកជាអ្នកទទួលខុសត្រូវរោងដាក់ឡានហ្នឹងតែម្ដង ឬក៏យ៉ាងម៉េច? ហើយលោកត្រូវធ្វើ ត្រូវរាយការណ៍ទៅអ្នកណា ទៅតាល្វៃ ឬក៏ទៅអ្នកណាផ្សេង?

**ឆ៖** បាទ ខ្ញុំអត់មែនអ្នកគ្រប់គ្រងធ្វើទេ ព្រោះខ្ញុំជាយុទ្ធជន។ គេទេឈ្មោះ ស៊ុំ តែមិនដឹងនៅឯណា។ ស៊ុំ ជាអ្នកធ្វើប្រធានគ្រប់គ្រងធ្វើឡាន -- ធ្វើរោងដាក់ឡានហ្នឹង។ ខ្ញុំស្គាល់តែឈ្មោះ ស៊ុំ ហ្នឹងគាត់ធ្វើប្រធាន តែបច្ចុប្បន្នមិនដឹងនៅឯណាអត់ដឹង។ ព្រោះខ្ញុំអ្នកដែលធ្វើ ព្រោះខ្ញុំជាប់ពាក់ព័ន្ធអីចឹង គេមិនឲ្យធ្វើអីផ្សេងទៀតទេ ក្រៅពីយុទ្ធជនហ្នឹង។

[១៥:៤៦:៥៩]

**សៈ** ខ្ញុំនឹងអានចម្លើយរបស់លោកមួយទៀត គឺនៅក្នុងឯកសារដដែលគឺ E3/5273, ភាសាខ្មែរគឺ 00282941, ជាភាសាបារាំង 00355856, ជាភាសាអង់គ្លេសគឺ 00290500។ លោកបានឆ្លើយថា "នៅពេលសាងសង់ដំបូងហ្នឹងគឺមានតែមនុស្សតែ ១០នាក់ដែលមានឈ្មោះ សុង ជាមេក្រុម និងមានជនជាតិប៉េកាំងចំនួន១០នាក់ដែលជាអ្នកជំនាញ ដូចជាពិសោធដី និងវាស់វែងស្ទង់។ ក្រុមខ្ញុំជាមួយនឹងចិនទាំងនោះត្រូវជិះតាមឡានក្រុងធំៗចេញពីកំពង់ឆ្នាំងនៅពេលព្រឹកម៉ោងប្រាំពីរ មកការដ្ឋាននៅក្រាំងលាវ ហើយត្រឡប់ទៅវិញនៅម៉ោងដប់មួយដើម្បីហូបបាយ។ ម៉ោងពីររសៀលត្រឡប់មកធ្វើការវិញ និងបញ្ចប់ទៅម៉ោងប្រាំល្ងាចជារៀងរាល់ថ្ងៃ"។ ហើយលោកបានបន្ថែមទៀតថា៖ "ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងចាប់ផ្ដើមដំបូងនៅខែមីនា ឆ្នាំ១៩៧៦"។ ក្រៅពីឈ្មោះ សុង តើលោកចាំឈ្មោះអ្នកផ្សេងទៀតដែលនៅក្នុងក្រុម១០នាក់ជាមួយលោកទេ?

**ឆ៖** ខ្ញុំដូចអត់ចាំទេ ភ្លេចអស់ហើយ បើយូរដែរទៅហើយ មិនដឹងពីណា ដឹងជាពីណី អស់។

អត់មានចាំឈ្មោះទេ។ ចាំឈ្មោះ សុង១ នេះមួយតែម្ដង គាត់ស្លាប់បាត់ទៅហើយ។ អត់មានស្គាល់ពីណាពីណីទៀត ព្រោះសម័យនុំងធ្វើការជាមួយគ្នា ធ្វើអត់មានជជែករកគ្នាអីបានយូរទេ គិតតែពីខំធ្វើ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** តើលោកដឹងទេថា អ្នកទាំង ១០នាក់ហ្នឹងគឺមកពីកងពល៥០២ មែនទេ?

**ឆ៖** បាទ មកពីកងពល៥០២ដូចគ្នាទេ មិនមែននៅក្រុមជាមួយគ្នាណា គេយកចម្រុះមក។ គេយកពីនេះមួយ នោះមួយ យកមកដាក់។ ខ្ញុំវាភ្លេចឈ្មោះអស់ហើយ អត់បានចាំ អត់បានសិក្សារឿងហ្នឹងផង។

[១៥:៤៩:៥៧]

**ស៖** កាលពីមុននោះ លោកបាននិយាយថា តាល្វៃ ដកលោកចេញ។ អ៊ីចឹង អ្នកដែលទៅជាមួយលោកហ្នឹងគឺសុទ្ធតែអ្នកដែលគេដកចេញមែនទេ ឬក៏មិនមែនអ៊ីចឹងទេ គឺមានន័យថាគេបញ្ជូនមកហ្នឹងគឺដោយសារតែគេទុកចិត្តទេ?

**ឆ៖** បាទ គេអ្នកគេបញ្ជូនមកហ្នឹងទុកចិត្តហ្នឹងខ្លះ អ្នកអត់ទុកចិត្តខ្លះ។ អ្នកអត់ទុកចិត្តនៅកូនក្រុមគេហ្នឹង អត់មានបានធ្វើអីទេ។ ដូចខ្ញុំ ដូចអី ជាប់និន្នាការអ៊ីចឹង អត់មានឲ្យធ្វើអីទេ។ ស្ដាប់តែបញ្ជាគេឲ្យធ្វើៗ គេឲ្យសម្រាកៗ។

**ស៖** អម្បាញ់មិញនេះ លោកនិយាយអំពីកម្មករប្រហែលជា ១០០០នាក់ ដែលមកធ្វើការនៅការដ្ឋាន។ តើលោកអាចជម្រាបបានទេថា កម្មករទាំង១០០០នាក់ជាងហ្នឹងមកពីណាខ្លះ? មកពីកងពល៥០២ ទាំងអស់តែម្ដង ឬក៏មានមកពីកងពលណាផ្សេងទៀត?

**ឆ៖** បាទ មិនមែនមកពីកលពល៥០២ហ្នឹង មកគ្រប់កងពល គ្រប់ភូមិភាគ តាំងពីនិរតី តាំងពីបូព៌ា តាំងពីបស្ចិម។ គេធ្វើការរៀង១ខ្លួនទៅ ខាងគេ គេកាន់អាត្រាក់ កាន់ឡានអ៊ីចឹងទៅ។ ខ្ញុំនេះធ្វើតែរោងឡានអ៊ីចឹងទៅ តែមិនដឹងឈ្មោះអី១ខ្ញុំអត់ស្គាល់ បើគេធ្វើការបែកគ្នា។ មិនដឹងថាកងពលណា១ ខ្ញុំដឹងតែកងពលបូព៌ា ហើយនិងនិរតី បស្ចិមហ្នឹង។

[១៥:៥២:០២]

**ស៖** តើលោកដឹងទេថា កងទ័ពប៉ុន្មាននាក់មកពីកងពល៥០២ហ្នឹង ដែលគេបញ្ជូនទៅការដ្ឋានព្រលានយន្តហោះហ្នឹង? ហើយពួកគេទាំងអស់ហ្នឹងមានមុខងារអ្វីខ្លះ?

**ឆ៖** ខ្ញុំអត់ដឹងច្បាស់ ប៉ុន្មាននាក់១ ខ្ញុំអត់ដឹង។ មិនដឹងជាមុខងារខាងអី១ ខ្ញុំវាមិនសូវដឹងដែរ។

និយាយរួមទៅអត់បានដឹងជ្រាប អត់បានសួរគេផង។ ព្រោះធ្វើការថ្ងៃល្ងាចឡើង ដឹងតែលាងដៃលាងជើង ហូបបាយហើយ មិនបានទៅសួរគេសួរអីអ៊ីចឹងទេ។ ខ្លាច។

**សះ** នៅពេលដែលកងទ័ពមកពីភូមិភាគផ្សេងៗមកធ្វើការនៅការដ្ឋានហ្នឹង គេមានធ្វើបញ្ជីចុះឈ្មោះកងទ័ពទាំងអស់ហ្នឹងទេ?

**ផះ** បាទ ខ្ញុំអត់ដឹងដែរ មិនដឹងគេធ្វើបញ្ជីចុះឈ្មោះ មិនដឹងជាអី ខ្ញុំវាអត់ដឹងរលីងអ៊ីចឹងតែម្តង។ ព្រោះថ្ងៃល្ងាចឡើងដឹងតែធ្វើការរួច មកធ្វើការ សម្រាកវិញ។ ត្រូវកត់ឈ្មោះ ត្រូវកត់អីមិនដឹង ខ្ញុំអត់ដឹងដែរ ព្រោះការងាររបស់គេ ខ្ញុំយុទ្ធជនអ៊ីចឹងអត់ដឹងរឿងគេ។

**សះ** តើលោកដឹងទេថា ក្រោយពីកម្មករជាង១០០០នាក់មកដល់ហើយហ្នឹង តើក្រោយទៀតមកហ្នឹង មានកម្មករផ្សេងទៀតមកទេនៅឆ្នាំ៧៧, ៧៨នុ៎ង? ហើយបើសិនជាមាន តើអ្នកទាំងអស់ហ្នឹងមកពីខាងណា? មកពីភូមិភាគណា? មកពីកងពលណា?

[១៥:៥៤:០៩]

**ផះ** បាទ ខ្ញុំអត់ដឹង។ ដឹងឃើញតែគ្នាប៉ុន្មានហ្នឹង ឃើញតែនៅធ្វើហ្នឹង រួចមកប៉ុន្មានទៀត បើកន្លែងឆ្ងាយៗពីគ្នាឯណោះ។ គេមកនៅកើតមិនដឹង នៅលិចមិនដឹង បើខ្ញុំអត់ដឹង។ បើកន្លែងព្រលានហ្នឹងវាធំដែរមិនមែនតូចឯណា។ គេនៅខាងកើតមិនដឹង នៅខាងលិចមិនដឹង បើខាងលិចខ្ញុំឃើញហើយ ប៉ុន្តែខ្ញុំអត់ឃើញ ខ្ញុំថាអត់ដឹងហើយ។

**សះ** ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះនៅពេលក្រោយ។ ឥឡូវនេះ ខ្ញុំចង់សួរលោកថា តើលោកដឹងអំពីចំនួនអ្នកដែលធ្វើការនៅការដ្ឋានហ្នឹងទេ? ពីដំបូងលោកថាមានត្រឹម ១០នាក់។ ក្រោយមកមាន ១០០០នាក់។ អ៊ីចឹងនៅពេលដែលមកច្រើននោះ ខ្ញុំចង់ដឹងថាមានរាប់ពាន់ ឬក៏រាប់ម៉ឺន?

**ផះ** បាទ ខ្ញុំមើលឃើញប្រហែលជាមួយពាន់ហ្នឹងហើយយ៉ាងមើលទៅ អត់មានដល់ម៉ឺនទេ ព្រោះវាពិបាកដែរកន្លែងហ្នឹងវាធំ រួចថ្ងៃឡើងបើកឡានបាត់ៗអស់ទៅ ចេញទៅតាមណា តាមណី។ ដឹងទៅ -- ខ្លះគេដឹកថ្ម ខ្លះគេដឹកខ្សាច់អ៊ីចឹងទៅ ខ្ញុំវាអត់ -- ព្រឹកឡើងដឹងតែធ្វើការ អត់ដើរទៅណាទេ ដឹងតែធ្វើការនៅនឹងកន្លែងហ្នឹងតែម្តង។ ស្ថិតិសរុបអីខ្ញុំអត់ដឹងទេ ប្រហែលជាមួយពាន់នាក់អីហ្នឹង។ អត់បានដើរចេញក្រៅនឹងគេ នៅតែក្នុងកន្លែងការដ្ឋានធ្វើការរបស់ឯងហ្នឹង។

**សះ** បើតាមលោកដឹងកម្មករទាំងអស់ដែលធ្វើការនៅការដ្ឋាននោះ សុទ្ធតែជាកងទ័ពមែនទេ?

[១៥:៥៥:១២]

**ឆ៖** បាទ សុទ្ធតែកងទ័ពទាំងអស់ អត់មានប្រជាពលរដ្ឋអីឡូកឡំ សុទ្ធសាច់តែម្តង កងទ័ព អត់មានប្រជាពលរដ្ឋណាចូលឡូកឡំអីគ្នាទេ មានតែកងទ័ព ហើយនិងក្រុមចិន – ក្រុមចិនដែលមក ជំនួយបច្ចេកទេសធ្វើតែម្តងហ្នឹង ហើយកងទ័ពហ្នឹង អត់មានអ្នកណាឡូកឡំជាមួយទេ។

**ស៖** ក្នុងចំនោមកម្មករដែលធ្វើការនៅទីនោះ នៅពេលដែលទៅដល់ភ្លាមហ្នឹង ពួកគេដកកាំភ្លើង យកចេញ ហើយនៅពេល នៅកន្លែងហ្នឹងមានអ្នកណាដែលគេអ្នករក្សាទុកកាំភ្លើងទាំងអស់ហ្នឹងទេ?

**ឆ៖** បាទអត់ ទៅដល់ភ្លាមអត់ឃើញៗកាំភ្លើងផង តែដឹងគេដកតាំងពីណាអីពីណី ខ្ញុំអត់ដឹងដែរ បើទៅដល់ឃើញគេធ្វើព្រលានហ្នឹង មើលឃើញតែពីចម្ងាយអត់បានទៅជិតទេ ប៉ុន្តែអត់មានកាំភ្លើងទេ។ មិនដឹងគេដកតាំងពីថ្ងៃរណា អីថ្ងៃរណី ខ្ញុំអត់ដឹងទេ។ អត់មានឃើញកាំភ្លើងយកចូលទៅទេ។ មានតែ កាំភ្លើងកងការពារជាងហ្នឹងតែម្តង មាន បើថាកងទ័ពធ្វើព្រលាន ដូចខ្ញុំនេះអីចឹងអត់មានទេ។

**ស៖** អីចឹងមានន័យថា កងទ័ពដែលធ្វើការនៅដ្ឋានទាំងអស់ គឺត្រូវបានគេយាមកាមដោយ ទាហានដែលមានកាំភ្លើងមែនទេ?

**ឆ៖** បាទ អ្នកយាមមានកាំភ្លើង ប៉ុន្តែអ្នកយាមហ្នឹងឃើញតែនៅតាមកន្លែង តាមក្រុមតាមអី អត់មានឃើញដើរជិតកន្លែងធ្វើការហ្នឹងទេ។ ឃើញនៅឆ្ងាយៗពីកន្លែងធ្វើការ ដែលគេមានកាំភ្លើងមាន អីហ្នឹង។

[១៥:៥៨:៣៤]

**ស៖** បើនៅឆ្ងាយអីចឹង តើអ្នកយាមហ្នឹងគាត់ធ្វើអ្វីខ្លះ គាត់ដើរល្បាត ឬមើលអ្វីដែលបានកើត ឡើងនៅការដ្ឋានហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** គេដើរល្បាតខាងៗហ្នឹង ដើរតាមតែផ្លូវចុះឡើងៗហ្នឹង។ អ្នកធ្វើការ ធ្វើការព្រលានដែរ ហើយដល់ល្បាតយាមខាងៗ មិនដឹងគេយាមអី។

**ស៖** ដំបូងឡើយលោកនិយាយថា លោកស្នាក់នៅកំពង់ឆ្នាំងជាមួយអ្នកបច្ចេកទេសចិន នៅ ពេលដែលក្រុមលោកមានគ្នា១០នាក់។ ចុះក្រោយមក លោកសម្រាកនៅការដ្ឋានសាងសង់ព្រលានយន្ត ហោះហ្នឹងតែម្តង ឬក៏លោកនៅតែបន្តស្នាក់នៅកំពង់ឆ្នាំង?

**ឆ៖** បាទ ដល់ពេលធ្វើហ្គាវ៉ាសឡានធ្វើអីរួច ខ្ញុំស្នាក់នៅកន្លែងព្រលានហ្នឹងតែម្តង កន្លែងខាង លិចព្រលានហ្នឹង អត់មានស្នាក់នៅកំពង់ឆ្នាំងអីទៀតទេ ព្រោះធ្វើកន្លែងរួចហើយ គេយកមកដាក់ឯហ្នឹង។ នៅតាមរោងតាមអីហ្នឹង កន្លែងនៅតាមរោងហ្នឹង។

**ស៖** កន្លែងស្នាក់នៅហ្នឹងគឺសម្រាប់តែទាហានមកពីកងពល៥០២ ឬក៏សម្រាប់អ្នកផ្សេងទៀត?

**ឆ៖** សម្រាប់តែពួកកង៥០២ ប៉ុន្តែគេនៅតាមក្រុមគេ គេនៅតាមមួយក្រុមៗ មិនមែននៅច្របូកច្របល់គ្នា។ អានេះខាងក្រុមខ្ញុំធ្វើហ្កាវ៉ាសហ្នឹងនៅមួយក្រុមអ៊ីចឹងទៅ កន្លែងគេធ្វើខាងបើកឡានបើកអី ខាងចាក់សាំង ចាក់អី គេនៅមួយក្រុមគ្នាគេទៅ អត់នៅជាមួយគ្នាទេ នៅផ្សេងៗពីគ្នា។

**ស៖** តើលោកដឹងទេថា ព្រលានយន្តហោះដែលគេកំពុងសាងសង់ហ្នឹង ជាព្រលានយន្តហោះសម្រាប់ជនស៊ីវិល ឬក៏ជាព្រលានយន្តហោះសម្រាប់យោធា?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ មិនដឹងខាងអី បើគេឲ្យធ្វើអ៊ីចឹង ចេះតែធ្វើទៅតាមគេទៅ។ បើគេអត់ប្រាប់ផ្តល់អីផង មិនដឹងគេសម្រាប់យោធា មិនដឹងគេសម្រាប់ស៊ីវិល ខ្ញុំអត់ដឹង។

[១៦:០១:៣៤]

**ស៖** នៅពេលប្រជុំ ឬក្នុងឱកាសផ្សេងទៀត តើកម្មាភិបាលមានប្រាប់លោកទេថា ការដ្ឋានហ្នឹងជាការដ្ឋានក្តៅ ជាការដ្ឋានអាទិភាព?

**ឆ៖** បាទ ខ្ញុំ ពេលប្រជុំ គេអត់និយាយប្រាប់ពីរឿងអ៊ីចឹងៗផង គេប្រាប់តែពីរឿងយើងខំធ្វើការអត់ខំធ្វើការ គេទិតៀន គេរករឿង។ អារឿងប្រជុំព្រលានហ្នឹងស្អីៗ ខ្ញុំអត់មានឮគេប្រាប់ផង អត់ឮមេក្រុម មេអី គេនិយាយប្រាប់ផង។

**ស៖** ឥឡូវនេះ ខ្ញុំសួរសំណួរពីរបីបន្ថែមពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះកម្មករ។ ខ្ញុំនឹងដកស្រង់ចម្លើយរបស់លោកនៅក្នុងកំណត់ហេតុ E3/5273, ជាភាសាខ្មែរគឺ 00282941 រហូតទៅដល់ 42, ជាភាសាបារាំងគឺ 00355856, ជាភាសាអង់គ្លេសគឺ 00290500។ គេសួរនៅពេលនោះឲ្យលោករៀបរាប់បន្ថែមអំពីទិដ្ឋភាពផ្សេងៗនៃការធ្វើព្រលានយន្តហោះនោះ ពេលនោះលោកឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ “មនុស្សរាប់ពាន់នាក់ធ្វើការនៅទីនោះ អ្នកទាំងអស់នោះត្រូវបានគេដឹកមកពីខាងបស្ចិម និរតី និងបូព៌ា ប៉ុន្តែភាគច្រើនគឺមនុស្សមកពីខាងបូព៌ា ហើយត្រូវគេសម្លាប់ច្រើនជាងគេ”។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំនឹងនិយាយអំពីការបាត់ខ្លួនរបស់អ្នកមកពីភូមិភាគបូព៌ានេះនៅពេលក្រោយ។ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សួរលោកថា តើលោកដឹងទេថាមានទាហានមកពីភូមិភាគឧត្តរចាស់ ឬក៏ទាហានមកពីភូមិភាគកណ្តាលដែលស្ថិតនៅក្នុងកងពល៣១០ និង៤៥០ លោកធ្លាប់ឮទេថា មានកងពល -- មានទាហានមកពីកងពលទាំងពីរនេះ?

[១៦:០៤:០៤]

**ផ៖** បាទ ខ្ញុំដែលឮផង អត់ដែលឃើញផង មិនដឹងគេមកនៅចន្លោះណា ចន្លោះណី ក៏ខ្ញុំអត់ឃើញ អត់ឮ មិនឮទេ។ ខ្ញុំឮតែកងពល៥០២មួយហ្នឹងឯង កងពលមួយទៀត មិនដឹងកងពលប៉ុន្មានអីប៉ុន្មាន លេខប៉ុន្មាន ខ្ញុំមិនសូវដឹង អត់ដឹងហ្មង។

**ស៖** ក្នុងសម្រង់ចម្លើយរបស់លោក ហើយខ្ញុំអាននោះ លោកបានបញ្ជាក់ថាមានមនុស្សមកពីភូមិភាគបូព៌ា។ តើអ្នកមកពីបូព៌ាហ្នឹងមានសញ្ញាអីសម្គាល់ទេ? ឧទាហរណ៍ដូចជាពួកគេមានខោអាវ ឬក៏មានក្រមាអីខុសប្លែពីអ្នកផ្សេងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ដូចដែលខ្ញុំបានធ្វើជាញឹកញាប់ ខ្ញុំសូមរំឭកថា សំណួរនេះគឺជាសំណួរ -- គួរតែសួរសំណួរបើក។ គួរតែសួរថាតើគាត់មានសញ្ញាសម្គាល់អីទេ កុំសួរបន្ថែមខោអាវ សួរបន្ថែមក្រមាអីចឹង សួរតែសំណួររបៀបជាបើកវិញ ហើយឲ្យសាក្សីគាត់ឆ្លើយវិញ កុំឲ្យលោកព្រះរាជអាជ្ញាអានឲ្យគាត់ស្តាប់ហើយ ឲ្យគាត់ថាតាម។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំនឹងសម្រួលសំណួរខ្ញុំឡើងវិញ។

[១៦:០៥:៥៥]

**លោក វ៉ិចទ័រ កូប៉េ៖**

គឺជាការជំទាស់ដដែលដែលខ្ញុំបានធ្វើកន្លងមកហើយ គឺថាព្រះរាជអាជ្ញាគាត់បន្តនិយាយអំពីកម្មករ អំពីប្រជាជន អំពីការដ្ឋាន។ ចំពោះខ្ញុំៗមើលទៅដូចជាគួរឲ្យច្របូកច្របល់ណាស់ ព្រោះថាយើងកំពុងតែនិយាយពីកងទ័ពមកពីកងពល៥០២ មកពីកងពលផ្សេងៗ មកពីទីកន្លែងផ្សេងៗ។ ដូច្នេះគឺថាយើងនិយាយអំពីកងទ័ព។ ដើម្បីជាប្រយោជន៍ក្នុងការស្វែងរកការពិត យើងគួរតែនិយាយអំពីបុគ្គលទាំងអស់នោះថាជាកងទ័ព មិនត្រូវហៅថាជាកម្មករនោះឡើយ ព្រោះទីនោះគឺជាការដ្ឋានរបស់កងទ័ព យើងគួរតែមានការប្រុងប្រយ័ត្ននៅក្នុងការប្រើប្រាស់ពាក្យទាក់ទងទៅនឹងកងទ័ព។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ លោកប្រធាន ខ្ញុំប្រើពាក្យរបស់សាក្សីទេ ដែលគាត់ឆ្លើយនៅក្នុងកំណត់ហេតុរបស់គាត់ៗនិយាយអំពីកម្មករ។ អ៊ីចឹងហើយបានជាខ្ញុំប្រើពាក្យថាកម្មករនោះ។ ខ្ញុំរៀបចំសំណួរឡើងវិញ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោកសាក្សី អ្នកដែលធ្វើការមកពីភូមិភាគបូព៌ានោះ គាត់មានស្លៀកសម្លៀកបំពាក់ខុសពីកម្មករផ្សេងទៀតទេ?

**ឆ៖** បាទ អត់ទេ ស្លៀកពាក់ខោអាវខ្មៅដូចគ្នា អត់មានស្លៀកខុសគ្នាផង ស្លៀកតែខោអាវខ្មៅហ្នឹង មួកកាតិប តែប៉ុណ្ណឹង។

**ស៖** លោកក៏បាននិយាយអំពីការប្រជុំ។ ខ្ញុំនឹងដកស្រង់ចម្លើយផ្សេងមួយទៀតរបស់លោក គឺជាភាសាខ្មែរ គឺ 00282942, ជាភាសាបារាំងគឺ 00355857, ជាភាសាអង់គ្លេសគឺ 00290551។ លោកបាននិយាយដូចតទៅ៖ "ឈ្មោះ ល្វៃ ជាប្រធានទទួលបន្ទុកការដ្ឋានព្រលានយន្តហោះទាំងមូលតែម្តង។ ខ្ញុំបានឃើញ ល្វៃ កោះហៅអ្នកធ្វើការដ្ឋានមកប្រជុំនៅទួលអំពិល នៅកន្លែងព្រលានយន្តហោះជាច្រើនដង"។ សូមបញ្ចប់ការដកស្រង់។ តើលោកអាចជម្រាបបន្ថែមបានទេ ថាតើ ល្វៃ គាត់កោះហៅអ្នកណាខ្លះមកចូលរួមប្រជុំ?

[១៦:០៨:៥១]

**ឆ៖** គាត់កោះហៅដូចថា ពីអនុសេនាធំ វរសេនាតូច តែប៉ុណ្ណឹង ហៅប្រជុំៗកន្លែងគាត់ហ្នឹងទៅ ខ្ញុំអត់ -- កន្លែងខ្ញុំវាឆ្ងាយដែរ ឃើញតែគេមកប្រជុំគរគោក គរដីហ្នឹង។ មិនដឹងគេប្រជុំរឿងអី ខ្ញុំវាមិនសូវដឹង អត់ដឹង មួយអាទិត្យជួនកាលប្រជុំម្តង ជួនកាលមានការងារអី គេប្រជុំអត់ដល់មួយអាទិត្យទៅប្រជុំទៅ ឃើញតែៗគេមកប្រជុំអ៊ីចឹង។ ខ្ញុំមើលតែពីកន្លែងខ្ញុំទៅឃើញតែយ៉ាងអ៊ីចឹង អត់មានឃើញខុសពីហ្នឹងផង ឃើញតែប្រជុំអ៊ីចឹង។

**ស៖** តើការប្រជុំហ្នឹងគឺសម្រាប់តែកម្មាភិបាល និងអ្នកមើលការខុសត្រូវនៅការដ្ឋាននោះ ឬក៏មានកម្មករដែលជាកងទ័ពហ្នឹង បានចូលរួមក្នុងកិច្ចប្រជុំនោះដែរ?

**ឆ៖** អត់មានកងទ័ព អត់មានចូលប្រជុំទេ កម្មករ មានតែមេគេធំៗគេទៅប្រជុំ ចំណែកអ្នកតូចតាចអីអត់មានអ្នកណាទៅជិតបានទេ ព្រោះមានគេអ្នកយាមនៅក្បែរហ្នឹង។ គេមិនឲ្យចូល អត់ឲ្យចូលជិតផង យើងអត់មានភារកិច្ចអីទៅផង យើងនៅឯកន្លែងយើងនេះ។

**ស៖** ខ្ញុំមិនសួរយល់លោកសាក្សី។ លោកជាអ្នកទទួលខុសត្រូវ ជាអ្នកគ្រប់គ្រងរោងដាក់ឡានហ្នឹង ឬក៏លោកគ្រាន់តែជាអ្នកធ្វើការធម្មតានៅក្នុងរោងឡានហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំជាអ្នកធ្វើការក្នុងរោងឡានធម្មតា ខ្ញុំអត់អ្នកទទួលខុសត្រូវទេ។ អ្នកទទួលខុសត្រូវឈ្មោះ ស៊ុំ ផ្សេងតែមិនដឹង តែបច្ចុប្បន្នមិនដឹងនៅឯណា ខ្ញុំអត់ដឹង។ ខ្ញុំជាយុទ្ធជន អ្នកធ្វើការផ្សេង។

[១៦:១១:២៦]

**ស៖** តើ ស៊ុំ មានបានរៀបចំកិច្ចប្រជុំ ហើយមានកោះហៅលោកចូលទេ ហើយពេលគេប្រជុំហ្នឹងគេនិយាយអំពីអ្វីខ្លះ?

**ឆ៖** គេប្រជុំធំៗ គេអត់ហៅយើងប្រជុំទេ ប្រជុំតែ បើមេក្រុមមេអីគាត់ហៅប្រជុំ តែមេក្រុមបើថាកូនក្រុមគ្នា១០នាក់ហ្នឹង ហៅប្រជុំគ្នាប៉ុណ្ណឹងនាក់។ ប្រជុំប្រាប់ឲ្យធ្វើឡាន ឲ្យធ្វើសម្ភារៈរោងដូចជាអីហ្នឹង។ ឲ្យយើងខំប្រឹងប្រែងធ្វើតែប៉ុណ្ណឹង អត់មានប្រាប់រឿងអីៗផង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ។

បាទ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី១១ ខែមិថុនា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី កែវ គីន និងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-901 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

[១៦:១២:៣៩]

អង្គជំនុំជម្រះអរគុណលោក កែវ គីន ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈលោកជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយឥឡូវនេះលោកអាចសម្រាកបានហើយ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី កែវ គីន វិលត្រឡប់ទៅកន្លែងដែលគាត់ស្នាក់នៅវិញចុះ និងឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែក ឲ្យបានមុន -- នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប ខៀវ សំផ និង នួន ជា

ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៣ នាទី)*